សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្ដោះអាសន្ន

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ណា ម៉ារីយ៉ា**

កញ្ញា **អ៊ុំ ច័ន្ទលក្ខិណា**

សាស្ត្រាចារ្យណែនាំ

លោក **ច័ន្ទ តារាស្មី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២២**

ឆ្នាំចូលសិក្សា **២០១៨**

ឆ្នាំសរសេរសារណា **២០២២**

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំ **ណា ម៉ារីយ៉ា** និង **អ៊ុំ ច័ន្ទលក្ខិណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២ សូមសម្តែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

- **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់យ៉ាងកក់ក្តៅ ប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ មិនអាចកាត់ថ្លៃបាន ព្រមទាំងបានអប់រំ ប្រៀនប្រដៅ និងផ្គត់ផ្គង់ជាថវិកាឱ្យយើងខ្ញុំ បានសិក្សាតាំងពីវ័យកុមារ រហូតមកដល់បច្ចុប្បន្ន។
- **ឯកឧត្តម សាកលវិទ្យាធិការ លុយ ចណ្ណា** ព្រឹទ្ធបុរស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបើកឱកាសដល់យើងខ្ញុំ បានចូលខ្លួនមកសិក្សា ស្វែងយល់ស្រាវជ្រាវ បង្កើននូវចំណេះដឹង និងបានផ្តល់ឱកាសឱ្យយើងខ្ញុំ បានសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។
- **លោក សាស្ត្រាចារ្យណែនាំ ច័ន្ទ តារារស្មី** គឺជាអ្នកចែករំលែកនូវចំណេះដឹងយ៉ាងច្រើនមហាសាលជូនដល់សិស្ស-និស្សិត ស្ទើរគ្រប់ជំនាន់ ជាពិសេស លោក សាស្ត្រាចារ្យណែនាំ បានយកចិត្តទុកដាក់ខ្ពស់ ក្នុងការពន្យល់យើងខ្ញុំទាំងពីរនាក់ ពីរបៀបក្នុងការតាក់តែង និងចំណុចខ្វះខាតនានាក្នុងកំឡុងពេលសរសេរសារណានេះ ដែល លោក សាស្ត្រាចារ្យណែនាំ គឺជាប្រទីបបំភ្លឺផ្លូវដល់យើងខ្ញុំឱ្យដើរចំគោលដៅ និងទទួលបានជោគជ័យជាស្ថាពរ លើការសរសេរសារណាបញ្ចប់ការសិក្សានេះ។
- **សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបាន ចែករំលែកចំណេះដឹងដល់រូបយើងខ្ញុំទាំងពីរ ពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ថ្ងៃយើងខ្ញុំទាំងពីរអាចមានឱកាសនៅក្នុងការសរសេរសារណាបន្សល់ទុកជាស្នាដៃដល់សិស្សនិស្សិតជំនាន់ក្រោយ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក មេត្តាប្រោសប្រទានពរជ័យ សិរីមង្គលជូនចំពោះ លោកអ្នកមានគុណ នៃយើងខ្ញុំ ឯកឧត្តម សាកលវិទ្យាធិការ សាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យទទួលបាននូវសុខភាពល្អបរិបូណ៌ ប្រាជ្ញាវាងវៃ កម្លាំងពលំមាំមួន ជោគជ័យគ្រប់ភារកិច្ច មានសុភមង្គលក្នុងក្រុមគ្រួសារ និងជាពិសេសទទួលបាននូវពរជ័យប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# **អារម្ភកថា**

មានទ្រឹស្តីមួយបានពោលថា «**ទុកទៅ កំពង់នៅ**» គឺជាទ្រឹស្តី ដែលជាមាគ៌ា និងជាកាតាលីករ យ៉ាងសំខាន់ ដែលបានជំរុញកម្លាំងចិត្ត នៃយើងខ្ញុំ ឱ្យផ្តួចផ្តើមសិក្សាស្រាវជ្រាវសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង ដើម្បីបន្សល់ទុកជាស្នាដៃដល់និស្សិតជំនាន់ក្រោយ បានសិក្សាស្វែងយល់បន្ថែមជាគំនិត និងជាពុទ្ធិ បើទោះបីជាយើងខ្ញុំ បានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យហើយយ៉ាងណាក្តី។

សៀវភៅសារណា ដែលមានប្រធានបទ ស្តីពី «**ការឃុំខ្លួនបណ្តោះអាសន្ន**» ដែលកំពុងស្ថិតនៅក្នុងដៃរបស់លោកអ្នកនេះ អាចកើតចេញជាផ្លែផ្កាបាន អាស្រ័យលើកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ យ៉ាងយកចិត្តទុកដាក់ពីសំណាក់យើងខ្ញុំផ្ទាល់ ក្នុងការសម្រិតសម្រាំង ចម្រាញ់យកខ្លឹមសារ ដែលមានគុណភាព និងសារៈប្រយោជន៍ ជូនចំពោះអ្នកដែលមានបំណងសិក្សាស្វែងយល់បន្ថែម អំពីនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន។ រាល់គ្រប់កិច្ចការដែលបានចងក្រងមកនេះ គឺសុទ្ធសឹងតែបានដកស្រង់ចេញពីក្រមនីតិវិធីព្រហ្មទណ្ឌ ឯកសារមេរៀនដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ឯកសារពាក់ព័ន្ធនានា និងការអនុវត្តជាក់ស្តែង នៅស្ថាប័នអយ្យការ។

ជាចុងបញ្ចប់ យើងខ្ញុំ ដែលជាអ្នកសិក្សាស្រាវជ្រាវ និងតាក់តែងសារណានេះឡើង សូមលំអោនកាយខន្តីអភ័យទោសចំពោះសាស្ត្រាចារ្យ និងលោកអ្នកសិក្សាទាំងឡាយ នូវរាល់កំហុសឆ្គង ទាំងអត្ថន័យ អត្ថរស ខ្លឹមសារ ប្រយោគឃ្លោងឃ្លា ពាក្យពេចន៍ ក៏ដូចជាកំហុសអក្ខរាវិរុទ្ធ ដែលយើងខ្ញុំបានបង្កើតមានឡើងដោយអចេតនានៅក្នុងសៀវភៅសារណានេះ យើងខ្ញុំរីករាយទទួលស្វាគមន៍នូវរាល់មតិរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានជានិច្ច។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយក្បាលនេះ នឹងក្លាយទៅជាឯកសារជំនួយស្មារតី ក្នុងការសិក្សាស្រាវជ្រាវ និងជាគន្លឹះជួយបំភ្លឺផ្លូវដល់និស្សិតជំនាន់ក្រោយ អ្នកអាន និងអ្នកស្រាវជ្រាវទូទៅ បានសិក្សាស្វែងយល់បន្ថែម៕

# មាតិកា


ទំព័រ

សេចក្តីផ្តើម ........................................................................................ ១

## ជំពូកទី១
## ការឃុំខ្លួនបណ្តោះអាសន្ន

ផ្នែកទី១៖ គោលការណ៍ទូទៅ នៃការឃុំខ្លួនបណ្តោះអាសន្ន ............................ ៦

កថាខណ្ឌទី១៖ លក្ខខណ្ឌ នៃការឃុំខ្លួនបណ្តោះអាសន្ន ................................ ៧

១.១. លក្ខខណ្ឌ នៃការកំណត់បទល្មើសចំពោះការចោទប្រកាន់ ........................ ៧

១.១.១. លក្ខខណ្ឌ ក្នុងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ................................ ៧

១.១.២. លក្ខខណ្ឌ ក្នុងការចោទប្រកាន់ចំពោះបទមជ្ឈិម ................................ ១០

១.២. លក្ខខណ្ឌ នៃការកំណត់ទោសដាក់ពន្ធនាគារ ........................................ ១១

កថាខណ្ឌទី២៖ មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន និងមូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្ន ........................................ ១២

២.១. មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន ................................................ ១២

២.២. មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្ន ............................................ ១៥

២.២.១. មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើអាយុ ................ ១៦

២.២.២. មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើ លក្ខណៈសម្បត្តិ របស់ជនត្រូវចោទ ........................................ ១៦

កថាខណ្ឌទី៣៖ ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន ................................ ២០

៣.១. ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋ ............................ ២០

៣.១.១. ការឃុំខ្លួននីតិជន ................................................................ ២១

៣.១.២. ការឃុំខ្លួនអនីតិជន ................................................................ ២១

៣.២. ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទមជ្ឈិម ............................ ២២

៣.២.១. ការឃុំខ្លួននីតិជន ................................................................ ២២

៣.២.២. ការឃុំខ្លួនអនីតិជន ................................................................ ២២

៣.៣. ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទល្មើសពិសេស ...................... ២៣

**ផ្នែកទី២៖ សិទ្ធិរបស់ជាប់ឃុំខ្លួនបណ្ដោះអាសន្ន**....................................................២៣
**កថាខណ្ឌទី១៖ សិទ្ធិទូទៅរបស់ជនជាប់ឃុំខ្លួនបណ្ដោះអាសន្ន**...............................២៣
១.១. សិទ្ធិស្នើសុំឱ្យបំពេញកិច្ច .......................................................................២៣
១.២. សិទ្ធិស្នើសុំឱ្យនៅក្រៅឃុំ.........................................................................២៥
១.៣. សិទ្ធិជ្រើសរើស ឬស្នើសុំមេធាវី...................................................................២៦
១.៤. សិទ្ធិប្ដឹងជំទាស់ចិត្ត...................................................................................២៧
១.៥. សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ ...............................................................២៨
១.៦. សិទ្ធិស្នើសុំបិទសំណុំរឿង ........................................................................២៨
១.៧. សិទ្ធិទទួលបានការត្រួតពិនិត្យពីមន្ត្រីពេទ្យ.......................................................២៩
១.៨. សិទ្ធិទទួលបានការការពារពីការធ្វើទារុណកម្ម និងផ្សេងៗទៀត.................................២៩
១.៩. សិទ្ធិក្នុងការប្ដឹងតវ៉ាចំពោះអំពើរំលោភបំពាន ....................................................២៩
១.១០. សិទ្ធិក្នុងការប្រតិបត្តិសាសនា....................................................................៣០
១.១១. សិទ្ធិទទួលបានរបបអាហារ .......................................................................៣០
១.១២. សិទ្ធិក្នុងការទទួលបានព័ត៌មាន និងដំណឹងផ្សេងៗ............................................៣១
**កថាខណ្ឌទី២៖ សិទ្ធិរបស់អនីតិជនក្នុងការជាប់ឃុំខ្លួនបណ្ដោះអាសន្ន** .................៣១
២.១. សិទ្ធិទទួលបានបន្ទប់ឃុំឃាំងឯកជន ............................................................៣២
២.២. សិទ្ធិទទួលបានជំនួយពីមេធាវី....................................................................៣២
២.៣. សិទ្ធិទទួលបានការព្យួរការសិក្សា និងការព្យួរការងារ ...........................................៣៣
២.៤. សិទ្ធិដទៃទៀតដែលគាំពារដោយច្បាប់...........................................................៣៣

## ជំពូកទី២
## នីតិវិធី នៃការឃុំខ្លួនបណ្ដោះអាសន្ន និងមិនឃុំខ្លួនបណ្ដោះអាសន្ន

**ផ្នែកទី១៖ដំណើរការ នៃការឃុំខ្លួនបណ្ដោះអាសន្ន**................................................៣៤
**កថាខណ្ឌទី១៖ ដំណាក់កាលព្រះរាជអាជ្ញា**...........................................................៣៥
១.១. តួនាទី និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា .........................................................៣៦
១.២. សេចក្ដីសន្និដ្ឋានស្ថាពរ..............................................................................៣៦

**កថាខណ្ឌទី២៖ ដំណាក់កាលចៅក្រមស៊ើបសួរ** ........ ៣៧
២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ........ ៣៩
២.២. ដីកាសម្រេច ........ ៤០
**កថាខណ្ឌទី៣៖ អានុភាព នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** ........ ៤០
**ផ្នែកទី២៖ ដំណើរការ នៃការមិនឃុំខ្លួនបណ្ដោះអាសន្ន** ........ ៤០
**កថាខណ្ឌទី១៖ ដំណាក់កាលព្រះរាជអាជ្ញា** ........ ៤២
១.១. តួនាទី និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ........ ៤៣
១.២. សេចក្ដីសន្និដ្ឋានស្ថាពរ ........ ៤៣
**កថាខណ្ឌទី២៖ ដំណាក់កាលចៅក្រមស៊ើបសួរ** ........ ៤៣
២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ........ ៤៣
២.២. ដីកាសម្រេច ........ ៤៤
**កថាខណ្ឌទី៣៖ អានុភាព នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន** ........ ៤៤
**ផ្នែកទី៣៖ ការតាក់តែងដីកាឃុំខ្លួនបណ្ដោះអាសន្ន ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន.** ........ ៤៤
**កថាខណ្ឌទី១៖ និយមន័យ ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** .. ៤៤
១.១. និយមន័យ ........ ៤៤
១.២. ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ........ ៤៥
១.២.១. ដើម នៃដីកា ........ ៤៥
១.២.២. តួ នៃដីកា ........ ៤៥
១.២.៣. បញ្ចប់ នៃដីកា ........ ៤៦
**កថាខណ្ឌទី២៖ និយមន័យ ទម្រង់ និងខ្លឹមសារ នៃដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន** ........ ៤៦
២.១. និយមន័យ ........ ៤៦
២.២. ទម្រង់ និងខ្លឹមសារ នៃដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន ........ ៤៦
២.២.១. ដើម នៃដីកា ........ ៤៧
២.២.២. តួ នៃដីកា ........ ៤៧
២.២.៣. បញ្ចប់ នៃដីកា ........ ៤៨

**កថាខណ្ឌទី៣៖ និយមន័យ គោលការណ៍ នៃទម្រង់ និងខ្លឹមសារ នៃការចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន** ..... ៤៨
២.១. និយមន័យ ..... ៤៨
២.២. ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ..... ៤៩
២.២.១. ដើម នៃដីកា ..... ៤៩
២.២.២. តួ នៃដីកា ..... ៤៩
២.២.៣. បញ្ចប់ នៃដីកា ..... ៥០

## ជំពូកទី៣
## បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** ..... ៥១
**កថាខណ្ឌទី១៖ ដំណើរការ នៃបណ្ដឹងឧទ្ធរណ៍** ..... ៥១
១.១. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ..... ៥១
១.២. ជនដែលមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ..... ៥២
១.៣. រយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍ ..... ៥២
១.៤. ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ ..... ៥២
**កថាខណ្ឌទី២៖ តុលាការ ដែលមានសមត្ថកិច្ច** ..... ៥៣
២.១. សភាស៊ើបសួរ ..... ៥៣
២.១.១. សាលដីការបស់សភាស៊ើបសួរ ..... ៥៤
២.១.២. រយៈពេលក្នុងការចេញសាលដីកា ..... ៥៤
**ផ្នែកទី២៖ នីតិវិធីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន** ..... ៥៤
**កថាខណ្ឌទី១៖ ដំណើរការ នៃបណ្ដឹងឧទ្ធរណ៍** ..... ៥៥
១.១. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ..... ៥៥
១.២. អ្នកដែលមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ..... ៥៥
១.៣. រយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍ ..... ៥៥

## ជំពូកទី៤
## បណ្ដឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីបណ្តឹងសាទុក្ខចំពោះសាលដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់សភាស៊ើបសួរ** ........ ៥៧
**កថាខណ្ឌទី១៖ ដំណើរការ នៃបណ្តឹងសាទុក្ខ** ........ ៥៧
១.១. ការដាក់ពាក្យបណ្តឹងសាទុក្ខ ........ ៥៧
១.២. អ្នកដែលមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ ........ ៥៨
១.៣. រយៈពេលធ្វើបណ្តឹងសាទុក្ខ ........ ៥៨
១.៤. ការបញ្ជូនពាក្យបណ្តឹងសាទុក្ខទៅសភាព្រហ្មទណ្ឌ........ ៥៩
**កថាខណ្ឌទី២៖ តុលាការ ដែលមានសមត្ថកិច្ច** ........ ៥៩
២.១. សភាព្រហ្មទណ្ឌ ........ ៥៩
២.១.១. សាលដីការបស់សភាព្រហ្មទណ្ឌ ........ ៦១
២.១.២. រយៈពេលក្នុងការចេញសាលដីកា ........ ៦១
**ផ្នែកទី២៖ នីតិវិធីបណ្តឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរអំពីការមិនឃុំខ្លួនបណ្តោះអាសន្ន** ........ ៦១
**កថាខណ្ឌទី១៖ ដំណើរការ នៃបណ្តឹងសាទុក្ខ** ........ ៦២
១.១. ការដាក់ពាក្យបណ្តឹងសាទុក្ខ ........ ៦២
១.២. អ្នកដែលមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ ........ ៦២
១.៣. រយៈពេលធ្វើបណ្តឹងសាទុក្ខ ........ ៦២
១.៤. ការបញ្ជូនបណ្តឹងសាទុក្ខទៅសភាព្រហ្មទណ្ឌ ........ ៦៣
១.៥. សាលដីការបស់សភាព្រហ្មទណ្ឌ........ ៦៣
១.៥.១. រយៈពេលក្នុងការចេញសាលដីកា ........ ៦៣

## ជំពូកទី៥
## បញ្ហាប្រឈមនានា និងដំណោះស្រាយក្នុងការអនុវត្តចំពោះការឃុំខ្លួនបណ្តោះអាសន្ន

**ផ្នែកទី១៖ បញ្ហាប្រឈម** ........ ៦៤
**កថាខណ្ឌទី១៖ ឋិដ្ឋភាពជាក់ស្តែងក្នុងការអនុវត្ត នីតិវិធីរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា** ........ ៦៤
១.១. អំពីការបណ្តុះបណ្តាល ........ ៦៤

១.២. អំពើពុករលួយ ...................................................................................... ៦៥
១.៣. ការចុះទៅអនុវត្តផ្ទាល់របស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា .................................. ៦៥
**កថាខណ្ឌទី២៖ ការអនុវត្តនៅក្នុងពន្ធនាគារ** ................................................ ៦៦
២.១.ការប្រើប្រាស់ហិង្សា និងទារុណកម្ម ................................................................ ៦៦
២.២.សិទ្ធិទទួលបានដំណឹង .............................................................................. ៦៦
២.៣. សិទ្ធិទទួលបានមេធាវីការពារក្តី..................................................................... ៦៦
**កថាខណ្ឌទី៣៖ ដំណោះស្រាយ**......................................................................... ៦៧
៣.១.ការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា.......................................... ៦៨
៣.១.១.ការពង្រឹងច្បាប់................................................................................ ៦៨
៣.១.២.ការបញ្ជូនរឿងទៅជម្រះក្តី.................................................................... ៦៨
៣.១.៣.ការដាក់ទណ្ឌកម្ម............................................................................. ៦៩
៣.២. ការអនុវត្តនៅក្នុងពន្ធនាគារ ...................................................................... ៧០
៣.២.១. ការពង្រឹងច្បាប់ ........................................................................... ៧០
៣.២.២. ការដាក់ទណ្ឌកម្ម .......................................................................... ៧១
**សេចក្តីសន្និដ្ឋាន**........................................................................................ ៧២
**អនុសាសន៍** ............................................................................................ ៧៤
**វាក្យស័ព្ទគតិយុត្តិ**
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ជាការពិតណាស់ ប្រទេសកម្ពុជា គឺជានីតិរដ្ឋដែលគ្រប់សកម្មភាពជាសត្យានុម័តត្រូវអនុវត្តទៅតាមច្បាប់ជាធរមាន។ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ បន្ទាប់ពីការចូលជាធរមាន នៃការប្រកាសឱ្យប្រើនូវក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ទម្រង់នេះពិតជាបានដើរតួនាទីយ៉ាងសំខាន់ណាស់សម្រាប់សាធារណៈជនទូទៅយកទៅប្រត្តិបត្តិ និងសម្រាប់យកទៅអនុវត្ត និងពង្រឹងនៅក្នុងវិស័យយុត្តិធម៌សម្រាប់ឱ្យអ្នកវិជ្ជាជីវៈដែលមានដូចជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និង មេធាវី យកទៅអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវយុត្តិធម៌នៅក្នុងសង្គមជាតិ។ ការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើទារុណកម្មខុសច្បាប់មកលើជនជាប់ឃុំ ពុំត្រូវបានអនុញ្ញាតឱ្យអាជ្ញាធរដែលមានសមត្ថកិច្ចប្រើប្រាស់ នូវអំណាចហួសពីអ្វីដែលច្បាប់ជាធរមានបានកំណត់នោះឡើយ ពីព្រោះកម្ពុជាមិនមែនជាប្រទេសដែលរស់នៅពីស្រមោលអតីតកាលដែលជាសម័យសង្គ្រាមសម្លាប់រាល អង្គាស ចាប់ចង ធ្វើទារុណកម្ម និងឃុំខ្លួនមនុស្សដោយស្រេចតែចិត្តនោះឡើយ។

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដ៏សំខាន់សម្រាប់អនុវត្ត ទៅលើការឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទដោយចៅក្រមស៊ើបសួរ ដើម្បីធានាឱ្យបាននូវនីតិវិធីស៊ើបសួរ។ ការចេញដីកាសម្រេចឃុំ ឬមិនឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ ដោយការផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ ត្រូវមានការផ្តល់យោបល់ និងការស្នើសុំតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអំពីសេចក្តីសម្រេចនោះក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃក្រោយការផ្តល់យោបល់។

ហេតុដូចនេះហើយ បានជាអ្នកច្បាប់ និងអ្នកសិក្សាទាំងឡាយ គួរស្វែងយល់នូវនីតិវិធីឃុំខ្លួនជាបណ្តោះអាសន្ន ដើម្បីស្វែងយល់អំពីលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរ ការស្វែងយល់អំពីសិទ្ធិរបស់អ្នកជាប់ឃុំ និងដំណោះស្រាយដែលមិនយល់ស្របអំពីការឃុំ ឬមិនឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ ដោយធ្វើការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនោះ។

## ២. ចំណោទបញ្ហា នៃការសិក្សាស្រាវជ្រាវ

នៅពេលបុគ្គលណាម្នាក់ បានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់បានបញ្ញត្តិជាធរមាន ចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិក្នុងការសម្រេចឃុំ ឬមិនឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទដោយផ្អែកលើលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិ។ សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ មិនមែនចេះតែសម្រេចដោយប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនហួសពីអ្វីដែលច្បាប់បានកំណត់នោះឡើយ។ ការសម្រេចអំពីការ

ឃុំ ឬមិនឃុំខ្លួនជាបណ្ដោះអាសន្នចំពោះជនត្រូវចោទ ត្រូវមានសំអាងហេតុ និងមូលហេតុដែលច្បាប់ផ្ដល់សិទ្ធិអំណាចឱ្យចៅក្រមក្នុងការពិចារណា និងថ្លឹងថ្លែងឱ្យបានហ្មត់ចត់។ ដូច្នេះហើយបានជាយើងបង្កើតឱ្យមាននូវចំណោទបញ្ហាមួយចំនួនដែលទាក់ទងនឹង នីតិវិធីក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរៈ

-តើអ្វីទៅគឺជាគោលការណ៍ នៃការឃុំខ្លួនបណ្ដោះអាសន្ន?

-តើមូលហេតុ និងលក្ខខណ្ឌអ្វីខ្លះ ដែលនាំឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ឬមិនឃុំខ្លួនជាបណ្ដោះ-អាសន្ន?

-តើនីតិវិធីក្នុងការចេញសេចក្ដីសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវឆ្លងកាត់នូវនីតិវិធីអ្វីខ្លះ?

-តើអ្នកជាប់ឃុំត្រូវបានច្បាប់ធានានូវសិទ្ធិ ឬទេ នៅក្នុងអំឡុងពេលឃុំខ្លួនជាបណ្ដោះអាសន្ន?

-តើបុគ្គលណាខ្លះ ដែលមានសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំ ឬមិនឃុំខ្លួនជាបណ្ដោះអាសន្ន?

-តើគេអាចធ្វើបណ្ដឹងសាទុក្ខចំពោះដីការបស់សភាស៊ើបសួរពាក់ព័ន្ធនឹងការឃុំ ឬមិនឃុំខ្លួនបានដែរឬទេ?

## ៣. គោលបំណង នៃការសិក្សាស្រាវជ្រាវ

ការសរសេរតាក់តែងនូវសារណានេះ គឺក្នុងគោលបំណងធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់ និងស៊ីជម្រៅអំពីគោលការណ៍ទូទៅ នៃការឃុំខ្លួនបណ្ដោះអាសន្នដែលអ្នកវិជ្ជាជីវៈក្នុងការអនុវត្តទៅលើវិធានការក្នុងការឃុំខ្លួនបណ្ដោះអាសន្នមានដូចជាៈ ចៅក្រម និងព្រះរាជអាជ្ញា អនុវត្តទៅលើជនត្រូវចោទ ដោយគិតពិចារណា និងវែកញែកនូវខ្លឹមសារ នៃក្បួនមាត្រាឱ្យបានច្បាស់ជាមុនសិន មុននឹងឈានទៅដល់ការសម្រេចអំពីការឃុំ ឬមិនឃុំខ្លួនជាបណ្ដោះអាសន្ន ដោយហេតុថាការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការមិនឃុំខ្លួនជាបណ្ដោះអាសន្ន និងការដោះលែងជនត្រូវចោទ ដែលវៀចាកពីច្បាប់នីតិវិធីនឹងបង្កជាបញ្ហាប្រឈមមួយដ៏ធំសម្រាប់ជនរងគ្រោះ ជនត្រូវចោទ និងសណ្ដាប់ធ្នាប់សង្គមទាំងមូល។ ហេតុដូចនេះហើយ បានជាក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីការមូកភាពគ្នារវាងចៅក្រមស៊ើប-សួរ និងព្រះរាជអាជ្ញាមុននឹងចេញដីកាសម្រេចអំពីការឃុំ ឬឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីត្រួតពិនិត្យនូវនីតិវិធីរវាងគ្នាទៅវិញទៅមក មុននឹងចេញដីកាសម្រេច។ ជាពិសេស ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រ កម្ពុជាក៏បានទុកសិទ្ធិឱ្យ អគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញា និងជនត្រូវចោទ ដែលមិនសុខចិត្តនឹងដីកាសម្រេច និងមានឆន្ទៈក្នុងការប្ដឹងប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ (ដីកាសម្រេច) ទៅកាន់តុលាការជាន់ខ្ពស់ដែលជាសភាស៊ើបសួររបស់សាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះទៅលើដីកា

សម្រេច ក្នុងការចេញអំណាចសាលដីកាចំពោះ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន របស់ចៅក្រមស៊ើបសួរក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់ការិយាល័យក្រឡាបញ្ជីរបស់សភាស៊ើបសួរ។

## ៤. ទំហំ និងដែនកំណត់ នៃកិច្ចការស្រាវជ្រាវ

សារណាដែលមានប្រធានបទ ស្តីពី "**ការឃុំខ្លួនបណ្តោះអាសន្ន**" នេះ ត្រូវបានសរសេរគាក់តែងក្នុងការកម្រិតនូវទំហំ និងដែនកំណត់មួយដែលនឹងសិក្សាស្រាវជ្រាវអំពីគោលការណ៍ នៃការឃុំខ្លួនបណ្តោះ-អាសន្ន សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក្នុងការចេញនូវសេចក្តីសម្រេចរួមគ្នាមួយ។ ការជ្រើសរើសនូវប្រធានបទ ស្តីពី "**ការឃុំខ្លួនបណ្តោះអាសន្ន**" ដោយមិនដាក់នូវចំណងជើង នៃប្រធានបទដូចជា "**ឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**" គឺហាក់បីដូចជាបាត់បង់នូវសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការឃុំ ឬមិនឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។ ដូច្នេះហើយបានជាយើងខ្ញុំ សម្រេចចិត្តដាក់នូវប្រធានបទដែលមានចំណងជើង ស្តីពី "**ការឃុំខ្លួនបណ្តោះអាសន្ន**"ដែលត្រូវយកមកកំណត់បែងចែកនូវសិទ្ធិអំណាចរបស់អ្នកវិជ្ជាជីវៈដែលមានដូចជាចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា។

## ៥. សារៈប្រយោជន៍ នៃការសិក្សាស្រាវជ្រាវ

សារណានេះមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់អ្នកវិជ្ជាជីវៈច្បាប់ អ្នកច្បាប់ និងប្រជាជនទូទៅដែលត្រូវសិក្សាស្វែងយល់អំពីប្រធានបទនេះ។ ចំពោះអ្នកវិជ្ជាជីវៈច្បាប់ ដែលមានដូចជា៖ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ក្រឡាបញ្ជី នគរបាលយុត្តិធម៌ និងមេធាវី គឺសុទ្ធតែជាអ្នកដែលប្រកាន់នូវវិជ្ជាជីវៈច្បាប់ ហើយគោលបំណងដ៏ធំរួមមួយរបស់អ្នកវិជ្ជាជីវៈច្បាប់ទាំងអស់នោះ គឺស្រឡាញ់យុត្តិធម៌ និងមានបំណងស្វែងរកយុត្តិធម៌ជូនកោសិការបស់ប្រទេសជាតិ ដែលនោះគឺជាប្រជារាស្ត្រខ្មែរ។ ដូច្នេះហើយបានជាយុត្តិធម៌ត្រូវផ្តល់ជូនគ្រប់បុគ្គលទាំងអស់មិនថាជាជនរងគ្រោះ ឬជនត្រូវចោទ ដែលតម្រូវឱ្យអ្នកវិជ្ជាជីវៈច្បាប់ទាំងអស់ប្រើប្រាស់នូវមនសិកាក្នុងការអនុវត្តនូវវិធានការ នៃការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។

**ឧទាហរណ៍៖** ជនត្រូវចោទបានប្រព្រឹត្តអំពើលួចដែលត្រូវបានព្រះរាជអាជ្ញាធ្វើការស្នើសុំតាមរយៈសេចក្តីសន្និដ្ឋានឱ្យចៅក្រមស៊ើបសួរមិនឃុំខ្លួនជនត្រូវចោទ ដោយហេតុថាជនត្រូវចោទបានប្រព្រឹត្តអំពីលួចនេះ ក្នុងគោលបំណងយកទៅផ្គត់ផ្គង់គ្រួសារដែលមានជីវភាពក្រីក្រយ៉ាងខ្លាំង។ ដូច្នេះប្រសិនបើចៅក្រមស៊ើបសួរ សម្រេចមិនឃុំតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា នោះប្រៀបដូចជាផ្តល់នូវយុត្តិធម៌មួយជូនជនត្រូវចោទ ព្រោះទោះបីជាជនត្រូវចោទប្រព្រឹត្តបទល្មើសលួចក៏ពិតមែន ប៉ុន្តែព្យសនកម្មដែលកើតចេញពី

អំពើរបស់ជនត្រូវចោទ គឺមានលក្ខណៈតិចតួច មិនប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈខ្លាំង ហើយអំពើនោះជាភាពកតញ្ញូ និងពោរពេញទៅដោយក្ដីស្រឡាញ់ចំពោះគ្រួសារ។ ជនត្រូវចោទដែលប្រព្រឹត្តបទមជ្ឈិម នោះក៏ត្រូវមានគ្រួសារក្រីក្រដែលត្រូវចិញ្ចឹមមើលថែរដែរ ហើយប្រសិនបើសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន ដោយសារតែរឿងបន្តិចបន្តួចនេះ ព្យសនកម្មនឹងកើតមានកាន់តែធំឡើង។ ដូច្នេះចៅក្រមស៊ើបសួរគួរគប្បីសម្រេចមិនឃុំខ្លួនជនត្រូវចោទ ធ្វើការអប់រំកែប្រែ និងដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឱ្យការឃុំខ្លួនជាបណ្ដោះអាសន្នវិញ ដើម្បីបញ្ចៀសនូវព្យសនកម្មផ្សេងៗបន្ថែមទៀត និងដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿង និងពន្ធនាគារទើបជាការស្វែងរកនូវយុត្តិធម៌មួយដ៏សមហេតុសមផល។

## ៦. វិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ លម្អិតនូវខ្លឹមដោយដកស្រង់ចេញពីប្រភពជាច្រើន។ ប្រភពចម្បងដែលយើងធ្វើការសិក្សាស្រាវជ្រាវភាគច្រើន គឺចេញពីក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា គឺជាកម្រងនៃច្បាប់ទម្រង់ ដែលជាមូលដ្ឋានសម្រាប់យកទៅអនុវត្តនីតិវិធីជាក់ស្ដែងនៅប្រទេសកម្ពុជា។ ដូច្នេះការសរសេរឱ្យចេញជាខ្លឹមសារក្រោមប្រធានបទខាងលើ យើងខ្ញុំធ្វើការសិក្សាអំពីមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជានីមួយៗ រួចសរសេរចងក្រងឱ្យចេញជាខ្លឹមសារអត្ថបទ។ បន្ថែមពីនេះ យើងខ្ញុំក៏បានសិក្សាទៅលើប្រភព នៃច្បាប់អន្តរជាតិមួយចំនួនដែលមានដូចជា កតិកាសញ្ញា ស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានចែងអំពីសិទ្ធិរបស់អ្នកជាប់ឃុំផងដែរ ការធានាឱ្យមាននូវសិទ្ធិរបស់អ្នកជាប់ឃុំ ការដកស្រង់ចេញពីច្បាប់ពិសេសដែលរួមមានដូចជា៖ ច្បាប់ពន្ធនាគារ ដែលមានចែងអំពីការគ្រប់គ្រងពន្ធនាគាររបស់មន្ត្រីពន្ធនាគារ និងការធានាបាននូវសិទ្ធិរបស់អ្នកជាប់ឃុំនៅក្នុងអំឡុងពេលឃុំខ្លួនជាបណ្ដោះអាសន្ន។

ក្រៅពីប្រភពចម្បងខាងលើនេះ យើងខ្ញុំក៏ប្រមូលបាននូវប្រភពទិន្នន័យបន្ទាប់បន្សំទៀត ដូចជាតាមរយៈការទទួលបានការណែនាំអំពីអ្នកច្បាប់ និងអ្នកវិជ្ជាជីវៈដែលបំពេញមុខងារនៅក្នុងវិស័យយុត្តិធម៌ ការស្រាវជ្រាវតាមរយៈហ្គូហ្គល និងតាមបណ្ណាល័យច្បាប់មួយចំនួនទៀត។

## ៧. រចនាសម្ព័ន្ធ នៃការសិក្សាស្រាវជ្រាវ

សារណានេះចែកចេញជា ០៥ជំពូកគឺ **ជំពូកទី១៖** ការឃុំខ្លួនបណ្ដោះអាសន្ន **ជំពូកទី២៖** នីតិវិធី នៃការឃុំខ្លួនបណ្ដោះអាសន្ន និងមិនឃុំខ្លួនបណ្ដោះអាសន្ន **ជំពូកទី៣៖** បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ **ជំពូកទី៤៖** បណ្ដឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរ **ជំពូកទី៥៖** បញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធចំពោះដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន។ នៅក្នុង**ជំពូកទី១** យើង

បានបែងចែកចេញជា២ផ្នែក ដែលផ្នែកទី១ រៀបរាប់អំពីគោលការណ៍ទូទៅ នៃការឃុំខ្លួនបណ្ដោះអាសន្ន ដោយផ្អែកទៅលើលក្ខខណ្ឌ មូលហេតុ នៃការឃុំ ឬមិនឃុំខ្លួនបណ្ដោះអាសន្ន និងថិរវេលាក្នុងការឃុំខ្លួនបណ្ដោះអាសន្នចំពោះជនត្រូវចោទ និងផ្នែកទី២ រៀបរាប់អំពីសិទ្ធិរបស់អ្នកជាប់ឃុំបណ្ដោះអាសន្ន។ ដោយឡែកក្នុង **ជំពូកទី២** បកស្រាយពាក់ព័ន្ធនឹងនីតិវិធីឃុំខ្លួនបណ្ដោះអាសន្ន និងមិនឃុំខ្លួនបណ្ដោះអាសន្ន ដែលត្រូវបានបែងចែកចេញ៣ផ្នែក ដែលផ្នែកទី១ រៀបរាប់អំពីដំណើរការ នៃការឃុំខ្លួនបណ្ដោះអាសន្ន ផ្នែកទី២ រៀបរាប់អំពីដំណើរការ នៃការមិនឃុំខ្លួនបណ្ដោះអាសន្ន និងផ្នែកទី៣ រៀបរាប់អំពីការតាក់តែងដីកាឃុំ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ ចំណែកឯ **ជំពូកទី៣** បកស្រាយអំពីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលបែងចែកចេញជា ០២ផ្នែក ដោយផ្នែកទី១ រៀបរាប់អំពីនីតិវិធីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងផ្នែកទី២ រៀបរាប់អំពីនីតិវិធីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ ចំពោះ **ជំពូកទី៤៖** បកស្រាយអំពីបណ្ដឹងសាទុក្ខ ដែលប្ដឹងប្រឆាំងនឹងសាលដីកា ដែលសភាស៊ើបសួរបានសម្រេចចំពោះ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ និងនីតិវិធីក្នុងការធ្វើបណ្ដឹងសាទុក្ខ ចំណែកឯ **ជំពូកទី៥៖** បកស្រាយអំពីបញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# ការឃុំខ្លួនបណ្ដោះអាសន្ន

# ជំពូកទី១
# ការឃុំខ្លួនបណ្តោះអាសន្ន

## ផ្នែកទី១៖ គោលការណ៍ទូទៅ នៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជានីតិវិធីមួយ ដែលធ្វើឡើងនៅក្នុងដំណាក់កាល នៃចៅក្រមស៊ើបសួរ ពោលគឺមុនពេលជំនុំជម្រះក្តី ហើយការសម្រេចឱ្យមានការឃុំខ្លួនបណ្តោះអាសន្ននេះ ធ្វើឡើងតាមរយៈគំនិតផ្តួចផ្តើមពីចៅក្រមស៊ើបសួរផ្ទាល់ ឬតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា យោងតាមការពិចារណាទៅលើស្ថានភាព នៃជនត្រូវចោទ ឬលក្ខណៈ នៃបទល្មើស[1]នោះ។ ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើទៅបានចំពោះតែបទមជ្ឈិម និងបទឧក្រិដ្ឋដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារ[2]ស្មើ ឬលើសពីមួយឆ្នាំតែប៉ុណ្ណោះ។

ការឃុំខ្លួនបណ្តោះអាសន្ន ធ្វើឡើងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ធានាដំណើរការនីតិវិធី នៃការស៊ើបសួរប្រព្រឹត្តទៅដោយរលូន ការពារផលប៉ះពាល់ជាយថាហេតុណាមួយ ដែលបង្កឡើងដោយជនត្រូវចោទ និងដើម្បីធានាសុវត្ថិភាពរបស់ជនត្រូវចោទ។ ប៉ុន្តែវិធានការនេះ បានធ្វើឱ្យប៉ះពាល់ទៅដល់សេរីភាពរបស់ជនត្រូវចោទ ព្រោះជាគោលការណ៍ ជនត្រូវចោទ ត្រូវតែមានសេរីភាព តែមិនមែនមានន័យថា មិនអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទបាននោះទេ ហើយមិនមែនគ្រប់ពេលដែលមានបទល្មើសកើតឡើង ការសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវតែជាជម្រើសតែមួយគត់នោះដែរ ពោលគឺគេត្រូវសិក្សាទៅលើស្ថានភាព នៃបទល្មើស ក៏ដូចជាស្ថានភាពជនដែលបានប្រព្រឹត្តបទល្មើសជាមុនសិន មុននឹងឈានដល់ការសម្រេចរបស់ចៅក្រមស៊ើបសួរ[3]។ ដូចនេះ តើត្រូវមានលក្ខខណ្ឌពិសេសអ្វីខ្លះ ទើបអាចឃុំខ្លួនជនដែលប្រព្រឹត្តបទល្មើសជាបណ្តោះអាសន្នបាន?

---

[1] បទល្មើស គឺជាអំពើប្រឆាំងនឹងរដ្ឋ ជាអំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម ជាអំពើប្រឆាំងនឹងច្បាប់ជាធរមាន ដែលមានចែងក្នុងច្បាប់ ព្រហ្មទណ្ឌនឹងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ (យោងតាមវចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រ ២៧៥)។

[2] ពន្ធនាគារ សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំ តាមលិខិតឃុំខ្លួន ចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង។ (យោងតាមច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ មាត្រា ៤ )។

[3] ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលទទួលបន្ទុកស៊ើបសួររឿងព្រហ្មទណ្ឌ តាមសេចក្តីសន្និដ្ឋានចោទប្រកាន់ពីព្រះរាជអាជ្ញា។ (យោងតាមសន្ទានុក្រមបារាំង ខ្មែរ នៃពាក្យច្បាប់ ឆ្នាំ២០០៥ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទំព័រទី១៦៤)។

## កថាខណ្ឌទី១៖ លក្ខខណ្ឌ នៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនជាបណ្ដោះអាសន្នតម្រូវឱ្យមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីចៅក្រមស៊ើបសួរ ដោយត្រូវពិនិត្យអំពីលក្ខខណ្ឌមួយចំនួន ក្នុងការចេញដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន។ ដូច្នេះ យើងគួរគប្បីស្វែងយល់អំពីលក្ខខណ្ឌចំនួនពីរដូចខាងក្រោម៖ លក្ខខណ្ឌ នៃការកំណត់បទល្មើសចំពោះការចោទប្រកាន់ (១.១) និងលក្ខខណ្ឌ នៃការកំណត់ទោសចំពោះការដាក់ពន្ធនាគារ (១.២)។

### ១.១. លក្ខខណ្ឌ នៃការកំណត់បទល្មើសចំពោះការចោទប្រកាន់

ផ្អែកតាមស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៤ ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណី នៃការកម្រិតចំពោះបទល្មើសមួយចំនួនតែប៉ុណ្ណោះ គឺបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់ចែងផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី០១(មួយ)ឆ្នាំ។ ចំពោះបទលហុមិនតម្រូវឱ្យមានការឃុំខ្លួនជាបណ្ដោះអាសន្ននោះឡើយ។ ហេតុដូច្នេះហើយ បានជាយើងត្រូវសិក្សាអំពីលក្ខខណ្ឌក្នុងការចោទប្រកាន់ចំនួន០២ (ពីរ)គឺ៖ លក្ខខណ្ឌក្នុងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ (១.១.១) និងលក្ខខណ្ឌក្នុងការចោទប្រកាន់ចំពោះបទមជ្ឈិម (១.១.២)។

#### ១.១.១. លក្ខខណ្ឌក្នុងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ

នៅពេលដែលមានបទល្មើសណាមួយកើតឡើង មន្ត្រីនគរបាលយុត្តិធម៌[4]មានសិទ្ធិ និងកាតព្វកិច្ចក្នុងការទទួល និងធ្វើពាក្យបណ្ដឹង(បណ្ដឹងទាមទារ[5] ឬ/និងបណ្ដឹងបរិហារ[6]) ប្រមូលយកវត្ថុតាង ត្រួតពិនិត្យបទល្មើស ដែលបានកើតឡើង និងបើកការស៊ើបសង្កេតជុំវិញអង្គហេតុដែលបានកើតឡើងនោះ ក្នុងគោលដៅកំណត់អត្តសញ្ញាណជនល្មើស ធ្វើការឃាត់ខ្លួន និងរៀបចំកំណត់ហេតុទៅកាន់អង្គការអយ្យការ នៃ

[4] មន្ត្រីនគរបាលយុត្តិធម៌ គឺជាមុខងារមួយរបស់នគរបាលយុត្តិធម៌ មានតួនាទីជាជំនួយរបស់អំណាចតុលាការ ពោលគឺមានន័យថាជាជំនួយរបស់អំណាចព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ នគរបាលយុត្តិធម៌រួមមាន៖ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ (យោងតាមមាត្រា ៥៦ មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)

[5] បណ្ដឹងទាមទារ គឺជាបណ្ដឹងដែលធ្វើឡើងដោយជនរងគ្រោះប្ដឹងទៅសមត្ថកិច្ច (មន្ត្រីនគរបាលយុត្តិធម៌) ឱ្យជួយដោះស្រាយនូវសំណង នៃការខូចខាត សំណងជម្ងឺចិត្ត និងផ្ដន្ទាទោសតាមផ្លូវច្បាប់។ (យោងតាមសៀវភៅដំណើរការរឿងក្ដីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន របស់វរសេនីយ៍ឯក អាន សូរីដា ទំព័រ ១៤)។

[6] បណ្ដឹងបរិហារ គឺជាបណ្ដឹងដែលធ្វើឡើងដោយតតិយជន មន្ត្រីសាធារណៈ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ប្ដឹងទៅសមត្ថកិច្ចដើម្បីស្វែងរកភស្តុតាង និងឈានទៅដល់ការដេកមុខចាប់ជនល្មើសមកផ្ដន្ទាទោស។ (យោងតាមសៀវភៅដំណើរការរឿងក្ដីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន របស់វរសេនីយ៍ឯក អាន សូរីដា ទំព័រ ១៤)។

សាលាដំបូងរាជធានី-ខេត្ត។ នគរបាលយុត្តិធម៌ មានភារៈកិច្ចជាចម្បងនៅក្នុងការត្រួតពិនិត្យពីប្រភេទ នៃបទល្មើសថាតើជាបទលហុ បទមជ្ឈិម ឬក៏ជាបទឧក្រិដ្ឋ? ផ្អែកតាមស្មារតី នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា អាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែអំពីដែលបានប្រព្រឹត្តនោះ គឺមានចែងនៅក្នុងច្បាប់។[7] ប៉ុន្តែអ្វីដែលជាចំណុចសំខាន់នោះគឺ ក្នុងចំណោមបទល្មើសដែលច្បាប់បានចែងទាំងអស់ តើអាចកំណត់បានដោយរបៀបណាថា មួយណាជាបទឧក្រិដ្ឋ?

បទឧក្រិដ្ឋ គឺជាប្រភេទបទល្មើស ដែលអតិបរមា នៃទោសដាក់ពន្ធនាគារ មានរយៈពេលអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ០៥(ប្រាំ)ឆ្នាំ និងក្រោម ឬស្មើនឹង ៣០(សាមសិប)ឆ្នាំ។[8] ឧទាហរណ៍ដូចជា៖

- បទទារុណកម្ម និងអំពើឃោរឃៅ ដែលច្បាប់បានចែងដាក់ពន្ធនាគារពី ០៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ (មាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)
- បទឃាតកម្មគិតទុកជាមុន ដែលច្បាប់បានចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)
- បទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលច្បាប់បានចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (មាត្រា ១៨៣ និងមាត្រា១៨៤ នៃក្រមព្រះរាជាណាចក្រកម្ពុជា)
- បទល្មើសទាំងអស់នេះ គឺជាឧទាហរណ៍មួយផ្នែកតូចមួយ នៃបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានបិទបញ្ចប់ការស៊ើបអង្កេត និងរៀបចំកំណត់ហេតុរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនខ្លួនជនល្មើស[9] វត្ថុតាង និងកំណត់ហេតុ ទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់ និងផ្តន្ទាទោសទៅតាមផ្លូវច្បាប់។ ក្រោយពីព្រះរាជអាជ្ញា បានទទួលនូវពាក្យបណ្តឹង កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាវត្ថុតាងផ្សេងៗ តាមការបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌រួចមកព្រះរាជអាជ្ញាមានរយៈពេល ០២(ពីរ)ខែ ដើម្បីថ្លឹងថ្លែងអំពីចំណាត់ការ លើពាក្យបណ្តឹង ពិនិត្យ និងសិក្សាទៅ

[7] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣។

[8] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៦។

[9] ជនល្មើស គឺជាអ្នកប្រព្រឹត្តិអំពើខុសច្បាប់។

លើអង្គហេតុនោះ ក្នុងគោលដៅស្វែងរកពិរុទ្ធភាព[10] នៃជនល្មើស និងធ្វើការចោទប្រកាន់ តាមរយៈបណ្តឹងអាជ្ញា[11]។

ដោយឡែកប្រសិនបើ ព្រះរាជអាជ្ញាពិនិត្យមើលទៅឃើញថាពុំមានធាតុផ្សំនៃបទល្មើស[12]គ្រប់គ្រាន់អាចត្រូវផ្តន្ទាទោសជនល្មើស ឬដោយសារមូលហេតុផ្សេងៗទៀត នោះព្រះរាជអាជ្ញាមានសិទ្ធិតម្កល់រឿងទុកឥតចាត់ការ។ ដោយហេតុថាប្រទេសកម្ពុជា ព្រះរាជអាជ្ញាអនុវត្តតាមគោលការណ៍កាលានុវត្តភាព[13] ដែលការមានសិទ្ធិអំណាចក្នុងការជ្រើសរើសធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការបាន ដោយផ្ទុយពីប្រទេសមួយចំនួនដូចជាប្រទេសអាល្លឺម៉ង់ ដោយព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ចំពោះបទល្មើសមិនថាបទល្មើសតូច ឬធំក៏ដោយ។ ដូច្នេះហើយ បានជាការសម្រេចអំពីការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាត្រូវផ្អែកលើមូលហេតុធំៗចំនួន ០៧(ប្រាំពីរ) រួមមាន៖[14]

- មរណភាព នៃជនល្មើស
- បណ្តឹងអាជ្ញាត្រូវផុតរលត់
- ការលើកលែងទោសជាទូទៅ
- និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ

[10] ពិរុទ្ធភាព គឺសំដៅលើភាពជាអ្នកមានពិរុទ្ធ មានន័យថា ភាពជាជនដែលបានប្រព្រឹត្តបទល្មើស ប៉ុន្តែអយ្យការទើបតែផ្តើមចោទប្រកាន់ ឬ/និងជាជនដែលចៅក្រមស៊ើបសួរកំពុងឃុំខ្លួនជាបណ្តោះអាសន្នដើម្បីស្រាវជ្រាវរកភស្តុតាង (យោងតាមវចនានុក្រមច្បាប់ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រទី ៣៥០ និងទំព័រទី ៣៥១)។

[11] បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលធ្វើឡើងដោយអយ្យការ មានគោលបំណងនៅក្នុងការពិនិត្យអត្ថិភាព នៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាព នៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។ បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពផ្សេងៗ។ (មាត្រា ២ មាត្រា ៣ មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

[12] ធាតុផ្សំបទល្មើស ត្រូវបានចែកចេញជា ០៣(បី)ធំៗ រួមមាន៖

-ធាតុផ្សំនីត្យានុកូល៖ ច្បាប់ដែលបានចាត់ទុកអំពើណាមួយជាបទល្មើស។

-ធាតុផ្សំសត្យានុម័ត៖ សកម្មភាព ឬអសកម្មភាពប្រព្រឹត្តដោយជនល្មើស។

-ធាតុផ្សំអត្តនោម័ត៖ កំហុសចេតនា ឬអចេតនារបស់ជនល្មើស។ (យោងតាមសៀវភៅជំនួយស្មារី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយ លោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ជំពូកទី១ ទំព័រ ៣) ។

[13] គោលការណ៍កាលានុវត្តភាព មានន័យថា អង្គហេតុ នៃរឿងជារឿងព្រហ្មទណ្ឌ ប៉ុន្តែវាជាបទល្មើសតូចតាច។ (យោងតាមសៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន របស់វរសេនីយ៍ឯក អាន សូរីដា ទំព័រ ៥៨)

[14] យោងតាមសៀវភៅ ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ វរសេនីយ៍ឯក អាន សូរីដា ផ្នែកទី២ កថាខណ្ឌទី ៣ ទំព័រ ៥៧ និងទំព័រ ៥៨)។

- អាជ្ញាអស់ជំនុំ
- អង្គហេតុ នៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ។

ប៉ុន្តែប្រសិនបើ ព្រះរាជអាជ្ញា ពិនិត្យឃើញថា មានធាតុផ្សំ នៃបទល្មើសគ្រប់គ្រាន់ ក្នុងការចោទប្រកាន់ និងពុំមានមូលហេតុផ្សេងទៀត ដែលនាំឱ្យលត់បណ្តឹងអាជ្ញាទេ នោះអយ្យការនឹងធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងស្នើសុំឱ្យមានការអនុវត្តច្បាប់ នៅចំពោះមុខយុត្តាធិការស៊ើបសួរ[15] និងយុត្តាធិការជំនុំជម្រះ[16]។[17]

ការចោទប្រកាន់ខាងព្រហ្មទណ្ឌអាចធ្វើតាមរយៈ ការបើកធ្វើការស៊ើបសួរ (ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (ការបញ្ជាឱ្យជនត្រូវចោទចូលទៅបង្ហាញខ្លួននៅសាលាដំបូង) និងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (ព្រះរាជអាជ្ញាបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមនៅសាលាដំបូង កាលបើជាបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង បទល្មើសត្រូវផ្តន្ទាទោសពី១ឆ្នាំយ៉ាងតិច ហើយ ០៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ជនត្រូវចោទជានីតិជន រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន)។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញា ត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។[18] ដូច្នេះប្រសិនបើជនត្រូវចោទបានប្រព្រឹត្តនូវបទឧក្រិដ្ឋណាមួយ នោះចៅក្រមស៊ើបសួរត្រូវពិចារណាអំពីការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនជាបណ្តោះអាសន្ន។

### ១.១.២. លក្ខខណ្ឌក្នុងការចោទប្រកាន់ចំពោះបទមជ្ឈិម

ចំពោះលក្ខខណ្ឌនៅក្នុងការចោទប្រកាន់ចំពោះបទមជ្ឈិម ក៏ពុំសូវមានភាពខុសគ្នាប៉ុន្មានដែរពីការចោទប្រកាន់នៅក្នុងបទឧក្រិដ្ឋ ដោយដំណើរនីតិវិធី គឺមានភាពដូចគ្នា គ្រាន់តែអតិបរមា នៃទោស និងថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅក្នុងកម្រិតមួយផ្សេងគ្នា និងទាបជាងបទឧក្រិដ្ឋ។ ដូចនេះតើគេអាចកំណត់បទមជ្ឈិមតាមវិធីណា?

[15] យុត្តាធិការស៊ើបសួរ គឺជាស្ថាប័នស៊ើបអង្កេត រួមមានចៅក្រមស៊ើបសួរ (យោងតាមវចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រទី ៣៩៥)។

[16] យុត្តាធិការជំនុំជម្រះ គឺជាស្ថាប័នទទួលបន្ទុកខាងជំនុំជម្រះក្តី។ តុលាការរួមមានចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ។ (យោងតាមវចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រទី ៣៩៤)។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៣ និងមាត្រា ៤៤។

បទមជ្ឈិម គឺជាប្រភេទបទល្មើសដែល អតិបរមា នៃទោសដាក់ពន្ធនាគារ មានរយៈពេលលើសពី ០៦ (ប្រាំមួយ)ថ្ងៃ និងក្រោម ឬស្មើនឹង ០៥(ប្រាំ)ឆ្នាំ។[19]

**ឧទាហរណ៍៖**

- បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត ដែលផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ទៅ ០៦ (ប្រាំមួយ)ខែ (មាត្រា៤២៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)។
- បទលួច ដែលផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦(ប្រាំមួយ)ខែ ទៅ ០៣(បី)ឆ្នាំ (មាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)។
- បទរំលោភអំណាចមេបាន ដែលផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ទៅ ០១(មួយ)ឆ្នាំ (មាត្រា ៣៤៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា)។

បទល្មើសដូចមានរៀបរាប់ខាងលើនេះ គ្រាន់តែបទមជ្ឈិមមួយចំនួន ក្នុងចំណោមបទមជ្ឈិមផ្សេងទៀត ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។ ដូច្នេះប្រសិនបើជនត្រូវចោទបានប្រព្រឹត្តនូវបទមជ្ឈិមណាមួយ នោះចៅក្រមស៊ើបសួរត្រូវពិចារណាអំពីការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ។

### ១.២. លក្ខខណ្ឌ នៃការកំណត់ទោសចំពោះការដាក់ពន្ធនាគារ

គ្រប់ប្រទេសនៅលើពិភពលោកយើងនេះ ពុំមានឡើយប្រទេសដែលគ្មានពន្ធនាគារ ពោលគឺឱ្យតែមានអ្នកប្រព្រឹត្តបទល្មើស តែងតែមានពន្ធនាគារសម្រាប់ឃុំឃាំង អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅសង្គមវិញ និងដើម្បីទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារជាថ្មី។[20] បើទោះបីជាច្បាប់កំណត់ថាការសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវអនុលោមទៅតាមលក្ខខណ្ឌ នៃបទល្មើសឧក្រិដ្ឋ និងបទមជ្ឈិមក៏ដោយ ក៏ប៉ុន្តែមិនមែនគ្រប់បទមជ្ឈិមសុទ្ធ តែត្រូវឃុំខ្លួនជាបណ្តោះអាសន្នឡើយ។ ការកំណត់ទោសសម្រាប់អាចឱ្យចៅក្រមស៊ើបសួរឃុំខ្លួនជាបណ្តោះអាសន្នបានគឺចាប់ពី ០១(មួយ)ឆ្នាំឡើងទៅ។ ដូច្នេះប្រសិនបើបទល្មើសមជ្ឈិមខ្លះ ដែលច្បាប់ព្រហ្មទណ្ឌកំណត់អំពីទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ០១(មួយ)ឆ្នាំ នោះចៅក្រមស៊ើបសួរមិនអាចពិចារណា អំពីការសម្រេចឃុំខ្លួនជាបណ្តោះអាសន្នបានឡើយ។

[19] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧។

[20] មាត្រា ២ និងមាត្រា ៤ នៃច្បាប់ ស្តីពី ពន្ធនាគារ ឆ្នាំ២០១១។

**ឧទាហរណ៍៖** ឈ្មោះ ក បានធ្វើការញុះញង់ឱ្យឈ្មោះ ខ បោះបង់ទារកដែលទើបនឹងកើតដែលឈ្មោះ គ ដោយដោះដូរយកកម្រៃ។ អំពើរបស់ឈ្មោះ ក គឺស្ថិតនៅក្នុងការប្រព្រឹត្តបទញុះញង់ឱ្យបោះបង់ទារក ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ដល់ ០៦(ប្រាំមួយ)ខែ ដូចមានចែងនៅក្នុងមាត្រា៣៣០ នៃក្រមព្រហ្មទណ្ឌ។[21] បើយើងពិនិត្យចំពោះបទល្មើសខាងលើ យើងសង្កេតឃើញថា អំពើរបស់ឈ្មោះ ក ត្រូវបានចាត់ចូលក្នុងបទមជ្ឈិម ប៉ុន្តែក្នុងករណីនេះ ចៅក្រមស៊ើបសួរ ពុំអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្នលើ លោក ក បានឡើយ បើទោះបី វាជាបទមជ្ឈិមក៏ដោយ ព្រោះផ្អែកតាមគោលការណ៍ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនណាម្នាក់ជាបណ្តោះអាសន្នបាន លុះត្រាតែជននោះបានប្រព្រឹត្តិបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ០១(មួយ)ឆ្នាំឡើងទៅ។ ដោយឡែកអំពើដែលលោក ក បានប្រព្រឹត្ត គឺច្បាប់កំណត់ទោសដាក់ពន្ធនាគារត្រឹមតែ ០១(មួយ)ខែ ដល់ ០៦(ប្រាំមួយ)ខែ តែប៉ុណ្ណោះ ជាហេតុនាំឱ្យការឃុំខ្លួនជាបណ្តោះអាសន្នមិនអាចធ្វើទៅរួច ហើយរឿងក្តីនេះត្រូវតែបញ្ជូនទៅជំនុំជម្រះភ្លាម។

## កថាខណ្ឌទី២៖ មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន និងមូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្ន

ការសម្រេចឃុំខ្លួនបណ្តោះអាសន្នមិនមែនជាជម្រើសតែមួយគត់ដែលចៅក្រមស៊ើបសួរត្រូវតែសម្រេចនោះទេ។ ក្នុងកាលៈទេសៈខ្លះ ចៅក្រមស៊ើបសួរ ត្រូវតែសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ចំណែកឯក្នុងកាលៈទេសៈខ្លះទៀត ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្នបាន ព្រោះស្មារតី នៃហេតុដែលនាំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ននេះ គឺសម្រាប់ការពារ និងបង្ការកុំមានមានមហន្តរាយនានា កើតមានឡើងដោយថាហេតុដោយសារតែជនត្រូវចោទស្ថិតនៅក្រៅឃុំ និង/ឬនាំឱ្យមានការកកស្ទះដល់ដំណើរការ នៃការស៊ើបសួរ និងការកកស្ទះសំណុំរឿងនៅដំណាក់កាលចៅក្រមស៊ើបសួរ និងពន្ធនាគារផងដែរ។ ដូចនេះ តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន និងការមិនឃុំខ្លួនបណ្តោះអាសន្ន?

### ២.១. មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន

នៅពេលដែលលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើត្រូវបានបំពេញ ចៅក្រមស៊ើបសួរត្រូវពិនិត្យអំពីមូលហេតុ នៃការឃុំខ្លួនជាបណ្តោះអាសន្ន។ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព[22]។ ក្នុង

[21] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២ ឆ្នាំ២០០៩, មាត្រា ៣៣០។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៣ ។

ករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នដោយផ្អែកលើមូលហេតុចំនួន ០៦(ប្រាំមួយ) ដូចខាងក្រោមនេះ៖

**ក. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី**

ប្រសិនបើជនត្រូវចោទ គឺជាអ្នកប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋធ្ងន់ធ្ងរ ការសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន គឺជាជម្រើសដ៏ល្អមួយនៅក្នុងការបញ្ចប់បទល្មើស និងបង្ការបទល្មើសកុំឱ្យកើតជាថ្មី។

**ឧទាហរណ៍៖** លោក ក គឺជាឃាតកររំលោភសម្លាប់លើអនីតិជនម្នាក់យ៉ាងសាហាវ។ ទង្វើរបស់លោក ក ត្រូវបានចាត់ចូលក្នុងបទឃាតកម្មដោយរំលោភសេពសន្ថវៈ ដែលត្រូវផ្ដន្ទាទោសអស់មួយជីវិត ដូចមានចែងនៅក្នុង មាត្រា២០៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ អ្នកប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ និងសាហាវឃោឃៅដូចនេះ គួរត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន ព្រោះបើទុករូបលោក នៅខាងក្រៅ រូបលោកអាចនឹងលបគេចខ្លួន ឬ/និងទៅប្រព្រឹត្តិបទល្មើសជាបន្តបន្ទាប់ទៀត ឬអាចបង្ករឿងកាន់តែធ្ងន់ធ្ងរជាងនេះ ឬ/និងទៅបំផ្លាញភស្តុតាង ឬវត្ថុតាងផ្សេងៗ ជាហេតុនាំឱ្យពិបាកនៅក្នុងដំណើរការនីតិវិធីស៊ើបសួរ។

**ខ. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត**

ចៅក្រមស៊ើបសួរ អាចចេញនូវដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នទៅលើជនត្រូវចោទបាន កាលបើសង្ស័យថា ជនត្រូវចោទអាចនឹងទៅគំរាមកំហែង ឬគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ជាហេតុនាំឱ្យមានការប្រែប្រួលចម្លើយរបស់សាក្សី ឬ/និងជនរងគ្រោះ ដែលជាលទ្ធផលនឹងធ្វើឱ្យកិច្ចនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរមិនមានភាពរលូន។ ម្យ៉ាងវិញទៀត ការឃុំខ្លួននៅក្នុងកាលៈទេសៈខ្លះ គឺធ្វើឡើងក្នុងគោលបំណងបញ្ចៀសនូវការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

**ឧទាហរណ៍៖** លោក ក គឺជាអ្នកជួញដូរ និងចែកចាយគ្រឿងញៀន ចំណែកឯ លោក ខ ជាអ្នកចាំផ្លូវឱ្យ លោក ក នៅពេលចែកចាយបន្ត។ ស្រាប់តែនៅថ្ងៃមួយ លោក ក ត្រូវបានឃាត់ខ្លួន តែលោក ខ ពុំបានដឹងពីរឿងនេះឡើយ។ ដូចនេះប្រសិនបើពុំមានការឃុំខ្លួន លោក ក ជាបណ្ដោះអាសន្នទេ នោះ លោក ខ អាចនឹងទទួលបានដំណឹងហើយលបគេចខ្លួនបាត់ ឬរៀបចំគម្រោងការជាមួយ លោក ក ក្នុងការបំផ្លាញភស្តុតាងផ្សេងៗ ។ល។ ជាហេតុនាំឱ្យខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។

**គ. ដើម្បីរក្សាវត្ថុតាង ឬតម្រុយជាសម្ភារៈ**

អ្នកដែលប្រព្រឹត្តិបទល្មើសភាគច្រើន តែងតែមានភាពរអៀសខ្លួន និងភ័យខ្លាចចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តិ។ ហើយអ្វីដែលជាអំណះអំណាងនៅតុលាការក្នុងការបង្ហាញពីពិរុទ្ធភាព នៃជនល្មើស គឺជា

ភស្តុតាង[23]នេះហើយ ព្រោះតុលាការធ្វើការវិនិច្ឆ័យសេចក្តីដោយផ្អែកទៅលើភស្តុតាង។ ដូចនេះចំពោះកាលៈទេសៈខ្លះ ប្រសិនបើមិនសម្រេចឃុំខ្លួនជនត្រូវចោទទេនោះ វត្ថុតាង ឬតម្រុយជាសម្ភារៈមួយចំនួន អាចនឹងត្រូវបំផ្លាញជាយថាហេតុដោយជនត្រូវចោទ។ ជាលទ្ធផល នៃនីតិវិធីនឹងពុំអាចស្វែងរកយុត្តិធម៌បាន ដោយហេតុថាភស្តុតាងត្រូវបានបំផ្លាញដោយជនត្រូវចោទ[24]បាត់ទៅហើយ។

### ឃ. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ កាលបើសង្ស័យថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន។ កត្តាមួយចំនួនដែលអាចបង្ហាញថា ជនត្រូវចោទអាចនឹងគេចខ្លួនរួមមាន៖

- ការប្រើវិធានការដើម្បីលាក់បាំងអតីតកាលរបស់ខ្លួន
- ការប្រើឈ្មោះមិនពិត
- ការប្តូរការងារ ឬទីតាំងច្រើនដង
- ការផ្តល់ព័ត៌មានមិនពិត
- ការបាត់ខ្លួនពីមុន
- ការរស់នៅក្នុងតំបន់ដោយមានអ្នកគាំទ្រច្រើន
- ការមានទំនាក់ទំនងជិតស្និទ្ធជាមួយជនមានឥទ្ធិពល
- ការធ្វើដំណើរទៅក្រៅប្រទេសញឹកញាប់
- មធ្យោបាយផ្នែកហិរញ្ញវត្ថុ[25]

កត្តាទាំងអស់នេះ អាចជាមូលដ្ឋានមួយនៅក្នុងការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរ ព្រោះដើម្បីធានាថា ជនត្រូវចោទពុំអាចគេចខ្លួន និងមានវត្តមាននៅពេលជំនុំជម្រះក្តី។

---

[23] ភស្តុតាង គឺជាតឹកតាងជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងចំណុចវិវាទគូភាគីដែលជាមូលដ្ឋាន នៃការសម្រេចសេចក្តីរបស់តុលាការ។ (យោងតាមវចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រទី ៣៦២)។

[24] ជនត្រូវចោទ គឺជាឈ្មោះសម្រាប់ហៅសម្គាល់ជនល្មើសនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ។ (យោងតាមវចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស របស់លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង ទំព័រទី ១២៨)។

[25] អត្ថបទខ្លី ស្តីពីការវិភាគផ្លូវច្បាប់ជុំវិញការឃុំខ្លួនបណ្តោះអាសន្ន របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១៦ ត្រង់ចំណុចទី១ https://cchrcambodia.org/admin/media/analysis/analysis/khmer/2016_11_21_JLA_of_Pre-trial_Detention_of_the_5_KHM.pdf

### ង. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ

ការអនុវត្តនូវនីតិវិធីឱ្យមានប្រសិទ្ធិភាព និងយុត្តិធម៌ គឺមិនមែនតែសម្រាប់ជនរងគ្រោះ នៃរឿងក្តីតែមួយនោះឡើយ។ យុត្តិធម៌ត្រូវមានបានចំពោះ ជនគ្រប់រូបដែលពាក់ព័ន្ធនៅក្នុងរឿងក្តីដូចជា ជនរងគ្រោះ ជនត្រូវចោទ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត។ ជួនកាលជនត្រូវចោទបានប្រព្រឹត្តិនូវបទល្មើសដូចជាសម្លាប់ជនរងគ្រោះ ជាហេតុធ្វើឱ្យកើតមានការគុំគួន និងខឹងសម្បារពីសំណាក់សាច់ញាតិរបស់ជនរងគ្រោះ ជាលទ្ធភាពនាំឱ្យមានការប្រើប្រាស់អំពើហិង្សា ឬសម្លាប់ជនត្រូវចោទជាការសងសឹកវិញក៏ថាបាន ប្រសិនបើទុកឱ្យជនត្រូវចោទនៅក្រៅឃុំ ជួនកាលគាត់អាចនឹងរងគ្រោះ ឬត្រូវរងគ្រោះវិញក៏ថាបាន។

ក្នុងករណីខ្លះ ជនត្រូវចោទ ជាអ្នកស៊ីឈ្នួលធ្វើជាឃាតករសម្លាប់មនុស្ស អាចត្រូវបានបុគ្គលណាម្នាក់ជួលក្នុងតម្លៃណាមួយ ដើម្បីឱ្យទៅសម្លាប់ជនរងគ្រោះ។ ក្រោយសម្លាប់រួច បែរជាត្រូវចាប់ខ្លួនបាន ក្នុងករណីនេះ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នទេនោះ អាយុជីវិតរបស់ជនត្រូវចោទអាចនឹងត្រូវញាំញីដោយប្រការណាមួយជាក់ជាមិនខាន។

**ឧទាហរណ៍៖** បើទុកគាត់នៅខាងក្រៅ អាចនឹងត្រូវបានគេលបសម្លាប់ដើម្បីបំបិទមាត់។ល។ ដូចនេះ ការឃុំខ្លួនបណ្តោះអាសន្នពេលខ្លះវាអាចជាប្រយោជន៍ និងសុវត្ថិភាពដល់ជនត្រូវចោទផងដែរ។

### ច. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

ពេលខ្លះការឃុំខ្លួនបណ្តោះអាសន្នធ្វើឡើង ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ និងបង្ការកុំឱ្យមានភាពច្របូកច្របល់នៅក្នុងសង្គមដែលបណ្តាលមកពីបទល្មើសណាមួយដែលបង្កឡើងជនត្រូវចោទ។

## ២.២. មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្ន

ដូចយើងបានបញ្ជាក់នៅពីខាងដើមមកហើយថា លក្ខខណ្ឌក្នុងការឃុំខ្លួនបណ្តោះអាសន្នត្រូវកំណត់ទោសដាក់ពន្ធនាគារចាប់ពី ០១(មួយ)ឆ្នាំឡើងទៅ ប៉ុន្តែមិនមែនគ្រប់បទល្មើសដែលត្រូវផ្តន្ទាទោសចាប់ពី ០១(មួយ)ឆ្នាំឡើងទៅ គឺសុទ្ធតែតម្រូវឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ននោះឡើយ ក្នុងករណីពិសេសមួយចំនួន ចៅក្រមស៊ើបសួរ ក៏មិនអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបានដែរ ហើយក្នុងកាលៈទេសៈខ្លះ ប្រសិនបើរឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបានហើយនោះ គេអាចរៀបចំដំណើរការនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាមតែម្តង ដើម្បីបញ្ចៀស ការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ។ ដូចនេះតើមានមូលហេតុអ្វីខ្លះ ដែលជាហេតុនាំឱ្យមិនអាចឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ហើយតើចៅក្រមស៊ើបសួរត្រូវផ្លាស់ប្តូរវិធីសាស្ត្រយ៉ាងដូចម្តេច?

### ២.២.១. មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើអាយុ

មូលហេតុចម្បងធំបំផុតដែលចៅក្រមស៊ើបសួរ មិនអាចធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន កាលបើជនត្រូវចោទជាអនីតិជនមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ ព្រោះកុមារគ្រប់រូប ត្រូវបានគាំពារដោយច្បាប់ និងអនុសញ្ញានានា ពាក់ព័ន្ធនឹងសិទ្ធិ សេរីភាព និងការមិនបំបែកអនីតិជនចេញពីអាណាព្យាបាល។ ម្យ៉ាងវិញទៀតជាគោលការណ៍ នៃច្បាប់ កាលបើអនីតិជនបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ វិធានការអនុវត្តចំពោះអនីតិជន[26] គឺមានតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ[27]។ ហេតុដូចនេះហើយ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គឺចៅក្រមស៊ើបសួរមិនអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្នបានឡើយ ក្រៅពីសម្រេចប្រគល់អនីតិជននេះ ឱ្យទៅឪពុកម្តាយ អ្នកអាណាព្យាបាល ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន ដើម្បីរង់ចាំសេចក្តីសម្រេចរបស់តុលាការ។[28]

### ២.២.២.មូលហេតុ នៃការមិនឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើលក្ខណៈសម្បត្តិរបស់ជនត្រូវចោទ

ទោះបីជាពេលខ្លះ ការឃុំខ្លួនជាបណ្តោះអាសន្ន គឺជាភាពចាំបាច់ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងយុត្តិធម៌ និងការពារជនរងគ្រោះ និងសាក្សីយ៉ាងណាក្តី ក៏ការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចក្លាយជាជម្រើសតែមួយគត់នោះដែរ ព្រោះការអនុវត្តការឃុំខ្លួនជាបណ្តោះអាសន្នហួសប្រមាណ ឬមិនត្រឹមត្រូវអាចធ្វើឱ្យមានការរឹតត្បិតលើសិទ្ធិសេរីភាព និងការសន្មត់ទុកជាមុនថាគ្មានទោស។ ដោយឡែកសន្និសិទ ស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្នលេខ៖ ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ បានសង្កត់ធ្ងន់ពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្នថា«ចៅក្រមស៊ើបសួរ ត្រូវព្យាយាមសួរព័ត៌មានឱ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន និងមិនឃុំខ្លួន ដូចជាជនត្រូវចោទជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីកំពុងបំបៅដោះកូន ជាស្ត្រីមានកូនតូចៗនៅជាមួយដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរកូនតូចៗទាំងនោះ ឬជនត្រូវចោទជាមនុស្សចាស់ជរា ឬក៏កំពុងមានជំងឺធ្ងន់ធ្ងរទាមទារឱ្យមានការពិនិត្យជាប្រចាំពីគ្រូពេទ្យ។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសបាន មិនគួរគប្បីឃុំខ្លួនជាបណ្តោះអាសន្នឡើយ»។ ត្រង់ចំណុចនេះ សបញ្ជាក់ឱ្យឃើញថា កាលបើការឃុំខ្លួនជា

[26] អនីតិជន គឺជាជនដែលមានអាយុក្រោម១៨ឆ្នាំ។

[27] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ , មាត្រា ៣៩។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២១២។

បណ្តោះអាសន្ន អាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជនត្រូវចោទ ឬអ្នកជាប់បន្ទុកជាមួយជនត្រូវចោទនោះ ចៅក្រមស៊ើបសួរមិនគួរគប្បីសម្រេចឃុំឡើយ។

**ឧទាហរណ៍ទី១៖** ស្ត្រី ក គឺជាស្ត្រីមានផ្ទៃពោះ ០៥(ប្រាំ)ខែ និងមានកូនក្នុងបន្ទុកចំនួន ០៣(បី)នាក់ បានប្រព្រឹត្តិអំពើទម្លាយព័ត៌មានសម្ងាត់ក្នុងក្រុមហ៊ុន ទៅមិត្តភក្តិរបស់នាងចំនួន០៨(ប្រាំបី)នាក់ ជាហេតុធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរ ដែលអំពើនេះ គឺជាបទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈមានចែងក្នុងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ជាបទមជ្ឈិម ដែលត្រូវបានច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ ពី ០១(មួយ)ខែ ដល់ ០១(មួយ)ឆ្នាំ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ត្រូវពិចារណាឱ្យបានល្អិតល្អន់ពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្ន ចំពោះស្ត្រី ក ព្រោះ វាអាចបង្កឱ្យកើតមានជាព្យសន្យកម្មយ៉ាងធ្ងន់ធ្ងរចំពោះកូននៅក្នុងផ្ទៃ និងកូនចំនួន ០៣(បី)នាក់ ដែលស្ថិតនៅក្នុងបន្ទុករបស់នាង កាលបើចៅក្រមស៊ើបសួរសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្នលើស្ត្រី ក ដោយផ្អែកលើមូលហេតុថា នេះជាបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ ក្នុងរយៈពេល ០១(មួយ)ឆ្នាំ។ ប្រសិនបើ មានការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋានស្តួចស្តើងបែបនេះនោះ ការសម្រេចសេចក្តីនេះ ពុំមែនជាមូលដ្ឋានសមស្របឡើយ ព្រោះវាបានធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិ និងប្រយោជន៍របស់ទារកនៅក្នុងផ្ទៃ និងកូនក្នុងបន្ទុកចំនួន ០៣(បី)នាក់ ថាតើទារកដែលគ្មានកំហុស ត្រូវបាត់បង់នូវសិទ្ធិសេរីភាព របស់ខ្លួន ដោយសារតែម្តាយជាអ្នកប្រព្រឹត្តបទល្មើស ឬយ៉ាងណា?[29] តើនេះផ្ទុយពីគោលការណ៍ឯកត្តកម្មដែរ ឬទេ? ហើយតើវាជាការរំលោភសិទ្ធិកុមារដែរ ឬអត់? ចំណែកឯកូនក្រោមបន្ទុកចំនួន ០៣(បី)នាក់នោះវិញ ប្រសិនបើមានការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្នទៅលើម្តាយ តើមានអ្នកណាជាអ្នកចិញ្ចឹម និងផ្គត់ផ្គង់ពួកគាត់? ដែលនេះ គឺជាការប៉ះពាល់ចំពោះសិទ្ធិ និងផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរជាហេតុនាំឱ្យចៅក្រមស៊ើបសួរ គួរតែបញ្ចៀសនូវវិធានការឃុំខ្លួនជាបណ្តោះអាសន្ន។

**ឧទាហរណ៍ទី២៖** លោកវេជ្ជបណ្ឌិត រក្សា គឺជាវេជ្ជបណ្ឌិតជំនាញឯកទេសព្យាបាលជម្ងឺទូទៅ និងវះកាត់ ក្នុងរយៈពេល ០១(មួយ)ថ្ងៃ គាត់បានជួយ និងព្យាបាលអ្នកជម្ងឺជាមធ្យមចំនួន ២៥(ម្ភៃប្រាំ)នាក់។ នៅថ្ងៃមួយគាត់បានធ្វើការវះកាត់បេះដូងឱ្យបុរសម្នាក់។ ជាការធ្វេសប្រហែសរបស់លោក បានធ្វើឱ្យអ្នកជំងឺទទួលមរណៈភាព នៅក្នុងកំឡុងពេលវះកាត់។ អំពើរបស់ លោកវេជ្ជបណ្ឌិត រក្សា គឺជាបទមនុស្សឃាតដោយអចេតនា ត្រូវបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា ២០៧ ដែលច្បាប់

[29] ផ្អែកតាមគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចមានកំណត់ក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

ត្រូវកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ឆ្នាំ ទៅ ០៣(បី)ឆ្នាំ។ ចិរវេលា នៃការកំណត់ទោសដាក់ពន្ធនាគារនេះ គឺធ្ងន់ល្មមនឹងអាចឱ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន លោកវេជ្ជបណ្ឌិត រក្សា ជាបណ្តោះ-អាសន្នដោយផ្អែកលើមូលហេតុ នៃការឃុំខ្លួនជាបណ្តោះអាសន្នបាន។ ប៉ុន្តែនៅក្នុងករណីនេះ ចៅក្រមស៊ើបសួរ ក៏គួរតែពិចារណាទៅលើលក្ខណៈសម្បត្តិរបស់ លោកវេជ្ជបណ្ឌិត រក្សា ដែលថា តើការឃុំខ្លួននេះ អាចកើតជាប្រយោជន៍អ្វីខ្លះ ហើយបង្កព្យសនកម្មយ៉ាងដូចម្តេច នៅក្នុងកំឡុងពេលឃុំខ្លួន? ព្រោះជាមធ្យមភាគប្រចាំថ្ងៃ លោកវេជ្ជបណ្ឌិត រក្សា បានព្យាបាលជម្ងឺឱ្យអ្នកជម្ងឺជាទូទៅយ៉ាងហោចណាស់ ២៥(ម្ភៃប្រាំ)នាក់ក្នុង០១(មួយ)ថ្ងៃ ចុះបើសម្រេចឃុំខ្លួនរូបលោកជាបណ្តោះអាសន្ននោះ តើអ្នកជម្ងឺដែលត្រូវការគ្រូពេទ្យដើម្បីព្យាបាលជម្ងឺត្រូវគិតយ៉ាងណា? ត្រង់ចំណុចនេះ ចៅក្រមស៊ើបសួរ គួរប្រើវិធានការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាជាងការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន។

ម្យ៉ាងវិញទៀត យោងតាម កតិកសញ្ញា ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៩ កថាខណ្ឌទី១ បានបង្ហាញថា «ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដ៏ទៃទៀត នៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម»។ កាលពីទី២៥ ខែតុលា ឆ្នាំ២០២១កន្លងទៅ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានដាក់ចេញនូវយន្តការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានីខេត្ត ដោយនៅក្នុងនោះ លោកបានគូសបញ្ជាក់ថា «ការឃុំខ្លួនបណ្តោះអាសន្ន គប្បីត្រូវបានប្រើប្រាស់សម្រាប់តែចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានភាពស្មុគស្មាញ និងធ្ងន់ធ្ងរ»។[30]

ដូចនេះ ក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ដែលវិធានការនេះ គឺជាវិធានការមួយឆ្លើយតបទៅនឹងការព្រួយបារម្ភទាំងឡាយខាងលើនេះបាន ប៉ុន្តែចៅក្រមស៊ើបសួរ មិនអាចអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះអនីតិជនដែលមានអាយុក្រោម ១៤ដប់បួន)ឆ្នាំ បានឡើយ។[31]

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ឬសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរអាចដាក់ជននេះ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើនតាមការសម្រេចរបស់តុលាការ និងមានគោលការណ៍រឹតត្បិត

[30] https://kohsantepheapdaily.com.kh/

[31] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២២៤។

សិទ្ធិសេរីភាពមួយចំនួនក្នុងគោលដៅបង្ការ ការពារ និងធានានាំជននោះមកអនុវត្តទោស។[32] ហើយកាតព្វកិច្ច ដែលបង្គាប់ឱ្យជនត្រូវចោទស្ថិតក្រៅឃុំអនុវត្តនៅក្នុងកំឡុងពេលស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួមមានចំនួន ១២(ដប់ពីរ) ចំណុចដូចតទៅ៖[33]

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ
- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ
- មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ
- ត្រូវចូលបង្ហាញខ្លួនតាមកាលកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថចាត់តាំងដោយចៅក្រមស៊ើបសួរ
- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ
- មិនត្រូវបើកបររថយន្ត
- មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ
- ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់
- ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ហើយដើម្បីអនុវត្តនូវចំណុចទាំង ១២(ដប់ពីរ)ខាងលើនេះ ចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានឡើយ។

ក្នុងករណីចៅក្រមស៊ើបសួរបានដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែជនត្រូវចោទបានរំលោភបំពានលើកាតព្វកិច្ចដែលចៅក្រមស៊ើបសួរបានកំណត់ឱ្យ នោះចៅក្រមស៊ើបសួរ

---

[32] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំសិក្សា២០១៣-២០១៤ ទំព័រ ៤១ និងទំព័រ ៤២។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២២៣។

អាចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបាន ដោយពុំចាំបាច់យោងតាមមាត្រា ២០៥ (មូលហេតុ នៃការឃុំខ្លួនបណ្ដោះអាសន្ន) ឡើយ និងមិនគិតពីបទល្មើសអ្វីទាំងអស់។ កាលណាចៅក្រមស៊ើបសួរ ចេញដីកាឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា និងជនត្រូវចោទ។ ព្រះរាជអាជ្ញាមានសិទ្ធិប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ ចំណែកឯជនត្រូវចោទមានសិទ្ធិប្ដឹងក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃដូចគ្នា គិតចាប់ពីថ្ងៃចៅក្រមស៊ើបសួរសម្រេចការឃុំខ្លួន។

## កថាខណ្ឌទី៣៖ ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន

ក្រោយពីចៅក្រមស៊ើបសួរ សម្រេចឱ្យមានការឃុំខ្លួនជាបណ្ដោះអាសន្ន ថិរវេលា នៃការឃុំខ្លួនជាបណ្ដោះអាសន្ន គឺជាចំណុចសំខាន់មួយនៅក្នុងការកំណត់ថា បទល្មើសប្រភេទបែបនេះ ត្រូវឃុំខ្លួនក្នុងរយៈពេលប៉ុន្មានខែ? ជាក់ស្ដែងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់បង្ហាញយ៉ាងច្បាស់ៗពាក់ព័ន្ធនឹងថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នអាចយូរ ឬឆាប់អាស្រ័យទៅលើប្រភេទ នៃបទល្មើស ថាតើជាបទមជ្ឈិម ឬបទឧក្រិដ្ឋ? និងអាយុរបស់ជនត្រូវចោទ ថាតើជានីតិជន[34] ឬជាអនីតិជន?

ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវផ្អែកទៅលើ ប្រភេទ នៃបទល្មើស ចំណាត់ថ្នាក់ នៃបទល្មើស និងស្ថានអាយុរបស់ជនត្រូវចោទ។ ដូច្នេះហើយ យើងគួរគប្បីស្វែងយល់អំពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដោយផ្អែកលើបទល្មើសចំនួនពីរប្រភេទគឺ៖ ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ (៣.១) និងថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិម (៣.២)។

### ៣.១. ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ

ច្បាប់បានកំណត់អំពីបទឧក្រិដ្ឋ គឺជាចំណាត់ថ្នាក់ នៃបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរជាងបទល្មើសដទៃទៀត។ ដូច្នេះ ថិរវេលាក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋត្រូវមានលក្ខណៈយូរជាងថិរវេលាក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះបទមជ្ឈិម ដែលយើងត្រូវយកមកសិក្សា។ មិនតែប៉ុណ្ណោះ ច្បាប់ក៏បានវែកញែកអំពីលក្ខខណ្ឌ នៃអាយុរបស់ជនត្រូវចោទដែលប្រព្រឹត្តបទឧក្រិដ្ឋ ដើម្បីកំណត់អំពីថិរវេលាក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នផងដែរ។ ដូច្នេះហើយ យើងគប្បីស្វែងយល់អំពីការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋដោយផ្អែកលើអាយុ៖ ការឃុំខ្លួននីតិជន (៣.១.១) និងការឃុំខ្លួនអនីតិជន (៣.១.២)។

[34] នីតិជន គឺជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។

### ៣.១.១. ការឃុំខ្លួននីតិជន

ចំពោះនីតិជន ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនជាបណ្ដោះអាសន្ន មិនអាចលើសពី ០៦ (ប្រាំមួយ)ខែបានឡើយ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនជាបណ្ដោះ-អាសន្នម្ដងបានចំនួន ០៦(ប្រាំមួយ)ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរ អាចសម្រេចពន្យារការឃុំខ្លួនជាបណ្ដោះអាសន្នបានតែ ០២(ពីរ)ដងតែប៉ុណ្ណោះ។[35]

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននោះ។ កាលណាជនត្រូវចោទ មានមេធាវីអម នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិ នៃមាត្រា២០៥ (មូលហេតុ នៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ដីកានេះ ត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។[36]

### ៣.១.២. ការឃុំខ្លួនអនីតិជន

អនីតិជន គឺជាជនដែលស្ថិតនៅក្រោមអាយុ ១៨(ដប់ប្រាំបី)ឆ្នាំ ពោលគឺជាជនទាំងឡាយណាដែលពុំទាន់ដល់នីតិភាព។ អនីតិជនត្រូវបានច្បាប់ការពារសិទ្ធិ និងប្រយោជន៍នានារបស់ខ្លួន ទោះបីជា អនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌក៏ដោយ ក៏របប នៃការដាក់ទោសដាក់ពន្ធនាគារ មានការបន្ធូរបន្ថយខ្ពស់ បើធៀបនឹងនីតិជន។ ដោយឡែកចំពោះការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនវិញ ថិរវេលា និងលក្ខខណ្ឌនៃការឃុំខ្លួនអាចមានការបន្ធូរបន្ថយ ឬក៏មិនអាចឃុំខ្លួនបានតែម្ដងក៏មាន។

ជាក់ស្ដែងអនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នបានជាដាច់ខាត។ ចៅក្រមស៊ើបសួរត្រូវសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ មជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នរង់ចាំសេចក្ដីសម្រេចរបស់តុលាការ។ ដោយឡែកចំពោះអនីតិជន ដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ រហូតដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ក្នុងករណីពិសេស និងចាំបាច់ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នបាន ហើយការឃុំខ្លួននេះមានកំណត់ថិរវេលាដូចតទៅ៖

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៨ ។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២១១។

-ក្នុងករណីអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ រហូតដល់ អាយុក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមានចិរវេលាកំណត់មិនអាចលើសពី ០៤(បួន)ខែ បានឡើយ។

-ក្នុងករណីអនីតិជន មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ រហូតដល់ អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមានចិរវេលាកំណត់មិនអាចលើសពី ០៦(ប្រាំមួយ)ខែ បានឡើយ។

## ៣.២. ចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិម

បទមជ្ឈិម គឺជាបទល្មើសដែលមានលក្ខណៈលជាងបទឧក្រិដ្ឋ។ ដូច្នេះហើយ បានជាចិរវេលាក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះបទមជ្ឈិម មានរយៈពេលតិចជាងបទឧក្រិដ្ឋ។ ហើយចិរវេលាក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន ទៅលើជនត្រូវចោទ ត្រូវផ្អែកលើលក្ខខណ្ឌអាយុផងដែរ។ ដូច្នេះហើយ យើងគួរសិក្សាស្វែងយល់អំពីចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិមពាក់ព័ន្ធនឹង៖ ការឃុំខ្លួននីតិជន (៣.២.១) និងការឃុំខ្លួនអនីតិជន (៣.២.២)។

### ៣.២.១. ការឃុំខ្លួននីតិជន

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ០៤(បួន) ខែបានទេ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់ មិនឱ្យលើសពី ០២(ពីរ)ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាល នៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់ឡើយ។[37] ចំពោះនីតិវិធី នៃការពន្យារចិរវេលាឃុំខ្លួនជាបណ្ដោះអាសន្នក្នុងបទមជ្ឈិម គឺមានដំណើរដូចគ្នានឹងការពន្យារចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋដែរ។

### ៣.២.២. ការឃុំខ្លួនអនីតិជន

ចំពោះការឃុំខ្លួនអនីតិជន នៅក្នុងករណីបទមជ្ឈិមវិញ ក៏ពុំសូវខុសគ្នាប៉ុន្មានដែរពីការឃុំខ្លួនក្នុងបទឧក្រិដ្ឋ គ្រាន់តែការឃុំខ្លួនក្នុងបទមជ្ឈិមមានចិរវេលាខ្លីជាងការឃុំខ្លួនក្នុងបទឧក្រិដ្ឋ។

ចិរវេលាកំណត់ក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះ អនីតិជននៅក្នុងបទមជ្ឈិម មានដូចតទៅ៖

- អនីតិជន ដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចឃុំខ្លួនជាបណ្ដោះអាសន្នបានជាដាច់ខាត។
- អនីតិជន ដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ រហូតដល់ អាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមានចិរវេលាកំណត់មិនអាចលើសពី ០២(ពីរ)ខែបានឡើយ។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា២០៩។

- អនីតិជន ដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ រហូតដល់ អាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមានថិរវេលាកំណត់មិនអាចលើសពី ០៤(បួន)ខែបានឡើយ។

ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នដូចមានរៀបរាប់ខាងលើនេះ មិនត្រូវមានរយៈពេលលើសពីពាក់កណ្ដាល នៃអប្បបរមា នៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជនបានឡើយ។[38]

### ៣.៣. ថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទល្មើសពិសេស

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនជាបណ្ដោះអាសន្នមិនអាចលើសពី ០១(មួយ) ឆ្នាំបានឡើយ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ០១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ០២(ពីរ)ដងគត់។[39]

## ផ្នែកទី២៖ សិទ្ធិរបស់អ្នកជាប់ឃុំជាបណ្ដោះអាសន្ន

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន សិទ្ធិសេរីភាពមួយចំនួនរបស់ជនត្រូវចោទ ត្រូវបានដកហូតមួយផ្នែក និងរឹតត្បិតមួយភាគធំ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏ច្បាប់បានធានារក្សានូវសិទ្ធិមួយចំនួនជូនជនត្រូវចោទផងដែរ។ ការបែងចេញនូវសិទ្ធិរបស់ជនត្រូវចោទដែលជាប់ឃុំជាបណ្ដោះ-អាសន្ន ត្រូវបែងចែកឱ្យច្បាស់លាស់ អំពីសិទ្ធិរបស់ពួកគេ អំពីអាយុ និងអំពីភេទរបស់ជនត្រូវចោទនោះ។ ដូច្នេះហើយបានជាយើងត្រូវសិក្សាស្វែងយល់អំពី៖ សិទ្ធិរបស់នីតិជនក្នុងការជាប់ឃុំជាបណ្ដោះអាសន្ន និងសិទ្ធិរបស់អនីតិជនក្នុងការជាប់ឃុំជាបណ្ដោះអាសន្ន។

### កថាខណ្ឌទី១៖ សិទ្ធិទូទៅរបស់នីតិជនក្នុងការជាប់ឃុំជាបណ្ដោះអាសន្ន

### ១.១. សិទ្ធិស្នើសុំឱ្យបំពេញកិច្ច

ការស៊ើបសួរ គឺជាសិទ្ធិ និងតួនាទីក្នុងការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរ ក្នុងការស្រាវជ្រាវចំពោះអង្គហេតុ នៃបទល្មើសព្រហ្មទណ្ឌ ក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ។ ចំពោះកិច្ចស៊ើបសួរទាំងអស់ ត្រូវបានអនុវត្ត និងដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរ ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងបញ្ជាក់ពីការពិត នៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្ដើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។ ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២១៤។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២១០ ។

វីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬពុំចាំបាច់ធ្វើក៏បាន។ គួរកត់សម្គាល់ថា កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ត្រូវបានគេកំណត់ដូចតទៅ៖

- ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ
- ការសួរចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ
- ការស្តាប់ចម្លើយសាក្សី
- ការឆែកឆេរ
- ការចាប់យកវត្ថុតាង
- កោសល្យវិច័យ
- ការស្តាប់ទូរស័ព្ទ
- ការចាត់ឱ្យស៊ើបសួរជំនួស និងវិធានការនិរន្តរាយ (ជាវិធានការសំដៅដល់ការចេញដីកាផ្សេងៗដោយចៅក្រមស៊ើបសួរ ដែលក្នុងនោះមានដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ[40])។

ចៅក្រមស៊ើបសួរក៏មានតួនាទីបំពេញកិច្ចស៊ើបសួរ តាមការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ របស់តំណាងអយ្យការ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ និងមេធាវី។ ក្នុងករណីមានការស្នើសុំឱ្យបំពេញកិច្ចណាមួយ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចត្រូវតែស៊ើបសួរតាមការស្នើសុំនោះទេ ដោយចៅក្រមស៊ើបសួរអាចបដិសេធសំណើរបានដោយតម្រូវឱ្យជូនដំណឹងដល់អ្នកស្នើសុំ។ ប្រសិនបើគ្មានការជូនដំណឹងអំពីការបដិសេធដល់អ្នកស្នើសុំទេ នោះអ្នកស្នើសុំអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន។[41]

ដោយឡែក តើជនត្រូវចោទអាចស្នើសុំបំពេញកិច្ចបានយ៉ាងដូចម្តេច?

[40] ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការដែលកាត់បន្ថយសេរីភាពមួយចំនួនរបស់ជនត្រូវចោទ។ វិធានការនេះមានលក្ខណៈស្រាលជាងវិធានការឃុំខ្លួនជាបណ្តោះអាសន្ន។ ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជនត្រូវចោទ នៅក្រៅឃុំ តែត្រូវគោរពកាតព្វកិច្ចមួយចំនួន ឬច្រើន នៃមាត្រា ២២៣ (កាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនកំណត់ពេលវេលា គឺអាស្រ័យទៅលើចៅក្រមស៊ើបសួរជាអ្នកកែប្រែ ឬលុបចោលបានគ្រប់ពេលវេលា។ (យោងតាមសៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន របស់វរសេនីយ៍ឯក អាន សូវីដា ទំព័រ ៨៤)។

[41] https://ciclg.com/kh/article/145

នៅគ្រប់ពេលវេលា នៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ (ចំពោះលិខិតគម្រូពាក្យស្នើសុំបំពេញកិច្ចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃអត្ថបទសារណានេះ)។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ០១(មួយ)ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ (ចំពោះដីកាសម្រេចមិនអនុញ្ញាតឱ្យជនល្មើសនៅក្រៅឃុំជាបណ្តោះអាសន្ន មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃអត្ថបទសារណានេះ)។

ក្នុងករណីចៅក្រមស៊ើបសួរមិនអាចសម្រេចក្នុងចិរវេលា ០១(មួយ)ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[42]

### ១.២. សិទ្ធិស្នើសុំនៅក្រៅឃុំ

ជនត្រូវចោទអាចដាក់ពាក្យស្នើសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ហើយការដាក់ពាក្យសុំនេះអាចធ្វើបានចំនួន ០២(ពីរ)លើក ដោយម្តងទៅចៅក្រមស៊ើបសួរ និងម្តងទៀតទៅចៅក្រមស៊ើបសួរក៏បាន ទៅសភាស៊ើបសួរក៏បាន។ នៅពេលដែលជនត្រូវចោទដាក់ពាក្យស្នើសុំរួច ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យស្នើសុំ និងសំណុំរឿង ទៅព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ពីព្រះរាជអាជ្ញាក្នុងរយៈពេលខ្លីបំផុត ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបញ្ជូនរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ (ចំពោះគម្រូពាក្យស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃអត្ថបទសារណានេះ)។

ក្នុងករណីមានការសម្រេចឱ្យឃុំខ្លួនបន្ត ជនត្រូវចោទអាចដាក់ពាក្យស្នើសុំនៅក្រៅឃុំម្តងទៀតបានដាក់ទៅចៅក្រមស៊ើបសួរក៏បាន សភាស៊ើបសួរក៏បាន ក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធពាក្យស្នើសុំ។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។ ហើយចំពោះដីកាសម្រេចពុំព្រមដោះលែងត្រូវមានសម្អាងហេតុ។

---

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ១៣៣។

ក្នុងករណីចៅក្រមស៊ើបសួរយល់ព្រមតាមពាក្យស្នើសុំ ចៅក្រមស៊ើបសួរអាចដោះលែង ឬដាក់ជននោះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។[43]

ជាគោលការណ៍សេចក្តីសម្រេចឱ្យនៅក្រៅឃុំ មិនអាចយកទៅអនុវត្តភ្លាមបានទេ គឺត្រូវទុកឱ្យផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិន។ លើកលែងតែព្រះរាជអាជ្ញា យល់ព្រមជាលាយលក្ខណ៍អក្សរ និងករណីបន្ទាន់ប៉ុណ្ណោះទើបអាចត្រូវដោះលែងភ្លាមបាន។

ក្នុងករណីព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ជនត្រូវចោទត្រូវឃុំខ្លួនជាបណ្តោះអាសន្ន ដើម្បីរង់ចាំសេចក្តីសម្រេចរបស់សភាស៊ើបសួរ។ ជាគោលការណ៍ច្បាប់ មិនបានចែងអំពីការធានាឱ្យនៅក្រៅឃុំទេ ប៉ុន្តែមានមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២០៥ (មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[44]

**ឧទាហរណ៍៖** ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងគោលបំណង ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីច្បាប់។ ដូចនេះ ប្រសិនបើជននោះ មានមូលដ្ឋានធានាច្បាស់លាស់ថា មិនរត់គេចខ្លួនទេ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យនៅក្រៅឃុំបាន។ ហើយចំពោះមូលដ្ឋានធានានេះ គឺជាការសម្រេចរបស់ចៅក្រមស៊ើបសួរ។

ក្នុងករណីសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោះ-លែងឱ្យនៅក្រៅឃុំ ហើយជូនដំណឹងភ្លាមអំពីដីកានេះទៅព្រះរាជអាជ្ញា និងទៅដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលជនត្រូវចោទត្រូវបានឃុំខ្លួន។ ដោយឡែកចំពោះដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ក៏ត្រូវតែជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[45]

(ចំពោះដីកាបង្គាប់ឱ្យដោះលែង និងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មាននៅក្នុងឧបសម្ព័ន្ធទី ៤ និងឧបសម្ព័ន្ធទី ៥ នៃសារណានេះ)។

## ១.៣. សិទ្ធិជ្រើសរើស ឬស្នើសុំមេធាវី

ជនដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានជំនួយពីមេធាវី ព្រោះដើម្បីធានាថា៖

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២១៧ និងមាត្រា ២១៨។

[44] សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ វរសេនីយ៍ឯក អាន សុវីដា ទំព័រ៨២ កថាខណ្ឌទី៣ ផ្នែកទី៣។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា២១៨។

- ជនត្រូវចោទទទួលបានកិច្ចការពារខាងច្បាប់ល្អបំផុត ពីអ្នកជំនាញដែលមានវិជ្ជាជីវៈ។
- ជនត្រូវចោទទទួលបានជំនួយពីបុគ្គលម្នាក់ ដែលមានសមត្ថភាពពន្យល់ និងការពារផលប្រយោជន៍របស់ខ្លួននៅតុលាការ។
- ជនត្រូវចោទគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយភាពយុត្តិធម៌មិនត្រូវបានផ្តល់ដោយមានភាពរើសអើង។[46]

រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូប នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។[47] យោងតាមមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានគូសបញ្ជាក់ថា ជំនួយពីមេធាវី ត្រូវតែមានដាច់ខាត ក្នុងករណីបទឧក្រិដ្ឋ ឬជនត្រូវចោទជាអនីតិជន។ តុលាការត្រូវចាត់តាំងមេធាវីម្នាក់ ប្រសិនបើជនត្រូវចោទ ពុំទាន់បានជ្រើសរើសមេធាវីដោយខ្លួនឯង ដើម្បីប្រគល់សិទ្ធិពឹងពាក់មេធាវីឱ្យការពារសិទ្ធិរបស់ខ្លួន។ (ចំពោះគម្រូពាក្យពឹងពាក់មេធាវី មាននៅក្នុងឧបសម្ព័ន្ធទី៦ នៃសារណានេះ) មេធាវីត្រូវបានច្បាប់អនុញ្ញាតឱ្យជួបកូនក្តីខ្លួនបានគ្រប់ពេលវេលាដែលច្បាប់កំណត់។ (ចំពោះគម្រូពាក្យសុំអនុញ្ញាតជួបកូនក្តីមាននៅក្នុងឧបសម្ព័ន្ធទី៧ នៃសារណានេះ)។

## ១.៤. សិទ្ធិប្តឹងជិតចិត្ត

នៅក្នុងកំឡុងពេលជាប់ឃុំជាបណ្តោះអាសន្ន កាលបើជនត្រូវចោទយល់ថាខ្លួនពុំអាចទទួលបាននូវការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌ នាពេលអនាគតដោយមូលហេតុមួយចំនួនដូចមានកំណត់ក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ (មូលហេតុ នៃការប្តឹងជិតចិត្តចៅក្រមអាសនៈ)។ ចំពោះមូលហេតុដែលនាំឱ្យជនត្រូវចោទអាចប្តឹងជិតចិត្តចៅក្រមអាសនៈបាន លុះត្រាតែមានមូលហេតុកំណត់ដូចខាងក្រោម៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយ នៃរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីណាមួយ។
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬកំពុងមានវិវាទតុលាការជាមួយភាគីណាមួយ

---

[46] សៀវភៅមគ្គុទេសក៍ ស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ ឆ្នាំ២០១២ រៀបរៀងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា CCHR។

[47] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករ[48]ចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះ នៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។

ភាគីដែលចង់ដាក់ពាក្យប្តឹងជំទាស់[49]ចៅក្រមអាសនៈណាមួយ ត្រូវជូនពាក្យប្តឹងតាំងពីពេលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជំទាស់ បើពុំដូចនេះទេ មិនអាចទទួលបានឡើយ។ ពាក្យបណ្តឹងជំទាស់ មិនអាចធ្វើក្រោយពេលបិទការពិភាក្សាដេញដោលឡើយ។ (ចំពោះពាក្យបណ្តឹងជំទាស់មាននៅក្នុងឧបសម្ព័ន្ធទី៨ នៃសារណានេះ)។

## ១.៥. សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

បើទោះបីជាជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្តោះអាសន្នយ៉ាងណាក្តី ក៏ជនត្រូវចោទនៅតែមានសិទ្ធិក្នុងការការពារខ្លួន ការជួបសន្ទនាដោយសម្ងាត់ជាមួយមេធាវីរបស់ខ្លួនដែរ។ តួយ៉ាង មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅមណ្ឌលឃុំខ្លួនបាន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្តាប់ ឬថតបានទេ។ មេធាវីអាចអានលិខិត នៃសំណុំរឿងឱ្យកូនក្តីខ្លួនស្តាប់។ ផ្ទុយទៅវិញមេធាវីមិនអាចឱ្យឯកសារចម្លងនៃសំណុំរឿង ដល់កូនក្តីរបស់ខ្លួនបានឡើយ។[50]

## ១.៦. សិទ្ធិស្នើសុំបិទសំណុំរឿង

នៅពេលផុតថិរវេលា ០១(មួយ)ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ០១(មួយ)ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានស៊ើបសួរដែលធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរឱ្យសម្រេច។ មួយវិញអំណាចត្រង់ចំណុចនេះ មេធាវីក៏អាចប្រើប្រាស់បានដែរ។[51]

[48] មជ្ឈត្តករ គឺជាអ្នកដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម នៅឯមជ្ឈត្តការ។

[49] ប្តឹងជំទាស់ គឺជាការប្តឹងដើម្បីប្តូរចៅក្រមអាសនៈ ស្របតាមមូលហេតុដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយចៅក្រមអាសនៈរួមមាន៖ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៦ មាត្រា ២៨៦។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៦ មាត្រា ២៨៦។

### ១.៧. សិទ្ធិទទួលបានការត្រួតពិនិត្យពីមន្ត្រីពេទ្យ

ជនជាប់ឃុំ ដែលមានជំងឺ ត្រូវទទួលបានសេវាថែទាំសុខភាពប្រចាំថ្ងៃ ដោយមន្ត្រីពេទ្យពន្ធនាគារ។ ជនជាប់ឃុំដែលមានជំងឺធ្ងន់ធ្ងរ ហើយតម្រូវឱ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅ តាមសំណើររបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឱ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើររបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើររបស់ជនជាប់ឃុំ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាលត្រូវបញ្ជូនអ្នកជាប់ឃុំនោះទៅពន្ធនាគារវិញ។

ដោយឡែកចំពោះ អ្នកជាប់ឃុំមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក។[52]

### ១.៨. សិទ្ធិទទួលបានការការពារពីការធ្វើទារុណកម្ម និងផ្សេងៗទៀត

ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាព ការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូបអាហារ ការដាក់ទណ្ឌកម្មជាសមូហភាពដល់អ្នកជាប់ឃុំ និងការប្រើប្រាស់អ្នកជាប់ឃុំឱ្យធ្វើទារុណកម្មអ្នកជាប់ឃុំដូចគ្នាត្រូវហាមឃាត់។

ការប្រើប្រាស់ខ្នោះដៃដើម្បីដាក់ទណ្ឌកម្មអ្នកជាប់ឃុំ[53] ត្រូវហាមឃាត់លើកលែងតែប្រើប្រាស់ក្នុងស្ថានភាពមួយចំនួនដូចជា ពេលមានភាពចលាចលក្នុងពន្ធនាគារ ឬពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ ឬពេលមានហេតុផលខាងពេទ្យ ឬដើម្បីការពារជនជាប់ឃុំកុំឱ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ។[54]

### ១.៩. សិទ្ធិក្នុងការប្ដឹងតវ៉ាចំពោះអំពើរំលោភបំពាន

កាលបើអ្នកជាប់ឃុំ ទទួលរងនូវការរំលោភបំពានសិទ្ធិនៅក្នុងកំឡុងពេលជាប់ឃុំ នោះជនជាប់ឃុំមានសិទ្ធិប្ដឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬ

---

[52] មាត្រា៣៨ នៃច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ២០១១។

[53] អ្នកជាប់ឃុំ សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិត ដែលត្រូវបានបញ្ជូនមកឃុំខ្លួន នៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួន ចេញដោយអាជ្ញាធរតុលាការ។ (យោងតាម ច្បាប់ ស្ដីពី ពន្ធនាគារ មាត្រា ៤)

[54] មាត្រា ៥០ និងមាត្រា ៥៣ នៃច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ២០១១។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភបំពានរបស់ជនជាប់ឃុំដូចគ្នា ឬអំពើរំលោភរបស់មន្ត្រីពន្ធនាគារ។

ពាក្យបណ្តឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ[55] ឬអ្នកសួរសុខទុក្ខផ្លូវការ ឬសាច់ញាតិ ឬមេធាវីរបស់ជនជាប់ឃុំ ឬតំណាងអង្គការអយ្យការ[56]។ រាល់បណ្តឹងតវ៉ាត្រូវតែបានដោះស្រាយ និងឆ្លើយតបក្នុងរយៈពេលសមស្រប។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវដាក់ទណ្ឌកម្ម ឬត្រូវបានរើសអើងដោយសារតែបានដាក់ពាក្យបណ្តឹង ឬការដាក់ពាក្យស្នើសុំនោះឡើយ។[57]

### ១.១០. សិទ្ធិក្នុងការប្រត្តិបត្តិសាសនា

បើទោះបីជាជនត្រូវចោទកំពុងជាប់ឃុំជាបណ្តោះអាសន្ននៅក្នុងពន្ធនាគារយ៉ាងណាក្តី ក៏សិទ្ធិនៅក្នុងការមានជំនឿលើសាសនារបស់ខ្លួន នៅតែមានដដែល ហើយគ្មានជនណាម្នាក់អាចមកហាមឃាត់បានឡើយ ពោលគឺជនត្រូវចោទនៅតែអាចប្រត្តិបត្តិសាសនារៀងៗខ្លួនបាន ដោយពុំមានការហាមឃាត់ ឬការបង្ខិតបង្ខំឱ្យប្រតិបត្តិសាសនាណាមួយឡើយ។[58]

### ១.១១. សិទ្ធិទទួលបានរបបអាហារ

ការផ្តល់អាហារដល់អ្នកជាប់ឃុំ ត្រូវតែមានការយកចិត្តទុកដាក់គិតគូរអំពីអាហារតម ស្របតាមតម្រូវការខាងសុខភាព ដែលបញ្ជាក់ពីមន្ត្រីពេទ្យក្នុងពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ។

**ឧទាហរណ៍ទី១៖** លោក ក មានជំងឺទឹកនោមផ្អែម។ មន្ត្រីពេទ្យបានណែនាំឱ្យលោកលេបថ្នាំ និងតមចំពោះអាហារដែលមានជាតិផ្អែមមួយចំនួន។ល។ ដូចនេះ របបអាហារនៅក្នុងពន្ធនាគារនៅក្នុងកំឡុងពេលឃុំខ្លួនជាបណ្តោះអាសន្ននេះត្រូវផ្តល់ជូនលោក ក ជាទៀងទាត់ និងស្របទៅតាមការណែនាំរបស់មន្ត្រីពេទ្យក្នុងពន្ធនាគារ។

---

[55] មន្ត្រីពន្ធនាគារ សំដៅដល់មន្ត្រីដែលស្ថិតនៅក្នុងក្របខណ្ឌពន្ធនាគារ។ (យោងតាម ច្បាប់ ស្តីពី ពន្ធនាគារ មាត្រា ៤)

[56] អង្គការអយ្យការ គឺជាស្ថាប័នមួយ ដែលមាននៅអមគ្រប់សាលាជម្រះក្តីទាំងអស់ ដែលជាអ្នកតំណាងឱ្យសង្គម និងជាអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ ហើយមានតួនាទីជាអ្នកធ្វើការចោទប្រកាន់ខាងផ្នែកបទល្មើសព្រហ្មទណ្ឌ ជាអ្នកធ្វើបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ព្រមទាំងជាអ្នកធានារ៉ាប់រងការអនុវត្តនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីការបង្គាប់ឱ្យចាប់ខ្លួន។ (យោងតាមសៀវភៅ ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ វរសេនីយ៍ឯក អាន សូរីដា ទំព័រ ៥០)

[57] មាត្រា ២៨ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១។

[58] មាត្រា ២៩ នៃច្បាប់ស្តីពី ពន្ធនាគារ ឆ្នាំ២០១១។

**ឧទាហរណ៍ទី២៖** លោក គ កាន់សាសនាអ៊ីស្លាម។ លោកមិនពិសារសាច់ជ្រូកឡើយ។ ការណ៍ដែលយកសាច់ជ្រូកយកមកឱ្យលោកពិសារ ឬបង្ខំឱ្យត្រូវតែបរិភោគនោះ គឺជាការរំលោភបំពានសិទ្ធិរបស់អ្នកជាប់ឃុំយ៉ាងធ្ងន់ធ្ងរជាហេតុនាំលោកមានសិទ្ធិធ្វើពាក្យបណ្ដឹងដូចមានកំណត់នៅក្នុងចំណុច ១.៩ កថាខណ្ឌទី១ នៃផ្នែកនេះ។

### ១.១២. សិទ្ធិក្នុងការទទួលបានព័ត៌មាន និងដំណឹងផ្សេងៗ

ជនជាប់ឃុំ មានសិទ្ធិទទួល និងផ្ញើលិខិតឆ្លងឆ្លើយ។ លិខិតឆ្លងឆ្លើយរបស់អ្នកជាប់ឃុំ ត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារ ដែលត្រូវបានប្រគល់សិទ្ធិ លើកលែងតែលិខិតរបស់មេធាវី។ លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំ ត្រូវបានដកហូតកាលបើមានការពាក់ព័ន្ធដល់សន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ។[59]

ក្រៅពីនេះ អ្នកជាប់ឃុំ ត្រូវបានអនុញ្ញាតឱ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី សារព័ត៌មាន និងទំនាក់ទំនងទូរស័ព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ។ អ្នកជាប់ឃុំ អាចអនុញ្ញាតឱ្យចូលសិក្សាស្រាវជ្រាវ នៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឱ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង។ លើសពីនេះ នៅពេលដែលមានដំណឹងពាក់ព័ន្ធនឹងជំងឺ ឬមរណៈភាពរបស់អ្នកជាប់ឃុំ ឬសាច់ញាតិអ្នកជាប់ឃុំ នោះពន្ធនាគារមានកាតព្វកិច្ចនៅក្នុងការជូនដំណឹងទៅវិញទៅមក។[60] ក្រៅពីការទទួលបានព័ត៌មានចំណេះដឹង និងដំណឹងផ្សេងៗដូចមានរៀបរាប់ខាងលើនេះ ការទទួលដំណឹងពាក់ព័ន្ធនឹងដំណើរការនីតិវិធី ការទទួលបានដំណឹងភ្លាមពាក់ព័ន្ធនឹងការសម្រេចរបស់ចៅក្រមស៊ើបសួរ ក្រោយពេលដែលខ្លួនបានដាក់ពាក្យស្នើសុំនៅក្រៅឃុំ ដូចមានរៀបរាប់នៅក្នុងចំណុចទី ១.២ កថាខណ្ឌទី១ ផ្នែកទី២ នៃជំពូកនេះរួច តើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបន្ត ឬសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ?

## កថាខណ្ឌទី២៖ សិទ្ធិរបស់អនីតិជនក្នុងការជាប់ឃុំជាបណ្ដោះអាសន្ន

បទដ្ឋានជាតិ និងអន្តរជាតិមួយចំនួនមិនគាំទ្រឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះអនីតិជនឡើយ។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ល្អបំផុតរបស់អនីតិជនត្រូវបានការពារដោយការមិនបំបែកពួក

[59] មាត្រា ៣២ នៃច្បាប់ស្ដីពី ពន្ធនាគារ ឆ្នាំ២០១១។

[60] មាត្រា ៣៧ នៃច្បាប់ស្ដីពី ពន្ធនាគារ ឆ្នាំ២០១១។

គេចេញពីឪពុកម្ដាយ។[61] ការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន គឺជាការរឹតត្បិតសិទ្ធិសេរីភាព និងការបំបែកចេញកុមារពីអ្នកអាណាព្យាបាលរបស់ពួកគេ។ តែក្នុងកាលៈទេសៈតម្រូវមួយចំនួន អាយុរបស់អនីតិជន និងផលប្រយោជន៍ផ្សេងទៀត ចៅក្រមស៊ើបសួរ អាចសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងមិនឃុំខ្លួនបណ្ដោះអាសន្នបាន។ ចុះប្រសិនបើកាលៈទេសៈតម្រូវនឹងស្ថានអាយុអនីតិជន អាចឱ្យច្បាប់កំណត់ឃុំខ្លួនបាន តើក្នុងកំឡុងពេលជាប់ឃុំ អនីតិជនទទួលបាននូវសិទ្ធិអ្វីខ្លះ?

### ២.១. សិទ្ធិទទួលបានបន្ទប់ឃុំឃាំងឯកជន

ផ្អែកតាមស្មារតី នៃច្បាប់ស្ដីពីពន្ធនាគារ បានគូសបញ្ជាក់ថា «អ្នកជាប់ឃុំជាអនីតិជន ត្រូវដាក់បំបែកពីអ្នកជាប់ឃុំជានីតិជន» ហើយនៅក្នុងមាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា «បើអនីតិជនត្រូវជាប់ពន្ធនាគារ កន្លែងឃុំឃាំងត្រូវនៅដាច់ដោយឡែកពីនីតិជន។ អនីតិជនត្រូវស្ថិតនៅក្រោមរបបដោយឡែកជា ឯកត្តបុគ្គល ដែលជាទីកន្លែងអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ»។

### ២.២. សិទ្ធិទទួលបានជំនួយពីមេធាវី

ជាក់ស្ដែងមាត្រា ១៤៣ និងមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ទាមទារជាចាំបាច់ថា គ្រប់អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិបទល្មើស ត្រូវមានមេធាវីជាដាច់ខាត។ ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងកំឡុងពេលស្ដាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្នុងករណីគ្មានការជ្រើសរើសចៅក្រមស៊ើបសួរ ត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុង ច្បាប់ ស្ដីពី លក្ខន្តិកៈមេធាវី។[62] (ចំពោះលក្ខន្តិកៈមេធាវី សូមពិនិត្យទៅឧបសម្ព័ន្ធទី៩ នៃសារណានេះ)។ ដោយឡែកចំពោះសោហ៊ុយចំណាយក្នុងការធ្វើការ និងថតចម្លងសំណុំរឿង គឺជាបន្ទុករបស់រដ្ឋ។[63] ពោលគឺមានន័យថា នៅពេលដែលអនីតិជន ត្រូវបានចោទប្រកាន់ពីបទល្មើសអ្វីមួយអនីតិជននោះ ត្រូវទទួលបានសិទ្ធិដោយស្វ័យប្រវត្តិនៅក្នុងការទទួលបានមេធាវី ហើយប្រសិនបើអនីតិជនពុំមានលទ្ធភាពក្នុងការស្វែងរកមេធាវីការពារក្ដីឱ្យខ្លួន នោះចៅក្រមស៊ើបសួរ ត្រូវចាត់តាំងមេធាវីម្នាក់ឱ្យអនីតិជន ជាដាច់ខាត ហើយសម្រាប់សោហ៊ុយចំណាយផ្សេងៗពាក់ព័ន្ធនឹងរឿងនេះ គឺជាបន្ទុករបស់រដ្ឋ។

---

[61] មាត្រា ៩ នៃអនុសញ្ញា ស្ដីពី សិទ្ធិកុមារ។

[62] មាត្រា ៣២ នៃច្បាប់ ស្ដីពី យុត្តិធម៌អនីតិជន។

[63] មាត្រា ៥០ នៃច្បាប់ ស្ដីពី យុត្តិធម៌អនីតិជន។

## ២.៣. សិទ្ធិទទួលបានការព្យួរការសិក្សា និងការព្យួរការងារ

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរគ្រឹះស្ថាន ឬនិយោជក អាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្ដីសម្រេចរបស់តុលាការជាស្ថាពរ។ ក្នុងករណី តុលាការសម្រេចសេចក្ដីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឱ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ[64] ពោលគឺមានន័យថា ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន គ្រឹះស្ថានសិក្សា មានកាតព្វកិច្ចព្យួរការសិក្សានោះ ឱ្យអនីតិជនរហូតមានការសេចក្ដីសម្រេចជាស្ថាពរពីតុលាការ ដោយពុំអាចយកវត្តមាន ឬទម្លាក់អនីតិជនបានឡើយ។

**ឧទាហរណ៍៖** ក ជាអនីតិជន អាយុ ១៥(ដប់ប្រាំ)ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នដើម្បីដំណើរការនីតិវិធីស៊ើបសួរ។ ក្នុងករណីនេះ គ្រឹះស្ថានសិក្សា ត្រូវព្យួរការសិក្សាឱ្យ ក។ ១៥(ដប់ប្រាំ)ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរ បានរកឃើញថា ក ពុំមានទោសនោះទេ។ ដូចនេះ គ្រឹះស្ថានសិក្សាត្រូវ ទទួល ក ឱ្យចូលរៀនធម្មតាវិញ ដោយពុំត្រូវឱ្យមានការអាក់ខាន ឬរើសអើងឡើយ។

## ២.៤. សិទ្ធិដទៃទៀតដែលគាំពារដោយច្បាប់

ក្រៅពីសិទ្ធិពិសេសទាំងនេះ អនីតិជនក៏ទទួលបានសិទ្ធិផ្សេងទៀត មិនខុសពីនីតិជននោះទេ នៅក្នុងកំឡុងពេលខ្លួនជាប់ឃុំជាបណ្ដោះអាសន្ន ដែលសិទ្ធិទាំងនោះរួមមាន៖

- សិទ្ធិមិនផ្ដល់ចម្លើយនៅពេលដែលមាន ឬគ្មានមេធាវី
- សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់ នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានដំណឹង
- សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងគ្រប់ដំណាក់កាល នៃរឿងក្ដី
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែ
- សិទ្ធិបង្ហាញភស្ដុតាង
- សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងបទដ្ឋានគតិយុត្តិជាធរមាន។[65]

---

[64] មាត្រា ៣៧ នៃច្បាប់ ស្ដីពី យុត្តិធម៌អនីតិជន។

[65] មាត្រា ៦ នៃច្បាប់ ស្ដីពី យុត្តិធម៌អនីតិជន។

# ជំពូកទី២

# នីតិវិធី នៃការឃុំខ្លួនបណ្ដោះអាសន្ន និងការមិនឃុំខ្លួនបណ្ដោះអាសន្ន

# ជំពូកទី២
# នីតិវិធី នៃការឃុំខ្លួនបណ្ដោះអាសន្ន និងការមិនឃុំខ្លួនបណ្ដោះអាសន្ន

## ផ្នែកទី១៖ ដំណើរការ នៃការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនជាបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌ ដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។[66] ប្រទេសកម្ពុជា គឺជាភាគី នៃកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលបញ្ញត្តិគោលការណ៍ច្បាប់អន្តរជាតិ ស្តីពី នីតិវិធីព្រហ្មទណ្ឌ។[67] ការឃុំខ្លួនជាបណ្ដោះអាសន្ន គឺជាវិធានការបង្ខាំងជនត្រូវចោទទុកក្នុងពន្ធនាគារដែលសម្រេចដោយចៅក្រមស៊ើបសួរ និងតាមការស្នើសុំរបស់ព្រះរាជ-អាជ្ញា ចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ផ្តន្ទា-ទោសដាក់ពន្ធនាគារស្មើ ឬលើសពី ០១(មួយ)ឆ្នាំ ហើយការសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នត្រូវតែមានមូលហេតុ នៃការឃុំខ្លួនជាបណ្ដោះអាសន្ន (មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រ កម្ពុជា) ច្បាស់លាស់។[68]

ការឃុំខ្លួនជាបណ្ដោះអាសន្នមិនមែនជាវិធានទូទៅ[69] សម្រាប់ឱ្យតុលាការអនុវត្តនីតិវិធីដែលមានប្រសិទ្ធិភាពចំពោះជនត្រូវចោទនោះឡើយ ដូច្នេះហើយបានជាចៅក្រមត្រូវពិនិត្យឱ្យបានហ្មត់ចត់ និងចេញពីឆន្ទៈរបស់ខ្លួនមុននឹងឈានទៅដល់ការសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នចំពោះជនត្រូវចោទ ដើម្បីជៀសវាងកុំឱ្យប៉ះពាល់ទៅដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ ប្រសិនបើ លក្ខខណ្ឌមិនតម្រូវដូចមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងបញ្ញត្តិ នៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។[70] ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានសម្រេចដោយឆន្ទានុ-

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា២០៣។

[67] សេចក្តីពន្យល់ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង, ការបោះពុម្ពផ្សាយលើកទី១ នៅខែមីនា ឆ្នាំ២០១៤, ទំព័រ១៣២។

[68] សន្ទានុក្រម នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

[69] កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា៨ កថាខណ្ឌទី៣។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៣។

សិទ្ធិ[71] របស់ចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីស៊ើបសួរ នៅពេលដែលព្រះរាជអាជ្ញាជ្រើសរើសជម្រើស នៃការចោទប្រកាន់ដោយបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយមានលិខិតជូនដំណឹងបញ្ជូនរឿងទៅជំនុំជម្រះ ឬតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ (ចំពោះលិខិតជូនដំណឹងស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាបង្គាប់ឱ្យចូលខ្លួន មានក្នុងឧបសម្ព័ន្ធទី១០ និងឧបសម្ព័ន្ធទី១១ នៃសារណានេះ)។

ថ្វីបើចៅក្រមជាអ្នកចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក៏ដោយ ប៉ុន្តែចៅក្រមត្រូវឆ្លងកាត់ការផ្តល់ជាមតិយោបល់តាមរយៈដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាជាមុនសិន មុននឹងឈានដល់ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ព្រោះនៅក្នុងច្បាប់បានចែងអំពីសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេច ក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថាមិនសមស្រប។ (ចំពោះដីកាសន្និដ្ឋានស្ថាពរ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១២ នៃសារណានេះ)។

ហេតុដូចនេះហើយ ដើម្បីចេញនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន គឺតម្រូវឱ្យឆ្លងកាត់ចំនួន ០២(ពីរ)ដំណាក់កាលគឺ៖ ដំណាក់កាលព្រះរាជអាជ្ញា (កថាខណ្ឌទី១) និងដំណាក់កាលចៅក្រមស៊ើបសួរ (កថាខណ្ឌទី២)។

## កថាខណ្ឌទី១៖ ដំណាក់កាលព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ត្រូវសម្រេចដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។[72] ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនចំពោះបទល្មើស ដែលត្រូវបានចោទប្រកាន់ទៅកាន់ចៅក្រមស៊ើបសួរ អំពីការស្នើសុំឱ្យឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ។ សូមបញ្ជាក់ផងដែរថា ចៅក្រមស៊ើបសួរមិនត្រូវបានជាប់កាតព្វកិច្ចតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអំពីការឃុំខ្លួនបណ្តោះអាសន្នឡើយ ពោលគឺ ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការស្នើសុំចំពោះចៅក្រមស៊ើបសួរតែប៉ុណ្ណោះ អំពីការឃុំខ្លួនបណ្តោះអាសន្ននេះ ចំណែកឯសិទ្ធិសម្រេច គឺស្ថិតនៅលើឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរក្នុងការចេញនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយព្រះរាជអាជ្ញាត្រូវបានច្បាប់ផ្តល់សិទ្ធិ ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។[73] (ចំពោះសេចក្តីប្តឹងឧទ្ធរណ៍ មាននៅក្នុងឧបសម្ព័ន្ធទី១៣ នៃសារណានេះ) ដូច្នេះហើយបានជា

[71] ឆន្ទានុសិទ្ធិ គឺជាអំណាច ដែលប្រគល់ឱ្យចៅក្រមរើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួន មកដោះស្រាយបញ្ហាណាមួយ។ គឺជាអំណាចរបស់ចៅក្រម ក្នុងការធ្វើសកម្មភាព ក្នុងនីតិវិធី នៃបណ្តឹងដោយមិនបាច់មានពាក្យសុំរបស់ភាគី។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៦។

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

យើងត្រូវសិក្សាស្វែងយល់អំពីនីតិវិធីក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលព្រះរាជអាជ្ញាដូចជា ៖ តួនាទី និងសិទ្ធិអំណាច (១) និងសេចក្តីសន្និដ្ឋានស្ថាពរ (២)។

## ១.១. តួនាទី និងសិទ្ធិអំណាចព្រះរាជអាជ្ញា

នៅក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមានតួនាទី និងសិទ្ធិអំណាចជាយ៉ាងខ្លាំងក្នុងការពារសណ្តាប់ធ្នាប់សាធារណៈ និយាយឱ្យខ្លីព្រះរាជអាជ្ញា គឺជាតួអង្គតំណាងឱ្យរដ្ឋមួយ ដែលស្ថិតនៅក្នុងដែនអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដើម្បីបង្ការ និងបង្ក្រាបទៅលើរាល់បទល្មើសដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់ជាធរមាន មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[74] អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងធ្វើសេចក្តីសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការ នៃសាលាដំបូងរាជធានី-ខេត្ត ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេច ខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងសវនាការរឿងព្រហ្មទណ្ឌ។[75]

ព្រះរាជអាជ្ញាមានតួនាទីក្នុងការដឹកនាំ និងសម្របសម្រួលទៅនឹងសកម្មភាពរបស់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណាអនុវត្តនូវដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។[76] នីតិវិធី នៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរអាចប្រព្រឹត្តទៅបានដោយតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។[77] ត្បិតតែសំណុំរឿងស្ថិតនៅក្នុងនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរក៏ដោយ ប៉ុន្តែព្រះរាជាអាជ្ញានៅតែមានសិទ្ធិក្នុងការអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនតាមរយៈ ការស្នើសុំដោយសេចក្តីសន្និដ្ឋានស្ថាពរទៅកាន់ចៅក្រមស៊ើបសួរអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ក្នុងគោលដៅធានាចំពោះកិច្ចស៊ើបសួរ។

## ១.២. សេចក្តីសន្និដ្ឋានស្ថាពរ

នៅពេលដែលព្រះរាជអាជ្ញាយល់ឃើញថា បទល្មើសដែលត្រូវបានប្តឹងមកកាន់តុលាការដែលមានសមត្ថកិច្ច ហើយអំពើនោះគឺមានធាតុផ្សំ នៃបទល្មើសគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ នោះព្រះរាជអាជ្ញា

[74] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា១៣១។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៧។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៣៧។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ១២៤។

នឹងធ្វើការចោទប្រកាន់ចំពោះបទល្មើសនោះ ដោយជ្រើសរើសជម្រើសក្នុងការចោទប្រកាន់ (ការបើកការស៊ើបសួរ ការបញ្ជូនទៅជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាម) ដូចដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់។[78]

ប្រសិនបើបទល្មើសជាបទមជ្ឈិម ព្រះរាជអាជ្ញាមានជម្រើសក្នុងការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ[79]។ ការបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់[80] ឬការបង្ហាញខ្លួនភ្លាមតាមរយៈដីកាបញ្ជាឱ្យចូលខ្លួនភ្លាម។[81] ចំពោះបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរជានិច្ចដោយអនុលោមតាមមាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា[82] ព្រោះបទឧក្រិដ្ឋត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌមួយធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ និងអស្ថេរភាពសង្គមជាតិ ដូច្នេះហើយ បទល្មើសនេះតម្រូវឱ្យឆ្លងកាត់នីតិវិធីស៊ើបសួរ ដើម្បីធានាទៅដល់នីតិវិធីរឿងក្តីប្រកបទៅដោយប្រសិទ្ធិភាព។

នៅក្នុងដីកាដែលព្រះរាជអាជ្ញាបានជ្រើសរើសក្នុងការចោទប្រកាន់ខាងលើ ព្រះរាជអាជ្ញាសរសេរភ្ជាប់ជាមួយនូវសេចក្តីសន្និដ្ឋានអំពីការស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកានោះ ទៅកាន់ចៅក្រមស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាជ្រើសរើសការចោទប្រកាន់តាមការបើកការស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវសម្រេចសេចក្តីអំពីសេចក្តីសន្និដ្ឋានស្តាពររបស់ព្រះរាជអាជ្ញាក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនសម្រេចសេចក្តីក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃខាងលើ[83]ទេ នោះព្រះរាជអាជ្ញាមានសិទ្ធិប្តឹង ទៅកាន់សភាស៊ើបសួរ ដើម្បីឱ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

### កថាខណ្ឌទី២៖ ដំណាក់កាលចៅក្រមស៊ើបសួរ

នៅក្នុងដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរមានសិទ្ធិប្រើប្រាស់អំណាចរបស់ខ្លួនក្នុងការឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ។ មុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះ-

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៣។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៥។

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៦។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៧ និង មាត្រា ៤៨។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤៧ និង មាត្រា ៤៤។

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៧។

អាសន្ន ចៅក្រមស៊ើបសួរត្រូវគោរពនូវគោលការណ៍សេរីភាពរបស់ជនត្រូវចោទ[84] ដើម្បីជៀងវាងការឃុំខ្លួននាំឱ្យប៉ះពាល់ទៅដល់សេរីភាពរបស់ជនត្រូវចោទ ដែលត្រូវបានច្បាប់ជាតិ និងច្បាប់អន្តរជាតិ បានការពារសិទ្ធិរបស់ពួកគេ។ ភាពចាំបាច់ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងការឃុំខ្លួន និងសេរីភាព គឺចៅក្រមត្រូវថ្លឹងថ្លែងអំពីមូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិទាក់ទងទៅនឹងសេរីភាពរបស់ជនត្រូវចោទ។ សច្ចធារណ៍[85] នៃសេរីភាពតម្រូវឱ្យការឃុំខ្លួនជាបណ្តោះអាសន្នមានមូលដ្ឋានតាមផ្លូវច្បាប់ជាធរមាន ដើម្បីឱ្យមានសមភាពរវាងសេរីភាពរបស់ជនត្រូវចោទ។[86]

ក្រោយពីព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ចំពោះបទល្មើស ហើយបញ្ជូនសំណុំរឿង ដើម្បីបើកឱ្យចៅក្រមស៊ើបសួរអនុវត្តនីតិវិធីស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១៤ នៃសារណានេះ) ដែលភ្ជាប់ជាមួយសេចក្តីសន្និដ្ឋានស្ថាពរ របស់ព្រះរាជអាជ្ញាអំពីការស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។

ចៅក្រមស៊ើបសួរត្រូវពិនិត្យចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលភ្ជាប់ជាមួយសេចក្តីសន្និដ្ឋានស្ថាពរ របស់ព្រះរាជអាជ្ញាអំពីការស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ថាតើការស្នើសុំរបស់ព្រះរាជអាជ្ញាពិតជាសមហេតុផល និងសមស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែរ ឬទេ? ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាអង្គហេតុ ស្របនឹងអង្គច្បាប់ (មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា) នោះចៅក្រមស៊ើបសួរត្រូវសម្រេចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ ក្នុងគោលបំណងការពារ និង

---

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៣។

[85] សច្ចធារណ៍ គឺជាគឺការសរុបសេចក្តីមួយ ឬជាការធ្វើសេចក្តីសន្និដ្ឋានមួយដែលទាញពីការដឹង ការសង្កេត ឬការពិចារណាអំពីអង្គហេតុ ឬព័ត៌មានខ្លះ។ គោលការណ៍នៃសច្ចធារណ៍មានដូចជា៖

- សច្ចធារណ៍ នៃច្បាប់
- សច្ចធារណ៍មិនអាចបដិសេធបាន
- សច្ចធារណ៍អាចជំទាស់បាន
- សច្ចធារណ៍ នៃអង្គហេតុ
- សច្ចធារណ៍ដាច់ស្រេច
- សច្ចធារណ៍ នៃនិរទោស
- សច្ចធារណ៍មិនដាច់ស្រេច (យោងតាមគេហទំព័រ https://law-asia.blogspot.com/2017/03/presumption-and-legitimate.html?fbclid=IwAR3H5fhZFl7ZcOlTw7PCePJes3jw5uA_orkLnWSRDngDmrYQsdkjFGAQ1tA)

[86] សេចក្តីពន្យល់ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និង អន្តរជាតិសម្រាំង, ការបោះពុម្ពផ្សាយលើកទី១ នៅខែមីនា ឆ្នាំ២០១៤, ទំព័រ ១៣០។

ធានានូវសណ្តាប់ធ្នាប់សាធារណៈ។ ប្រសិនចៅក្រមស៊ើបសួរមិនបានចេញក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ តាមការស្នើសុំរបស់ព្រះរាជអាជ្ញាទេ នោះព្រះរាជអាជ្ញាអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនធ្វើការប្តឹងឧទ្ធរណ៍ទៅកាន់សភាស៊ើបសួរ ដើម្បីសម្រេចជំនួសបាន។ ក្នុងករណីនេះមេធាវីអាចស្នើសុំឱ្យកូនក្តីរបស់ខ្លួននៅក្រៅឃុំបានគ្រប់ពេល។ (ចំពោះគម្រូពាក្យសុំឱ្យដោះលែងកូនក្តីនៅក្រៅឃុំមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១៥ នៃសារណានេះ)

### ២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ

នៅក្នុងនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរ គឺជាបុគ្គលតែម្នាក់គត់ ដែលមានតួនាទី និងសិទ្ធិអំណាចធំបំផុត។ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរចំពោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានឡើយ។[87] មួយវិញទៀត ចៅក្រមស៊ើបសួរទទួលបណ្តឹងអង្គហេតុ ពីព្រះរាជអាជ្ញាតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។[88] បន្ថែមពីនេះ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរចំពោះ ការលេចចេញនូវអង្គហេតុថ្មី ឬបទល្មើស ព្រហ្មទណ្ឌថ្មីចំពោះអង្គហេតុនោះឡើយ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវតែជូនព័ត៌មានអំពីអង្គហេតុនេះទៅកាន់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរចំពោះបទល្មើសព្រហ្មទណ្ឌថ្មីតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ លើសពីនេះចៅក្រមស៊ើបសួរមានករណីយកិច្ច[89]ក្នុងការដោះបន្ទុក និងដាក់បន្ទុកទៅលើជនត្រូវចោទ។[90] ច្បាប់ក៏បានផ្តល់អំណាចទៅដល់ចៅក្រមស៊ើបសួរក្នុងការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការផងដែរ។

នៅក្នុងនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរអាចប្រើប្រាស់នូវយន្តការដ៏សំខាន់មួយក្នុងការធានានូវកិច្ចស៊ើបសួររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព ដោយធ្វើការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ។ ការឃុំខ្លួនជាបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវគោរពទៅតាមគោលការណ៍ នៃការឃុំខ្លួនជាបណ្តោះអាសន្ន និងមូលហេតុ នៃការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ។[91] ចៅក្រម

---

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី៣ មាត្រា ២២៤។

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី១ មាត្រា ១២៥។

[89] ករណីយកិច្ច គឺជាកិច្ចដែលត្រូវតែបំពេញជាចាំបាច់ខានពុំបាន។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា១២៧។

ស៊ើបសួរត្រូវមានសំអាងហេតុក្នុងការចេញ ដីកាឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទលើកលែងតែបញ្ញត្តិច្បាប់មានចែង។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញានោះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងនេះត្រូវជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនោះ។ កាលណាមានមេធាវីអមផងនោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។[92] ការសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវមានមូលដ្ឋានគតិយុត្តិក្នុងភាពចាំបាច់ដើម្បីធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន។

### ២.២. ដីកាសម្រេច

ចៅក្រមស៊ើបសួរដែលសម្រេចអំពី ការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅលើ ជនត្រូវចោទដែលមានអត្តសញ្ញាណរបស់ជននោះ ដូចមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវបញ្ជាក់នៅត្រង់សេចក្តីសម្រេចអំពីអតិបរិមានៃការឃុំខ្លួនបណ្តោះអាសន្ន ឱ្យស្របទៅតាមលក្ខខណ្ឌនៃ បទល្មើស ទោស និងអាយុរបស់ជនត្រូវចោទ។ សូមបញ្ជាក់ផងដែរថា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នគ្រាន់តែជាដីកាសម្រេចមួយរបស់ចៅក្រមស៊ើបសួរអំពីការសម្រេចឃុំខ្លួនចំពោះជនត្រូវចោទតែប៉ុណ្ណោះ ដូច្នេះដើម្បីឱ្យមានអានុភាពក្នុងការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទបាន ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមួយទៀត គឺដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ច (ប្រធានពន្ធនាគារ) ទទួលជនត្រូវចោទដែលមានកំណត់នៅក្នុងដីកាសម្រេចនោះនៅក្នុងពន្ធនាគារទៅតាមអតិបរិមាក្នុងការឃុំខ្លួនជននោះ។

### កថាខណ្ឌទី៣៖ អានុភាព នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នមានអានុភាពអនុវត្តភ្លាម នៅពេលដែលចៅក្រមស៊ើបសួរសម្រេចអំពីការឃុំខ្លួននោះនៅក្នុងនីតិវិធីដេញដោល។ ចៅក្រមស៊ើបសួរតម្រូវឱ្យចេញដីកាបង្គាប់ឱ្យឃុំខ្លួនមួយទៀត ដើម្បីបញ្ជាឱ្យមន្ត្រីពន្ធនាគារទទួលជនត្រូវចោទឃុំខ្លួន។ ការដោះលែងជនជាប់ឃុំវិញបាន លុះត្រាតែមានលិខិតបញ្ជាថ្មីអំពីតុលាការ បើមិនដូច្នោះទេមន្ត្រីពន្ធនាគារពុំមានសិទ្ធិដោះលែងជនជាប់ឃុំបានឡើយ។

## ផ្នែកទី២៖ ដំណើរការ នៃការមិនឃុំខ្លួនបណ្តោះអាសន្ន

ដូចដែលយើងបានដឹងត្រួសៗកន្លងមកហើយថា អ្នកដែលមានសិទ្ធិក្នុងការសម្រេចឱ្យមានការឃុំខ្លួន ឬមិនឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ គឺមានតែចៅក្រមស៊ើបសួរតែម្នាក់ប៉ុណ្ណោះ ដែល

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៦។

អាចមានសិទ្ធិសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ឬមិនឃុំខ្លួនជាបណ្តោះអាសន្ន ឬ/និងដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះជនត្រូវចោទ ហើយការសម្រេចនេះគឺធ្វើឡើងតាមរយៈគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរផ្ទាល់ ឬតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

បើទោះបីជាច្បាប់បានផ្តល់នូវសិទ្ធិអំណាចជូនចៅក្រមស៊ើបសួរយ៉ាងនេះក្តី ក៏ការឃុំខ្លួនជាបណ្តោះ-អាសន្នមិនមែនជាវិធានទូទៅ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការឃុំខ្លួនស្រេចតាមតែអំពើចិត្ត ដោយមិនបានពិនិត្យទៅលើអង្គហេតុ លក្ខណៈសម្បត្តិរបស់ជនត្រូវចោទ និងអង្គច្បាប់ច្បាស់លាស់នោះឡើយ។ កាលណាចៅក្រមស៊ើបសួរចេះតែប្រើនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន ទៅលើជនត្រូវចោទតាមតែអំពើចិត្ត នោះនឹងផ្តល់នូវផលពិបាកយ៉ាងច្រើនចំពោះសិទ្ធិសេរីភាពរបស់ជនត្រូវចោទ និងថវិការបស់រដ្ឋដែលត្រូវចំណាយចំពោះជនត្រូវចោទនៅក្នុងពន្ធនាគារ និងផ្សេងៗទៀត។ ចៅក្រមស៊ើបសួរត្រូវគោរពយ៉ាងម៉ឺងម៉ាត់ចំពោះគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលមានចែងអំពីគោលការណ៍សេរីភាពរបស់ជនត្រូវចោទដែររដ្ឋត្រូវផ្តល់ជូន។

ពេលខ្លះបទល្មើសដែលត្រូវបានចោទជាបទមជ្ឈិម មិនមែនសុទ្ធតែមានលក្ខណៈធ្ងន់ធ្ងរ និងប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈទាំងអស់នោះឡើយ ចំណែកឯទោសទណ្ឌដែលត្រូវដាក់ពន្ធនាគារវិញ បើទោះបីជាបទល្មើសខ្លះមានចាប់ពី ០១(មួយ)ឆ្នាំឡើងទៅមែន ប៉ុន្តែកាលៈទេសៈមិនតម្រូវ ចៅក្រមស៊ើបសួរពុំគួរចាំបាច់ដាក់ឱ្យមាននូវរបបឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើជនត្រូវចោទមានបុគ្គលិកលក្ខណៈមិនសាហាវឃោរឃៅ និងបានផ្តល់ជាប្រយោជន៍ និងធ្លាប់ជួយទៅដល់សង្គមជាតិបានច្រើន នោះចៅក្រមស៊ើបសួរ គួរសិក្សាអំពីគុណសម្បត្តិនេះ និងផលប៉ះពាល់នៅពេលឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ ដោយមិនមែនឱ្យតែមានបទល្មើសអាចឃុំបានចេះតែឃុំតាមតែអំពើចិត្តនោះឡើយ ហើយការឃុំខ្លួននេះ ក៏ត្រូវស្របទៅតាមបញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២០៥ ដែរ។

ផ្ទុយទៅវិញ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរគប្បីធានាឱ្យបាននូវការអនុវត្តតាមគោលការណ៍ ស្តីពីការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់អំពីកាលៈទេសៈ នៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឱ្យបានសមស្រប និងឱ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ដោយដាក់ជនត្រូវចោទឱ្យស្ថិត

នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ។[93] ការអនុវត្តនូវគោលការណ៍ដោយតម្លាភាព នឹងផ្តល់នូវផលចំណេញច្រើន ចំពោះជនត្រូវចោទ និងការអនុវត្តនីតិវិធីរបស់តុលាការ។

## កថាខណ្ឌទី១៖ ដំណាក់កាលព្រះរាជអាជ្ញា

នៅពេលដែលព្រះរាជអាជ្ញាទទួលបន្ទុក នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដែលអង្គការអយ្យការបានចាត់តាំងឱ្យអនុវត្តនីតិវិធីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ ព្រះរាជអាជ្ញាត្រូវពិនិត្យអំពីអង្គហេតុ និងអង្គច្បាប់ដែលបទល្មើសត្រូវបានដាក់ជូនឱ្យអយ្យការពិនិត្យ ឱ្យបានល្អិតល្អន់មុនពេលសម្រេចអំពីការបញ្ជូនសំណុំរឿងឱ្យចៅក្រមស៊ើបសួរ ដើម្បីធ្វើការបើកការស៊ើបសួរ។ ព្រះរាជអាជ្ញាដែលសម្រេចតាមការផ្តួចផ្តើមរបស់ខ្លួនអំពីការមិនឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវស្នើសុំឱ្យចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ ត្រូវបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រង់ចំណុចនៃសេចក្តីសម្រេច ឬស្នើសុំដោយផ្ទាល់មាត់នៅក្នុងការពិភាក្សាដេញដោលតាមរយៈ កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ។[94]

កាលបើការពិនិត្យអំពីអង្គហេតុ នៃបទល្មើសបង្ហាញឱ្យព្រះរាជអាជ្ញាយល់ឃើញថា បទល្មើសដែលត្រូវបានចោទប្រកាន់នោះ ពុំមានលក្ខណៈធ្ងន់ធ្ងរ ជនល្មើសមានលក្ខណៈសម្បត្តិស្លូតបូតដែលការប្រព្រឹត្តបទល្មើសនោះស្ថិតនៅក្នុងស្ថានភាពមួយគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើស ប៉ុន្តែច្បាប់បានចែងថា «អំពើនោះជាបទល្មើស តុលាការបានរក្សា និងចាប់បានភស្តុតាងទាំងអស់ដែលមិនចាំបាច់បារម្ភអំពីការបាត់បង់តម្រុយជនត្រូវចោទ អាចធានាចូលនៅក្នុងនីតិវិធីស៊ើបសួរបាន និងបទល្មើសមិនបណ្តាលឱ្យមានភាពចលាចលនៅក្នុងសង្គម»។ និយាយជារួម នៅពេលដែលជនត្រូវចោទមានលក្ខខណ្ឌផ្ទុយទៅនឹងមូលហេតុអំពីការឃុំខ្លួនជាបណ្តោះអាសន្ន នោះការស្នើសុំពាក់ព័ន្ធ នឹងការឃុំខ្លួនជាបណ្តោះអាសន្នទៅកាន់ចៅក្រមស៊ើបសួរ ពុំមានភាពចាំបាច់ក្នុងការ ស្នើសុំអំពីការឃុំខ្លួននោះឡើយ ដោយដំណោះស្រាយនេះអាចធ្វើឡើងបានដោយការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមរយៈការស្នើសុំរបស់ព្រះរាជអាជ្ញា។[95]

ដោយឡែកចំពោះការសម្រេចពាក់ព័ន្ធនឹងការឃុំ ឬមិនឃុំខ្លួនជនត្រូវចោទ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ។ ដូច្នេះហើយ បានជាយើងត្រូវសិក្សាស្វែងយល់ អំពីនីតិវិធីក្នុងការមិនឃុំខ្លួនបណ្តោះ-

---

[93] សារាចរ ស្តីពី ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ០១ គយសរ/១៤ របស់ក្រសួងយុត្តិធម៌។

[94] នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ៖លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំសិក្សា៖ ឆ្នាំ២០១៣-២០១៤, ទំព័រ ៣៨។

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

អាសន្ននៅក្នុងដំណាក់កាលស្នើសុំរបស់ព្រះរាជអាជ្ញាដូចជា៖ តួនាទី និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា (១) និងសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា (២)។

### ១.១.តួនាទី និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាមានតួនាទីក្នុងការធ្វើសេចក្តីសន្និដ្ឋានស្ថាពរ ដោយធ្វើការសុំទៅដល់ចៅក្រមស៊ើបសួរមិនឱ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន កាលបើយល់ឃើញថាពុំចាំបាច់។ ក្រោយពីចៅក្រមស៊ើបសួរទទួលបាននូវសេចក្តីសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញារួច ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចតាមសេចក្តីន្និដ្ឋានរបស់ព្រះរាជអាជ្ញាក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចប្រើសិទ្ធិអំណាចរបស់ខ្លួនផ្ទាល់ ប្តឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។[96]

### ១.២.សេចក្តីសន្និដ្ឋានស្ថាពរ

សេចក្តីសន្និដ្ឋានស្ថាពរអំពីការមិនឃុំខ្លួនជាបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចសន្និដ្ឋានមួយដែលធ្វើឡើងដោយព្រះរាជអាជ្ញាចំពោះការសម្រេចអំពីការមិនឃុំខ្លួនជាបណ្តោះអាសន្ន ទៅកាន់ចៅក្រមស៊ើបសួរ។ សេចក្តីសន្និដ្ឋានស្ថាពរ របស់ព្រះរាជអាជ្ញានេះ ពុំមានអានុភាពឱ្យចៅក្រមស៊ើបសួរចេញនូវដីកាសម្រេចទៅតាមការសន្និដ្ឋានស្ថាពរអំពីការមិនឃុំខ្លួនជាបណ្តោះអាសន្នរបស់ព្រះរាជអាជ្ញាតែម្តងនោះទេ ចៅក្រមស៊ើប-សួរនៅតែអាចចេញនូវដីកាសម្រេចដែលផ្ទុយពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាបាន។ ប៉ុន្តែក្នុងករណីនេះ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការប្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះ-អាសន្នរបស់ចៅក្រមស៊ើបសួរទៅសភាស៊ើបសួរបាន។

## កថាខណ្ឌទី២៖ ដំណាក់កាលចៅក្រមស៊ើបសួរ

### ២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ

ក្រោយពីចៅក្រមស៊ើបសួរ ទទួលបាននូវសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសម្រេចអំពីការសុំមិនឱ្យចៅក្រមស៊ើបសួរឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ ចៅក្រមស៊ើបសួរ ត្រូវសម្រេចអំពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដោយចេញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន។ តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីនេះ គឺចេញនូវដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ឬមិនឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ។ ចៅក្រមស៊ើបសួរត្រូវសម្រេចអំពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជ-អាជ្ញាអំពីការស្នើសុំមិនឱ្យឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ។ ក្នុងករណីដែលចៅក្រមស៊ើបសួរ មិនបានសម្រេចតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាក្នុងរយៈពេល ០៥

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២០៧។

(ប្រាំ)ថ្ងៃទេ នោះព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការប្តឹងប្រឆាំងទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ទៅកាន់សភាស៊ើបសួរ ដើម្បីសម្រេចជំនួសបាន។

### ២.២. ដីកាសម្រេច

ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ មានអនុភាពអនុវត្តនៅក្នុងដំណាក់កាលស៊ើបសួរ។ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរមានច្រើនប្រភេទ និងច្រើនទម្រង់បែបផែនណាស់ អាស្រ័យទៅតាមស្ថានភាពជាក់-ស្តែង។ ជាឧទាហរណ៍៖ ក្នុងករណីមានបទល្មើសណាមួយបានកើតឡើង ជនត្រូវចោទនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរអាចចេញនូវដីកាបង្គាប់ឱ្យចូលខ្លួន ដើម្បីឱ្យជនត្រូវចោទចូលខ្លួនដោយសន្តិវិធី។ ប៉ុន្តែក្នុងករណីជនត្រូវចោទនៅតែពុំព្រមចូលខ្លួនទេនោះ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យនាំខ្លួនអមជាមួយដីកាបង្គាប់ឱ្យចាប់ខ្លួន ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌នាំខ្លួន និងចាប់ជនត្រូវចោទនោះ ប្រគល់មកឱ្យអង្គការអយ្យការ ដើម្បីដំណើរការនីតិវិធីបន្តបាន។ នៅក្នុងពេលនោះ ចៅក្រមស៊ើបសួរអាចពិចារណាអំពីការឃុំ ឬមិនឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទ ក្នុងករណីដែលចាំបាច់ត្រូវតែឃុំ នោះចៅក្រមស៊ើបសួរអាចចេញនូវដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន។

ប៉ុន្តែទោះបីជាចៅក្រមស៊ើបសួរមានសិទ្ធិអំណាចនៅក្នុងការចេញនូវដីកាសម្រេចបែបនេះ យ៉ាងណាក្តីក៏អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបានផងដែរ។[97]

### កថាខណ្ឌទី៣៖ អានុភាព នៃដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន របស់ចៅក្រមស៊ើបសួរទៅកាន់ជនត្រូវចោទនឹងមានអានុភាពមិនឃុំខ្លួនទៅលើជនត្រូវចោទភ្លាមក្រោយពីចេញនូវដីកាសម្រេច។

## ផ្នែកទី៣៖ ការតាក់តែងដីកាឃុំខ្លួនបណ្តោះអាសន្ន ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

### កថាខណ្ឌទី១៖និយមន័យ ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

### ១.១. និយមន័យ

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរដែលសម្រេចឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ។ ដីកាសម្រេចនេះ មានអានុភាពអាចអនុវត្តឃុំខ្លួនជាបណ្តោះអាសន្នបានភ្លាម បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន អមជាមួយដីកា

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

បង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្នដូចមានកំណត់បន្ថែមនៅក្នុងកថាខណ្ឌទី២ នៃផ្នែកនេះ។ (ចំពោះដីកា-សម្រេចឃុំខ្លួនបណ្ដោះអាសន្នមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១៦ នៃសារណានេះ)

### ១.២. ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ការចេញនូវដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវអនុលោមតាមទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឱ្យបានល្អិតល្អន់ និងហ្មត់ចត់។ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នត្រូវបែងចែកចេញជា ០៣(បី)ផ្នែករួមមាន៖ ដើម នៃដីកា(១.២.១) តួ នៃដីកា(១.២.២) និងបញ្ចប់ នៃដីកា(១.២.៣)។

#### ១.២.១. ដើម នៃដីកា

ដើម នៃដីកា គឺជាផ្នែកដើម ឬដំបូងគេបង្អស់ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយយោងនូវចំណុចមួយចំណុចនៅក្នុងដីកា។ ដើម នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរួមមាន៖

១.ឈ្មោះចៅក្រមស៊ើបសួរទទួលបន្ទុក

២.លេខសំណុំរឿងព្រហ្មទណ្ឌ

៣.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ចៅក្រមស៊ើបសួរដែលទទួលបន្ទុក នៅក្នុងសំណុំរឿងស៊ើបសួរដែលចាត់តាំងដោយប្រធានតុលាការ ត្រូវសរសេរឈ្មោះ និងសមត្ថកិច្ច នៃតុលាការដែលខ្លួនទទួលបន្ទុកនៅខាងផ្នែកដើម នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ បន្ទាប់ពីសរសេរឈ្មោះចៅក្រមស៊ើបសួរដែលទទួលបន្ទុករួច ត្រូវសរសេរនូវលេខសំណុំរឿងព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាបញ្ជូនមកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចុងបញ្ចប់ នៃដើមដីកា គឺត្រូវសរសេរយោងនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាចូលទៅក្នុងដើម នៃដីកា។

#### ១.២.២. តួ នៃដីកា

តួ នៃដីកា គឺជាផ្នែកកណ្ដាល ឬជាផ្នែកយល់ឃើញរបស់ចៅក្រមស៊ើបសួរនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ តួ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរួមមាន៖

១.ឈ្មោះ និងអាសយដ្ឋានរបស់ជនត្រូវចោទ

២.ពង្សាវតា

៣.បទល្មើសដែលត្រូវចោទប្រកាន់ និងទីកន្លែងដែលប្រព្រឹត្ត

### ១.២.៣. បញ្ចប់ នៃដីកា

បញ្ចប់ នៃដីកា គឺជាផ្នែកចុងក្រោយ ឬជាផ្នែកសម្រេច នៃដីកាអំពីការឃុំខ្លួនជាបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ។ ផ្នែកបញ្ចប់ នៃដីកានេះ គឺជាការសម្រេចរបស់ចៅក្រមស៊ើបសួរដោយផ្អែកទៅលើតួ នៃដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន ដោយកំណត់រយៈពេលឃុំខ្លួនទៅលើជនត្រូវចោទទៅតាមលក្ខខណ្ឌកំណត់ដោយច្បាប់។ ចុងបញ្ចប់ នៃដីកាត្រូវមានការចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងត្រារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

## កថាខណ្ឌទី២៖ និយមន័យ ទម្រង់ និងខ្លឹមសារ នៃដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន

### ២.១. និយមន័យ

ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន គឺជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលឃុំជនត្រូវចោទជាបណ្ដោះអាសន្ន។ (ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួន មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១៧ នៃសារណានេះ)។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។[98] បន្ទាប់ពីចៅក្រមស៊ើបសួរចេញនូវដីកាសម្រេច ឱ្យឃុំខ្លួនបណ្ដោះ-អាសន្នរួច ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាសម្រេចមួយទៀត គឺដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ ដីកានេះមានសិទ្ធិ និងអំណាចក្នុងការបញ្ជាទៅដល់កងកម្លាំងសាធារណៈ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំជនត្រូវចោទជាបណ្ដោះអាសន្ន ទៅតាមកាលកំណត់ដូចមាននៅក្នុងសេចក្ដីសម្រេច និងដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន។

### ២.២. ទម្រង់ និងខ្លឹមសារនៃដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ការចេញនូវដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវអនុលោមតាមទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចដែលជាកម្មវត្ថុ នៃការឃុំខ្លួនបណ្ដោះអាសន្នឱ្យបានល្អិតល្អន់ និងហ្មត់ចត់។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបែងចែកចេញជា ០៣(បី)ផ្នែករួមមានដូចតទៅ៖ ដើម នៃដីកា(២.២.១) តួ នៃដីកា(២.២.២) និងបញ្ចប់ នៃដីកា(២.២.៣)។

---

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ២០០៧, មាត្រា ២២០។

### ២.២.១. ដើម នៃដីកា

ដើម នៃដីកា គឺជាផ្នែកដើម ឬដំបូងគេបង្អស់ នៃដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នដោយយោងនូវចំណុចមួយចំនួននៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នមានលក្ខណៈទម្រង់ និងខ្លឹមសារស្រដៀងទៅនឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នដែរ គ្រាន់តែដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នមានលក្ខណៈជាការបង្គាប់ឱ្យកងកម្លាំងសាធារណៈនាំខ្លួន ឬ/និងចាប់ខ្លួនជនត្រូវចោទដែលបានរត់គេចខ្លួន ឬ/និងបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន។

ដើម នៃដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នរួមមាន៖

១.ឈ្មោះចៅក្រមស៊ើបសួរទទួលបន្ទុក

២.លេខសំណុំរឿងព្រហ្មទណ្ឌ

៣.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

៤.ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរដែលទទួលបន្ទុកនៅក្នុងសំណុំរឿងស៊ើបសួរ ដែលចាត់តាំងដោយប្រធានតុលាការត្រូវសរសេរឈ្មោះ និងសមត្ថកិច្ច នៃតុលាការដែលខ្លួនទទួលបន្ទុកនៅក្នុងផ្នែកដើម នៃដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន។ បន្ទាប់ពីសរសេរឈ្មោះចៅក្រមស៊ើបសួរដែលទទួលបន្ទុករួច ត្រូវសរសេរយោងនូវលេខសំណុំរឿងព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាបញ្ជូនមកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បន្ទាប់មកទៀតត្រូវសរសេរយោងនូវដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាចូលទៅក្នុងដើម នៃដីកា។ ចុងបញ្ចប់ នៃដើមដីកា ត្រូវយោងនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលចៅក្រមស៊ើបសួរបានសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន។

### ២.២.២. តួ នៃដីកា

តួ នៃដីកា គឺជាផ្នែកកណ្តាល ឬជាផ្នែកយល់ឃើញរបស់ចៅក្រមស៊ើបសួរនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ តួ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរួមមាន៖

១.ឈ្មោះចៅក្រមស៊ើបសួរទទួលបន្ទុក

២.អត្តសញ្ញាណរបស់ជនត្រូវចោទ

៣.ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ។

### ២.២.៣.បញ្ចប់ នៃដីកា

បញ្ចប់ នៃដីកា គឺជាផ្នែកចុងក្រោយ ឬជាផ្នែកសម្រេច នៃដីកាអំពីការបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន របស់ចៅក្រមស៊ើបសួរទៅកាន់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំជនត្រូវចោទជាបណ្ដោះអាសន្ន។ ផ្នែកបញ្ចប់ នៃដីកានេះ គឺជាការសម្រេចរបស់ចៅក្រមស៊ើបសួរដោយផ្អែកទៅលើតួ នៃដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន។ ចុងបញ្ចប់ នៃដីកាត្រូវមានការចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងត្រារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

## កថាខណ្ឌទី៣៖ និយមន័យ គោលការណ៍នៃទម្រង់ និងខ្លឹមសារ នៃការចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

### ៣.១. និយមន័យ

ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន គឺជាសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរដែលសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្នទៅលើជនត្រូវចោទ។ ដីកាសម្រេចនេះ មានអានុភាពភ្លាមមិនឃុំខ្លួនជាបណ្ដោះ-អាសន្នទៅលើជនត្រូវចោទ បើទោះបីជា សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាស្នើសុំឱ្យឃុំខ្លួនទៅលើជនត្រូវចោទក៏ដោយ។ (ចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១៨ នៃសារណានេះ)។

ការឃុំខ្លួនជាបណ្ដោះអាសន្ននឹងមានអានុភាពវិញ នៅពេលដែលសាលដីការបស់សភាស៊ើបសួរចំពោះពាក្យបណ្ដឹងធ្វើឡើងដោយព្រះរាជអាជ្ញាអំពីការឃុំខ្លួនវិញនោះ។

**ឧទាហរណ៍** ចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន។ តែព្រះរាជអាជ្ញាមិនយល់ស្របចំពោះសេចក្ដីសម្រេចនេះទេ នោះព្រះរាជអាជ្ញា អាចប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន ដើម្បីឱ្យសភាស៊ើបសួរធ្វើនូវសេចក្ដីសម្រេចសារជាថ្មី។ ក្នុងករណីសភាស៊ើបសួរសម្រេចឃុំតាមបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា នោះជនត្រូវចោទអាចត្រូវឃុំខ្លួនវិញបាន។

ផ្អែកតាម មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ ឬលើកលែងការចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។

## ៣.២. ទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

ការចេញនូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវអនុលោមតាមទម្រង់ និងខ្លឹមសារ នៃដីកាសម្រេចឱ្យបានល្អិតល្អន់ និងហ្មត់ចត់។ ការចេញនូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះ-អាសន្នដូចគ្នាទៅនឹង ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នដែរ គ្រាន់តែនៅត្រង់ចំណុចតួដីកាសម្រេចចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីមូលហេតុ នៃការមិនឃុំខ្លួនបណ្ដោះអាសន្ន។ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នត្រូវបែងចែកចេញជា ០៣(បី)ផ្នែកគឺ ដើម នៃដីកា(៣.២.១) តួ នៃដីកា(៣.២.២) និងបញ្ចប់ នៃដីកា(៣.២.៣)។

### ៣.២.១. ដើម នៃដីកា

ដើម នៃដីកា គឺជាផ្នែកដើម ឬដំបូងគេបង្អស់ នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នដោយយោងនូវចំណុចមួយចំណុចនៅក្នុងដីកា។ ដើម នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នរួមមាន៖

១.ឈ្មោះចៅក្រមស៊ើបសួរទទួលបន្ទុក

២.លេខសំណុំរឿងព្រហ្មទណ្ឌ

៣.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ចៅក្រមស៊ើបសួរដែលទទួលបន្ទុកនៅក្នុងសំណុំរឿងស៊ើបសួរ ដែលចាត់តាំងដោយប្រធានតុលាការត្រូវសរសេរឈ្មោះ និងសមត្ថកិច្ច នៃតុលាការដែលខ្លួនទទួលបន្ទុកនៅក្នុងផ្នែកដើម នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ បន្ទាប់ពីសរសេរឈ្មោះចៅក្រមស៊ើបសួរដែលទទួលបន្ទុករួច ត្រូវសរសេរនូវលេខសំណុំរឿងព្រហ្មទណ្ឌដែលព្រះរាជអាជ្ញាបញ្ជូនមកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ចុងបញ្ចប់ នៃដើមដីកា គឺត្រូវសរសេរយោងនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាចូលទៅក្នុងដើមនៃដីកា។

### ៣.២.២. តួ នៃដីកា

តួ នៃដីកា គឺជាផ្នែកកណ្ដាល ឬជាផ្នែកយល់ឃើញរបស់ចៅក្រមស៊ើបសួរនៅក្នុងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ តួ នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នរួមមាន៖

១.ឈ្មោះចៅក្រមស៊ើបសួរទទួលបន្ទុក

២.អត្តសញ្ញាណរបស់ជនត្រូវចោទ

៣.ប្រភេទ នៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

### ៣.២.៣. បញ្ចប់ នៃដីកា

បញ្ចប់នៃដីកា គឺជាផ្នែកចុងក្រោយ ឬជាផ្នែកសម្រេច នៃដីកាអំពីការមិនឃុំខ្លួនជាបណ្ដោះអាសន្ន របស់ចៅក្រមស៊ើបសួរ។ ផ្នែកបញ្ចប់នៃដីកានេះ គឺជាការសម្រេចរបស់ចៅក្រមស៊ើបសួរដោយផ្អែកទៅលើតួនៃដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្ន។ ចុងបញ្ចប់ នៃដីកាត្រូវមានការចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងត្រារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

# ជំពូកទី៣
# បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេច
# របស់ចៅក្រមស៊ើបសួរ

# ជំពូកទី៣
# បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ នីតិវិធីបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ជាការពិតណាស់ ការសម្រេចសេចក្ដីរបស់ចៅក្រមស៊ើបសួរ មិនមែនជាការបិទផ្លូវតវ៉ាទាំងស្រុងនោះទេ។ ហេតុដូចនេះហើយ បានជាគ្រប់ប្រទេសទាំងអស់នៅលើសកលលោកយើងនេះ តែងបង្កើតតុលាការជា ០២(ពីរ)ថ្នាក់ គឺតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់។ ប្រសិនបើតុលាការជាន់ទាបសម្រេចសេចក្ដីដោយមានការភ័ន្តច្រឡំ និងកង្វះខាត តុលាការជាន់ខ្ពស់ គឺជាអ្នកពិនិត្យ និងធ្វើការសម្រេចសេចក្ដីសារជាថ្មី តែប្រសិនបើការសម្រេចសេចក្ដីរបស់តុលាការជាន់ទាបមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ នោះតុលាការជាន់ខ្ពស់អាចតម្កល់សេចក្ដីសម្រេចរបស់តុលាការជាន់ទាបទុកជាធម្មតា។

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជានីតិវិធីមួយ ដែលធ្វើឡើងនៅក្នុងដំណាក់កាល នៃចៅក្រមស៊ើបសួរពោលគឺមុនពេលជំនុំជម្រះក្ដី ហើយការសម្រេចឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ននេះ ធ្វើឡើងតាមរយៈគំនិតផ្ដួចផ្ដើមពីចៅក្រមស៊ើបសួរផ្ទាល់ ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណាទៅលើស្ថានភាព នៃជនត្រូវចោទ ឬលក្ខណៈនៃបទល្មើសនោះ ប៉ុន្តែការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានចំពោះតែបទមជ្ឈិម និងបទឧក្រិដ្ឋដែលច្បាប់ចែងផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំតែប៉ុណ្ណោះ។

### កថាខណ្ឌទី១៖ ដំណើរការ នៃបណ្ដឹងឧទ្ធរណ៍

#### ១.១. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍

នៅពេលប្រកាសសាលដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កាលបើជនត្រូវចោទពុំសុខចិត្តចំពោះដីកាសម្រេចនេះ ជនត្រូវចោទ ត្រូវធ្វើការប្រកាសប្ដឹងនៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ នៅពេលនោះប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវប្រគល់ភ្លាមនូវលិខិតប្ដឹងឧទ្ធរណ៍មួយច្បាប់ ជូនទៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយលិខិតនេះត្រូវបញ្ចូលទៅក្នុងបញ្ជីបណ្ដឹងឧទ្ធរណ៍។ ក្រៅពីនេះ បណ្ដឹងឧទ្ធរណ៍ក៏អាចធ្វើដោយមេធាវីរបស់ជនត្រូវចោទបានផងដែរ។[99]

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៧២។

### ១.២. អ្នកដែលមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចឱ្យមានការឃុំខ្លួនជាបណ្ដោះអាសន្ន ចំពោះជនត្រូវចោទ កាលបើយល់ថា ពុំចាំបាច់នៅក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នទេ នោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញា អាចប្ដឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបាន។[100] ក្រៅពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា ជនត្រូវចោទ ក៏អាចប្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្នបានដូចគ្នា។[101]

### ១.៣. រយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍

បន្ទាប់ពីប្រកាសដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នទៅលើជនត្រូវចោទរួច កាលបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ/និងព្រះរាជអាជ្ញា យល់ថាវាពុំមែនជាមូលដ្ឋានចាំបាច់នៅក្នុងការឃុំខ្លួន ដោយមូលហេតុថា រឿងមានលក្ខណៈគ្រប់គ្រាន់ល្មមនឹងអាចជម្រះបាន នោះអគ្គព្រះរាជអាជ្ញា ឬ/និងព្រះរាជអាជ្ញា ក៏ដូចជាជនត្រូវចោទមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន គ្រាន់តែថិរវេលាដែលអាចធ្វើនូវបណ្ដឹងនេះ គឺមានរយៈពេលផ្សេងៗគ្នា។ ចំពោះថិរវេលា នៃការធ្វើបណ្ដឹងឧទ្ធរណ៍ នឹងដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ក្នុងរយៈពេលយ៉ាងយូរ ០១(មួយ)ខែ គិតចាប់ពីថ្ងៃប្រកាសដីកា។ ដោយឡែកចំពោះ ព្រះរាជអាជ្ញាវិញ គឺមានរយៈពេល ០៥(ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកា ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ។ រីឯជនត្រូវចោទវិញ កាលបើពុំសុខចិត្តចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ នោះជនត្រូវចោទមានសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ននេះ ក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ ដូចគ្នា គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាសម្រេច។[102]

### ១.៤. ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ ទៅសភាស៊ើបសួរ

នៅពេលដែលជនត្រូវចោទ ប្រកាសប្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នោះប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវប្រគល់នូវលិខិតប្ដឹងឧទ្ធរណ៍មួយច្បាប់ ទៅក្រឡាបញ្ជី នៃតុលាការជាន់ដំបូង។ ហើយនៅពេលដែលក្រឡាបញ្ជីបានទទួលនូវបណ្ដឹងឧទ្ធរណ៍រួច ក្រឡាបញ្ជី នៃតុលាការជាន់ដំបូងត្រូវជូនដំណឹងភ្លាមទៅដល់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីបញ្ជូនដំណឹងរួច ក្រឡាបញ្ជី នៃចៅក្រម

---

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៧។

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៧០។

ស៊ើបសួរត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយសេចក្តីចម្លង នៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់មកជាមួយផង។

ចំពោះសេចក្តីចម្លង នៃលិខិតប្តឹងឧទ្ធរណ៍នេះ ត្រូវធ្វើឡើងដោយក្រឡាបញ្ជី នៃតុលាការជាន់ដំបូង ក្រោយពីបានឃើញនិទ្ទេសដែលចុះក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍។ ហើយចំពោះបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងទាំងអស់ ក្រឡាបញ្ជី នៃចៅក្រមស៊ើបសួរ ត្រូវបញ្ជូនទៅការិយាល័យប្រឡាបញ្ជី នៃសភាស៊ើបសួរ នៅក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជំនះបាន។[103]

## កថាខណ្ឌទី២៖ តុលាការដែលមានសមត្ថកិច្ច

### ២.១. សភាស៊ើបសួរ

នៅសាលាឧទ្ធរណ៍ មានសភាមួយដែលមានឈ្មោះថា សភាស៊ើបសួរ។ សភាស៊ើបសួរ មានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ សមាជិក នៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានេះ ត្រូវចាត់ទុកជាមោឃៈ។[104]

សភាស៊ើបសួរ មានសមត្ថកិច្ចធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូង ឬសម្រេចអំពីបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយ នៃនីតិវិធី។

ប្រធានសភាស៊ើបសួរ គឺជាអ្នកផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ឬក៏ត្រូវដាក់ឱ្យមានការស៊ើបសួរបន្ត? បន្ទាប់ពីពិនិត្យ និងផ្ទៀងផ្ទាត់រួច ប្រធានសភាស៊ើបសួរ ត្រូវកំណត់អំពីកាលបរិច្ឆេទបើកសវនាការ។ ពាក់ព័ន្ធនឹងការជូនដំណឹងអំពីកាលបរិច្ឆេទបើកសវនាការនេះ ប្រធានសភាស៊ើបសួរអាចជូនដំណឹងដោយផ្ទាល់មាត់ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។ ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការនេះ បន្តដល់គូភាគី និងដល់មេធាវី។

ដោយឡែកចំពោះនីតិវិធី នៃការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចជូនដំណឹងទៅជនត្រូវចោទដោយផ្ទាល់មាត់ ឬតាមរយៈការឱ្យប្រធានពន្ធនាគារ ឬ

---

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៧៣។

[104] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៥៥។

មណ្ឌលឃុំខ្លួនជូនដំណឹងបន្ត។ ដោយឡែកចំពោះការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចជូនដំណឹងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថបាន។

### ២.១.១. សាលដីការបស់សភាស៊ើបសួរ

បន្ទាប់ពីបើកសវនាការរួច សភាស៊ើបសួរត្រូវធ្វើការកត់សម្គាល់ចំពោះរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីគូភាគី វត្តតាង ក៏ដូចជាចម្លើយរបស់ជនត្រូវចោទ និងក្រោយពិភាក្សាដេញដាលនៅក្នុងបន្ទប់ពិភាក្សារួច សភាស៊ើបសួរត្រូវធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និងមេធាវីឡើយ។ បន្ទាប់ពីពិគ្រោះរួច សភាស៊ើបសួរអាចប្រកាសនូវសាលដីកានោះនៅពេលសវនការអសាធារណៈនៅថ្ងៃនោះ ឬក៏នៅពេលសវនាការលើកក្រោយបាន។

សាលដីការបស់សភាស៊ើបសួរ ត្រូវតែមានសំអាងហេតុច្បាស់លាស់ និងត្រូវតែមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យ។

### ២.១.២. រយៈពេលក្នុងការចេញសាលដីកា

ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន សាលដីការបស់សភាស៊ើបសួរ ត្រូវសម្រេចចេញនៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានសំណុំរឿងនៅការិយាល័យក្រឡាបញ្ជី នៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះ ជនត្រូវចោទ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះជាហេតុមិនអាចឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ នោះការប្រកាសអាចពន្យារពេល ឬលើកទៅពេលក្រោយបាន។[105]

## ផ្នែកទី២៖ នីតិវិធីបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ក្រៅពីការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរក៏អាចសម្រេចឱ្យមានការមិនឃុំខ្លួនជាបណ្តោះអាសន្នបានផងដែរ កាលបើពិនិត្យ និងយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នពុំមែនជាជម្រើសចាំបាច់។ តែក្នុងករណីព្រះរាជអាជ្ញា ពុំសុខចិត្តចំពោះដីកាសម្រេចនេះ ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៧៨។

ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ទៅសភាស៊ើបសួរបាន។[106] (ចំពោះពាក្យបណ្តឹងឧទ្ធរណ៍មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១៩ នៃសារណានេះ)

## កថាខណ្ឌទី១៖ ដំណើរការ នៃបណ្តឹងឧទ្ធរណ៍

### ១.១. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

ចំពោះនីតិវិធី នៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ទៅសភាស៊ើបសួរ មានលក្ខណៈពុំសូវខុសគ្នាប៉ុន្មាននោះទេ នឹងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្ន។ ដោយដំណើរការ នៃការដាក់ពាក្យបណ្តឹងនេះ ព្រះរាជអាជ្ញា ត្រូវដាក់ពាក្យប្តឹងដោយមានសំអាងហេតុ និងមូលហេតុច្បាស់លាស់ ដែលបញ្ជាក់អំពីមូលហេតុចាំបាច់នាំឱ្យត្រូវតែមានការឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទដើម្បីជាមូលដ្ឋានដល់សភាស៊ើបសួរក្នុងការពិចារណាអំពីភាពចាំបាច់នេះ។

### ១.២. អ្នកដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចឱ្យមានការមិនឃុំខ្លួនជាបណ្តោះអាសន្ន ចំពោះជនត្រូវចោទ កាលបើយល់ថា ចាំបាច់ត្រូវតែឃុំខ្លួនជាបណ្តោះអាសន្ន នោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ទៅសភាស៊ើបសួរបាន។[107]

### ១.៣. រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍

បន្ទាប់ពីប្រកាសដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទរួច កាលបើអគ្គព្រះរាជ-អាជ្ញាអមសាលាឧទ្ធរណ៍ ឬ/និងព្រះរាជអាជ្ញា យល់ឃើញថាវាមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ សុខសន្តិភាពសង្គម កាលបើជនត្រូវចោទនៅក្រៅឃុំ នោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ/និងព្រះរាជ-អាជ្ញា មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន គ្រាន់តែថិរវេលាដែលអាចធ្វើនូវបណ្តឹងនេះ គឺមានរយៈពេលខុសគ្នា។

ចំពោះថិរវេលា នៃការធ្វើបណ្តឹងឧទ្ធរណ៍ នឹងដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេលយ៉ាងយូរ ០១ (មួយ)ខែ គិតចាប់ពីថ្ងៃប្រកាសដីកា។ ដោយឡែកចំពោះ ព្រះរាជអាជ្ញាវិញ គឺមានរយៈពេល ០៥(ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកា ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ។

[106] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

ដោយឡែកចំពោះការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ ទៅសភាស៊ើបសួរ ការចេញដីកាសម្រេច និង រយៈពេល នៃការចេញដីកាសម្រេច ពីសភាស៊ើបសួរ គឺមានលក្ខណៈពុំសូវខុសគ្នាប៉ុន្មាននោះទេ ពីដំណើរ ការនីតិវិធី នៃការប្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនជាបណ្តោះអាសន្ន ដូចមានកំណត់ក្នុងជំពូកទី៣ ផ្នែកទី១ នៃ សៀវភៅនេះ។

# ជំពូកទី៤
# បណ្តឹងសាទុក្ខចំពោះ
# សាលដីការបស់សភាស៊ើបសួរ

# ជំពូកទី៤
# បណ្តឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរ

## ផ្នែកទី១៖ នីតិវិធីបណ្តឹងសាទុក្ខចំពោះសាលដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់សភាស៊ើបសួរ

បណ្តឹងសាទុក្ខ គឺជាបណ្តឹងដែលប្តឹងទៅតុលាការកំពូលប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។[108] (ចំពោះគម្រូបណ្តឹងសាទុក្ខមាននៅក្នុងឧបសម្ព័ន្ធទី២០ នៃសារណានេះ)

សាលដីកា នៃសភាស៊ើបសួរ ដោយគិតបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន។[109] នៅពេលដែលសភាស៊ើបសួរបានចេញ សាលដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ សាលដីការបស់សភាស៊ើបសួរនេះ ត្រូវជូនដំណឹងទៅដល់ភាគីដែលពាក់ព័ន្ធដើម្បីទុកសិទ្ធិពួកគេប្តឹងសាទុក្ខចំពោះ សាលដីការបស់សភាស៊ើបសួរដោយគិតចាប់ពីថ្ងៃទទួលលិខិត នៃសាលដីការបស់សភាស៊ើបសួរ។

### កថាខណ្ឌទី១៖ ដំណើរការ នៃបណ្តឹងសាទុក្ខ

#### ១.១. ការដាក់ពាក្យបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខចំពោះសាលដីកា នៃសភាស៊ើបសួរអំពីការឃុំខ្លួនជាបណ្តោះអាសន្នត្រូវធ្វើឡើង នៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជី នៃតុលាការនេះ។[110] ការប្តឹងសាទុក្ខអាចធ្វើឡើងតាមរយៈអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬជនត្រូវចោទផ្ទាល់ ឬអ្នកការពារក្តីឱ្យជនត្រូវចោទ(មេធាវី) តាមរយៈលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ។ (ចំពោះលិខិតប្រគល់សិទ្ធិឱ្យប្តឹង

[108] សន្ធានុក្រម នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី១ មាត្រា ៤១៧។

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី១ មាត្រា ៤២២។

សាទុក្ខមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២១ នៃសារណានេះ) [111]បណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹង ឬអ្នកតំណាង។ កាលណាអ្នកប្តឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬអ្នកតំណាងត្រូវផ្តិតស្នាមម្រាមដៃ។ លិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់ជាមួយនឹងពាក្យសុំប្តឹងសាទុក្ខ។

ប្រសិនបើខ្វះហត្ថលេខារបស់ក្រឡាបញ្ជី ឬខ្វះកាលបរិច្ឆេទ ពាក្យប្តឹងសាទុក្ខអាចទទួលបានប្រសិនបើគ្មានឃើញការបន្លំអ្វីទេ។ ក្រឡាបញ្ជីត្រូវរងទោសពិន័យ ៥,០០០ (ប្រាំពាន់រៀល)។ ប្រាក់ពិន័យនេះត្រូវប្រកាសដោយតុលាការកំពូលនៅក្នុងសាលដីការបស់ខ្លួន។

### ១.២. អ្នកដែលមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

នៅពេលដែលសភាស៊ើបសួរចេញ សាលដីកាសម្រេចដោយតម្កល់ទុកដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរទុកជាបានការដដែល កាលបើយល់ថានៅសាលដីកាដែលសភាស៊ើបសួរដែលសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នមិនត្រឹមត្រូវតាមផ្លូវច្បាប់ នោះបុគ្គលដែលអាចប្តឹងសាទុក្ខចំពោះសាលដីកានោះបានរួមមាន៖

១.អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

២.អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

៣.ជនត្រូវចោទ ឬពិរុទ្ធជន

សេចក្តីសម្រេចរបស់សភាស៊ើបសួរអំពីការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ ត្រូវរក្សាទុកជននោះជាប់ឃុំនៅក្នុងពន្ធនាគារ រហូតដល់មានសេចក្តីសម្រេចអំពីបណ្តឹងសាទុក្ខនោះ។

### ១.៣. រយៈពេលធ្វើបណ្តឹងសាទុក្ខ

ការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលដីកា របស់សភាស៊ើបសួរអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវធ្វើឡើងតាមរយៈពេល ដែលច្បាប់បានកំណត់ជាកំហិត។ ចំពោះបណ្តឹងសាទុក្ខប្តឹងប្រឆាំងនឹងសាលដីការបស់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ។[112] កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវគិតចាប់ពីការប្រកាសសាលដីកា។ ហើយកាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវគិតចាប់ពីពេលឱ្យដំណឹង។

---

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី១ មាត្រា ៤២៣។

[112] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី២ មាត្រា ៤២០។

ដូច្នេះ បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរ ត្រូវដាក់ពាក្យបណ្តឹងសាទុក្ខឱ្យបានមុនក្នុងអំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសាលដីកានោះ នៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍។ ក្នុងករណីដែលបុគ្គលដែលមានសិទ្ធិប្តឹងសាទុក្ខ មិនបានដាក់ពាក្យប្តឹងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដែលច្បាប់កំណត់ នោះបុគ្គលត្រូវបានផុតសិទ្ធិក្នុងការប្តឹងសាទុក្ខ ហើយសាលដីការបស់សភាស៊ើបសួរត្រូវបានចូលជាស្ថាពរ។

### ១.៤. ការបញ្ជូនបណ្តឹងសាទុក្ខ ទៅសភាព្រហ្មទណ្ឌ

ដោយហេតុថាតុលាការកំពូល នៃព្រះរាជាណាចក្រកម្ពុជាពុំមានសភាស៊ើបសួរ ដូច្នេះបណ្តឹងសាទុក្ខដែលធ្វើឡើងនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ ត្រូវរៀបចំបែបបទសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល នៃសភាព្រហ្មទណ្ឌជំនួសវិញក្នុងរយៈពេលដ៏ខ្លី។ [113]

## កថាខណ្ឌទី២៖ តុលាការដែលមានសមត្ថកិច្ច

### ២.១. សភាព្រហ្មទណ្ឌ

សភាព្រហ្មទណ្ឌ នៃតុលាការកំពូល គឺជាផ្នែកមួយនៃតុលាការជាន់ខ្ពស់ដែលទទួលបន្ទុកពិនិត្យទៅលើពាក្យបណ្តឹងសាទុក្ខ ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ។ នៅពេលដែលពាក្យបណ្តឹងសាទុក្ខត្រូវបានទទួលចុះបញ្ជីដោយការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍រួច ក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ត្រូវបញ្ជូនសំណុំរឿងទៅកាន់សភាព្រហ្មទណ្ឌ នៃក្រឡាបញ្ជីតុលាការកំពូល។ នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី នៃសំណុំរឿង នៃពាក្យបណ្តឹងសាទុក្ខនោះ។ ភាគីអាចជ្រើសតាំងមេធាវីឱ្យការពារក្តីឱ្យខ្លួនបានចាប់តាំងពីពេលចុះបញ្ជីសំណុំរឿង ក្នុងរយៈពេលយ៉ាងយូរបំផុតរហូតដល់មុនថ្ងៃបើកសវនាការ ០១(មួយ)ថ្ងៃ។ ភាគីត្រូវបញ្ជូនឈ្មោះមេធាវីរបស់ខ្លួនជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីតុលាការកំពូល។

ក្រឡាបញ្ជីតុលាការកំពូលឱ្យដំណឹងដល់គូភាគីអំពីការចុះបញ្ជី នៃសំណុំរឿង។ ក្នុងរយៈពេល១០(ដប់)ថ្ងៃ។ ក្រោយការជូនដំណឹងនេះ ក្រឡាបញ្ជីឱ្យដំណឹងដល់អ្នកប្តឹងសាទុក្ខថាខ្លួនមានថិរវេលា ២០(ម្ភៃ)ថ្ងៃ ដើម្បីផ្ញើជូនសភាព្រហ្មទណ្ឌតុលាការកំពូល នូវសារណាមួយដែលខ្លួនត្រូវរៀបរាប់អំពីមធ្យោបាយខាងច្បាប់ (ចំពោះលិខិតជូនដំណឹងឱ្យដាក់សារណា មាននៅក្នុងឧបសម្ព័ន្ធទី២២ នៃសារណានេះ)។ នៅក្នុងសារណាដែលអ្នកប្តឹងសាទុក្ខបានដាក់នោះ ត្រូវសរសេរអំពីអង្គហេតុ អង្គច្បាប់ និងសេចក្តីសន្និដ្ឋានចំពោះសាលដីការបស់សភាស៊ើបសួរអំពីការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ដោយលើកនូវអំណះអំណាងផ្លូវ

[113] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤២៥។

ច្បាប់តបនឹងសាលដីកាដែលសម្រេចនោះ។ ប្រសិនបើអ្នកប្ដឹងសាទុក្ខបានជ្រើសតាំងមេធាវី និងបានបញ្ជូនឈ្មោះមេធាវីនេះទៅក្រឡាបញ្ជី នោះការជូនដំណឹងនេះក៏ត្រូវផ្ញើទៅមេធាវីផងដែរ។ ប្រសិនអ្នកប្ដឹងសាទុក្ខបានជូនសារណា ក្រឡាបញ្ជីនឹងឱ្យដំណឹងដល់ភាគីដទៃទៀត និងជាយថាហេតុដល់មេធាវី ដែលមានថិរវេលា ២០(ម្ភៃ)ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកប្ដឹងសាទុក្ខ។ នៅក្នុងសារណាតបរបស់ចុងបណ្ដឹងសាទុក្ខ ត្រូវសរសេរតបប្រឆាំងអំពីសារណារបស់ដើមបណ្ដឹងសាទុក្ខ ដោយលើកនូវអង្គហេតុ អង្គច្បាប់ និងសេចក្ដីសន្និដ្ឋាន។ ការដាក់សារណាអាចត្រូវបានពន្យារពេលបាន ១០(ដប់)ថ្ងៃ ទៀត ដោយការដាក់ពាក្យសុំពីភាគី។

លុះដល់ផុតរយៈពេលដាក់សារណា ប្រធានតុលាការកំពូលត្រូវចាត់ចៅក្រមរបាយការណ៍ម្នាក់ និងបញ្ជូនសំណុំរឿងទៅចៅក្រមនេះ ដោយមានភ្ជាប់សារណាទៅជាមួយផង។ ចៅក្រមរបាយការណ៍ត្រូវសរសេររបាយការណ៍ជាលាយលក្ខណ៍អក្សរដោយត្រូវរៀបរាប់អំពី៖

**-នីតិវិធី និងរឿងហេតុ៖**

ចៅក្រមរបាយការណ៍ត្រូវរៀបរាប់អំពី នីតិវិធីដែលដើមបណ្ដឹងសាទុក្ខបានប្ដឹងសាទុក្ខប្រឆាំងនឹងសាលដីការបស់សភាស៊ើបសួរអំពីការឃុំខ្លួនជាបណ្ដោះអាសន្ន នីតិវិធីរបស់តុលាការជាន់ទាបអំពីការឃុំខ្លួនជាបណ្ដោះអាសន្ន និងរឿងហេតុដូចមាននៅក្នុងសារណារបស់ដើមបណ្ដឹងសាទុក្ខ និងសារណារបស់ចុងបណ្ដឹងសាទុក្ខ។

**-ចំណុចច្បាប់ដែលភាគីបានលើក**

ចៅក្រមរបាយការណ៍ត្រូវរៀបរាប់អំពីសារណារបស់ដើមបណ្ដឹងសាទុក្ខ ដែលដើមបណ្ដឹងសាទុក្ខបានលើកឡើងអំពីអង្គច្បាប់ដែលជាមូលហេតុ នៃការប្ដឹងសាទុក្ខ និងអង្គច្បាប់ដែលលើកឡើងដើម្បីឱ្យតុលាការកំពូលចេញសាលដីកាដោះលែងជនត្រូវចោទឱ្យមានសេរីភាពវិញ។ ចំណែកឯចុងបណ្ដឹងសាទុក្ខវិញចៅក្រមរបាយករណ៍ត្រូវរៀបរាប់អំពីចំណុចដែលចុងបណ្ដឹងសាទុក្ខ បានលើកឡើងអំពីភាពសមស្របតាមផ្លូវច្បាប់នៃសាលដីការបស់សភាស៊ើបសួរ ដែលសម្រេចអំពីការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះជនត្រូវចោទ និងអង្គច្បាប់ប្រឆាំងទៅនឹងសារណារបស់ដើមបណ្ដឹងសាទុក្ខ។

**-ដំណោះស្រាយដែលចៅក្រមរបាយការណ៍ស្នើសុំ**

ចៅក្រមរបាយការណ៍ត្រូវសរសេរអំពីការស្នើសុំរបស់ខ្លួនទៅកាន់ប្រធាន អំពីលទ្ធផល នៃការថ្លឹងថ្លែងរបស់ដើមបណ្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខ ថាគួរចេញសាលដីកាដោយតម្កល់សាលដីការបស់សភាស៊ើបសួរទុកជាបានការ ឬដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន។ របាយការណ៍នេះត្រូវបញ្ចូលទៅក្នុងសំណុំរឿង។

របាយការណ៍របស់ចៅក្រមរបាយការណ៍ ត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីរៀបចំសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរទៅប្រធានសភាព្រហ្មទណ្ឌ។ ប្រធានសភាព្រហ្មទណ្ឌត្រូវកំណត់ពេលដើម្បីសវនាការ និងជូនដំណឹងដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទសវនាការនេះ។

### ២.១.១. សាលដីការបស់សភាព្រហ្មទណ្ឌ

កាលណាសភាព្រហ្មទណ្ឌ ធ្វើការជំនុំជម្រះដោយយល់ឃើញថា ពាក្យបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងសាទុក្ខ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ សភាព្រហ្មទណ្ឌត្រូវចេញសាលដីកាសម្រេចដោះលែង ឬមិនដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ។ ក្នុងករណីដែលសភាព្រហ្មទណ្ឌចេញសាលដីកាសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នោះអគ្គព្រះរាជអាជ្ញាត្រូវធ្វើដីកាបញ្ជូនទៅកាន់ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត (ចំពោះដីកាបញ្ជូនទៅព្រះរាជអាជ្ញាមាននៅក្នុងឧបសម្ព័ន្ធទី២៣ នៃសារណានេះ) និងទៅប្រធានពន្ធនាគារដែលជននោះត្រូវបានឃុំ (ចំពោះគម្រូដីកាបញ្ជូនទៅប្រធានពន្ធនាគារមាននៅក្នុងឧបសម្ព័ន្ធទី២៤ នៃសារណានេះ) ដោយភ្ជាប់ជាមួយដីកាបង្គាប់ឱ្យដោះលែង និងសាលដីកាព្រហ្មទណ្ឌរបស់សភាព្រហ្មទណ្ឌ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចទទួលនូវលិខិតពីតុលាការក្នុងការដោះលែងជនត្រូវចោទនោះ។ សាលដីការបស់តុលាការកំពូលមានអានុភាពអនុវត្តភ្លាម និងមិនអាចប្ដឹងតវ៉ាជំទាស់បានទៀតឡើយ។

### ២.១.២. រយៈពេលក្នុងការចេញសាលដីកា

សភាព្រហ្មទណ្ឌ នៃមហាអយ្យការអមតុលាការកំពូល ត្រូវចេញសាលដីកាសម្រេចអំពីពាក្យបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងសាទុក្ខក្នុងរយៈពេល ០៦(ប្រាំមួយ)ខែ ដោយគិតចាប់ពីថ្ងៃទទួលសំណុំរឿង លើកលែងតែកាលៈទេសៈមិនអាចជំនះបាន។

## ផ្នែកទី២៖នីតិវិធីបណ្ដឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរអំពីការមិនឃុំខ្លួនជាបណ្ដោះអាសន្ន

ក្រោយពីសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ចេញសាលដីកា តម្កល់ដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរចំពោះជនត្រូវចោទទុកជាបានការដដែលនោះ ហើយក្រោយមានការប្ដឹងសាទុក្ខដោយបុគ្គលដែលមានសិទ្ធិប្ដឹង នោះជនត្រូវចោទដែលសភាស៊ើបសួរចេញសាលដីកាសម្រេចមិនឃុំខ្លួននោះ ត្រូវស្ថិតនៅក្រៅឃុំជាបណ្ដោះអាសន្នសិន រង់ចាំនូវសេចក្ដីសម្រេចរបស់តុលាការកំពូលអំពីបណ្ដឹងសាទុក្ខនោះ។

## កថាខណ្ឌទី១៖ ដំណើរការ នៃបណ្ដឹងសាទុក្ខ

### ១.១. ការដាក់ពាក្យបណ្ដឹងសាទុក្ខ

ចំពោះនីតិវិធី នៃការដាក់ពាក្យបណ្ដឹងសាទុក្ខ ទៅសភាព្រហ្មទណ្ឌ មានលក្ខណៈពុំសូវខុសគ្នាប៉ុន្មាននោះទេ នឹងការដាក់ពាក្យបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្ដោះអាសន្ន។ នៅក្នុងនីតិវិធីនេះ បុគ្គលដែលមានសិទ្ធិប្ដឹងសាទុក្ខ ត្រូវចុះហត្ថលេខានៅលើលិខិតបណ្ដឹងសាទុក្ខនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។

### ១.២. អ្នកដែលមានសិទ្ធិធ្វើបណ្ដឹងសាទុក្ខ

ជាការពិតណាស់ នៅក្នុងសាលាដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្នរបស់សភាស៊ើបសួរ ជនត្រូវចោទនឹងមិនប្ដឹងសាទុក្ខចំពោះសាលដីកានោះឡើយ ព្រោះវាជាប្រយោជន៍របស់ជនត្រូវចោទស្រាប់ទៅហើយ។ ដូច្នេះជនដែលមានសិទ្ធិប្ដឹងសាទុក្ខនឹងសាលដីកាអំពីការមិនឃុំខ្លួនជាបណ្ដោះអាសន្នរបស់សភាស៊ើបសួររួមមានដូចតទៅ៖

១.អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

២.អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

### ១.៣. រយៈពេលធ្វើបណ្ដឹងសាទុក្ខ

ការធ្វើបណ្ដឹងសាទុក្ខប្រឆាំង នឹងសាលដីការបស់សភាស៊ើបសួរ អំពីការមិនឃុំខ្លួនជាបណ្ដោះអាសន្នត្រូវអនុវត្តតាមខ្លឹមសារខាងលើដូចគ្នាដែរ ដោយគ្រាន់តែខុសកម្មវត្ថុ នៃការប្ដឹងលើសេចក្ដីសម្រេច ដោយធ្វើឡើងក្នុងរយៈពេលដែលច្បាប់បានកំណត់ជាកំហិត។ ចំពោះបណ្ដឹងសាទុក្ខប្ដឹងប្រឆាំងនឹងសាលដីការបស់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ។[114] កាលណាសាលដីកាដែលប្ដឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវគិតចាប់ពីការប្រកាសសាលដីកា។ ហើយកាលណាសាលដីកាដែលប្ដឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខរយៈពេលត្រូវគិតចាប់ពីពេលជូនដំណឹង។

ដូច្នេះ បុគ្គលដែលអាចធ្វើបណ្ដឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរអំពីការមិនឃុំខ្លួន ត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខឱ្យបានមុនក្នុងអំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសាលដីកានោះ នៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍។ ក្នុងករណីដែលបុគ្គលដែលមានសិទ្ធិប្ដឹងសាទុក្ខ

[114] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, កថាខណ្ឌទី២ មាត្រា ៤២០។

មិនបានដាក់ពាក្យប្តឹងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដែលច្បាប់កំណត់ នោះបុគ្គលនោះត្រូវបានផុតសិទ្ធិក្នុងការប្តឹងសាទុក្ខ ហើយសាលដីការបស់សភាស៊ើបសួរត្រូវបានចូលជាស្ថាពរ។

### ១.៤. ការបញ្ជូនបណ្តឹងសាទុក្ខ ទៅសភាព្រហ្មទណ្ឌ

បណ្តឹងសាទុក្ខអំពីការមិនឃុំខ្លួន ត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ ត្រូវរៀបចំបែបបទសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល នៃសភាព្រហ្មទណ្ឌ ក្នុងរយៈពេលដ៏ខ្លីបំផុត។ [115]

### ១.៥. សាលដីការបស់សភាព្រហ្មទណ្ឌ

កាលណាសភាព្រហ្មទណ្ឌ ធ្វើការជំនុំជម្រះដោយយល់ឃើញថាពាក្យបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ សភាព្រហ្មទណ្ឌត្រូវចេញសាលដីកាសម្រេចដោះលែង (ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌ សម្រេចដោះលែងជនត្រូវចោទនៅក្រៅឃុំ មាននៅក្នុងឧបសម្ព័ន្ធទី ២៥ នៃសារណានេះ) ឬមិនដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ។ ក្នុងករណីដែលសភាព្រហ្មទណ្ឌចេញសាលដីកាសម្រេចតម្កល់សាលដីការបស់សភាស៊ើបសួរទុកជាបានការដដែល នោះជនត្រូវចោទមិនត្រូវបានឃុំខ្លួនឡើយ។ ប៉ុន្តែប្រសិនបើសភាព្រហ្មទណ្ឌចេញសាលដីកាសម្រេចបដិសេធសាលដីការបស់សភាស៊ើបសួរ នោះសភាព្រហ្មទណ្ឌនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ហើយធ្វើដីកាបញ្ជូនទៅកាន់ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត និងទៅប្រធានពន្ធនាគារដែលជននោះត្រូវបានឃុំ ដោយភ្ជាប់ជាមួយដីកាបង្គាប់ឱ្យឃុំខ្លួន និងសាលដីការបស់សភាព្រហ្មទណ្ឌ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចទទួលនូវលិខិតពីតុលាការក្នុងការទទួលឃុំខ្លួនជនត្រូវចោទនោះ។ សាលដីការបស់សភាព្រហ្មទណ្ឌ នៃតុលាការកំពូល គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា និងមានអនុវត្តភ្លាម ពោលប្រសិនបើជនត្រូវចោទកំពុងជាប់ឃុំជាបណ្តោះអាសន្ន ស្រាប់តែសភាព្រហ្មទណ្ឌ នៃតុលាការកំពូលសម្រេចឱ្យដោះលែងនោះជនត្រូវចោទត្រូវបានគេដោះលែងភ្លាម។

#### ១.៥.១. រយៈពេលក្នុងការចេញសាលដីកា

សភាព្រហ្មទណ្ឌ នៃមហាអយ្យការអមតុលាការកំពូល ត្រូវចេញសាលដីកាសម្រេចអំពីពាក្យបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខក្នុងរយៈពេល ០៦(ប្រាំមួយ)ខែ ដោយគិតចាប់ពីថ្ងៃទទួលសំណុំរឿងលើកលែងតែកាលៈទេសៈមិនអាចជំនះបាន។

---

[115] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៤២៥។

# ជំពូកទី៥

# បញ្ហាប្រឈមនានា

# និង

# ដំណោះស្រាយ ក្នុងការអនុវត្ត

# ចំពោះ

# ការឃុំខ្លួនបណ្ដោះអាសន្ន

# ជំពូកទី៥
# បញ្ហាប្រឈមនានា និងដំណោះស្រាយក្នុងការអនុវត្តចំពោះការឃុំខ្លួនបណ្ដោះអាសន្ន

## ផ្នែកទី១៖ បញ្ហាប្រឈម

ទោះបីជានៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ ជាប្រទេសដែលប្រកាន់យកប្រព័ន្ធស៊ីវិលឡ៍ ដោយមានការកំណត់ច្បាប់ជាលាយលក្ខណ៍អក្សរ ក៏ដូចជាមានក្រមនីតិវិធីព្រហ្មទណ្ឌ ដែលកំណត់អំពីដំណើរការនីតិវិធី នៃរឿងក្ដីព្រហ្មទណ្ឌយ៉ាងណាក្ដី ក៏នៅតែមាននូវបញ្ហាប្រឈម និងផលវិបាកនានា នៅក្នុងកំឡុងពេលបំពេញការងារនោះដែរ។ តែទោះបីជាបែបនេះក្ដី ពាក្យចាស់តែងពោលថា មានបញ្ហា តែងមានដំណោះស្រាយ។

ហេតុដូចនេះហើយ បានជានៅក្នុងផ្នែកនេះ យើងបានបែងចែកចេញជា ០៣(បី) កថាខណ្ឌ ដូចតទៅ ៖ ទិដ្ឋភាពជាក់ស្ដែងក្នុងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា (កថាខណ្ឌទី១) ការអនុវត្តនៅក្នុងពន្ធនាគារ (កថាខណ្ឌទី២) និង ដំណោះស្រាយ (កថាខណ្ឌទី៣)។

### កថាខណ្ឌទី១៖ ទិដ្ឋភាពជាក់ស្ដែងក្នុងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា

#### ១.១. អំពីការបណ្ដុះបណ្ដាល

ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាត្រូវស្វែងយល់ឱ្យច្បាស់អំពីបទប្បញ្ញត្តជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងការឃុំខ្លួនជាបណ្ដោះអាសន្ន ដែលជាវិធានការ នៃមធ្យោបាយចុងក្រោយបង្អស់ ដើម្បីធ្វើការឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា គឺជាមនុស្សដូចអ្នកទូទៅដែរ ហើយការកាត់សេចក្ដីក៏មិនត្រឹមត្រូវទាំងស្រុងនោះដែរ។ ហេតុដូចនេះហើយ បានជាតម្រូវឱ្យមានការបង្កើតនូវតុលាការជាន់ខ្ពស់ពីលើសាលាដំបូងរាជធានី-ខេត្ត ដើម្បីធ្វើការត្រួតពិនិត្យអំពីសេចក្ដីសម្រេចរបស់តុលាការជាន់ទាបថា តើពិតជាមានភាពត្រឹមត្រូវ និងតម្លាភាពទៅតាមនីតិវិធីដែរឬទេ? សេចក្ដីសម្រេចខ្លះរបស់ចៅក្រមស៊ើបសួរ និងតាមការស្នើសុំរបស់ព្រះរាជអាជ្ញាអំពីការឃុំខ្លួនបណ្ដោះអាសន្ន ទៅលើជនត្រូវចោទមានភាពមិនសមស្របទៅ នឹងអង្គហេតុ និងអង្គច្បាប់ដែលជាមូលហេតុ នៃការឃុំខ្លួនជាបណ្ដោះអាសន្នដូចមានចែងនៅក្នុងមាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ការសម្រេចដោយពុំបានពិចារណាច្បាស់លាស់ និងល្អិតល្អន់អាចធ្វើឱ្យប៉ះពាល់ និងរំលោភបំពានចំពោះសិទ្ធិរបស់ជនត្រូវចោទយ៉ាងខ្លាំង។

ដូច្នេះ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាគួរពិចារណា និងទទួលបាននូវការបណ្តុះបណ្តាលយល់ដឹងឱ្យស៊ីជម្រៅបន្ថែមអំពីបទប្បញ្ញត្តិជាតិ និងអន្តរជាតិ ជាមុនសិនមុននឹងឈានដល់ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ។

### ១.២. អំពើពុករលួយ

ជាការពិតណាស់ អំពើពុករលួយតែងកើតមាននៅគ្រប់ប្រទេសនៅលើសកលលោកយើងនេះ។ ចំណែកឯការអនុវត្តនីតិវិធីចំពោះការឃុំខ្លួនបណ្តោះអាសន្នទៅកាន់ជនត្រូវចោទ របស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញានៅប្រទេសកម្ពុជានៅមានចន្លោះខ្វះខាតមួយចំនួន។ ការចេញដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទ ដោយផ្អែកលើបញ្ហាស៊ីសំណូកសូកប៉ាន់របស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា គឺជាកត្តាមួយដែលធ្វើឱ្យបទល្មើសមានការកើនឡើង ជាថ្មីបន្ថែមទៀត ជាហេតុបង្កឱ្យមានភាពវឹកវរនៅក្នុងសង្គម។ ដូច្នេះ ចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងផ្លូវកណ្តាល និងមិនលំអៀងដោយផ្អែកលើ ភេទ ពណ៌ សម្បុរ ឬនិន្នាការនយោបាយឡើយ។

### ១.៣. ការចុះទៅអនុវត្តផ្ទាល់របស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា

ការអនុវត្តនូវនីតិវិធីដែលទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ គឺជារឿងចាំបាច់ណាស់ដែលតម្រូវឱ្យមានការចូលរួមសហការរវាងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក្នុងការចុះទៅអនុវត្តផ្ទាល់ចំពោះបទល្មើស។ ការមិនចុះទៅអនុវត្តផ្ទាល់ចំពោះបទល្មើសរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាផ្ទាល់ គឺនាំឱ្យមានផលវិបាកច្រើនពាក់ព័ន្ធនឹងរបាយការណ៍ និងកំណត់ហេតុ ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌មួយចំនួន។ របាយការណ៍ និង កំណត់ហេតុដែលមិនតម្លាភាព មិនឆ្លុះបញ្ចាំងអំពីនីត្យានុកូលភាព និងអំពើពុករលួយជាយថាហេតុ អាចធ្វើឱ្យរំលោភបំពានចំពោះសិទ្ធិរបស់ជនត្រូវចោទ ឬធ្វើឱ្យប៉ះពាល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីជាដើម ព្រោះដោយយល់ឃើញថាការអនុវត្តនូវនីតិវិធី និងចំណេះដឹងរបស់មន្ត្រីនគរបាលមួយចំនួននៅមានចន្លោះខ្វះខាត ដែលជាហេតុតម្រូវឱ្យមានការចុះទៅពិនិត្យផ្ទាល់របស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា។

ចំពោះការចេញដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នវិញ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាត្រូវយល់ដឹងអំពីស្ថានភាពជាក់ស្តែងនៅក្នុងពន្ធនាគារ ហើយដើម្បីធានាថាចៅក្រមបានដឹងពីផលប៉ះពាល់របស់របស់ជនជាប់ឃុំ និងសុខភាពសាធារណៈ ផលវិបាក នៃការកកស្ទះពន្ធនាគារ និងកង្វះធនធានជាដើមនោះ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា គប្បីត្រូវមានការតម្រូវឱ្យចុះទៅសួរសុខទុក្ខ និងពិនិត្យអំពីស្ថានភាពក្នុងពន្ធនាគារឱ្យបានញឹកញាប់ យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ដើម្បីសង្កេតមើលលក្ខណៈ និងស្ថានភាពជាក់ស្តែងនៅក្នុងពន្ធនាគារដែលជននោះត្រូវបានឃុំខ្លួន។ ការណ៍ដែលតម្រូវឱ្យចៅក្រម និង

ព្រះរាជអាជ្ញាឧស្សាហ៍ចុះទៅញឹកញាប់ដូចនេះ គឺដើម្បីពញ្ញាក់ស្មារតីរបស់ពួកគាត់ឱ្យបានដឹង និងយល់អំពីស្ថានភាពជាក់ស្ដែងនៅក្នុងពន្ធនាគារ មុននឹងធ្វើសេចក្ដីសម្រេចឃុំខ្លួន ជនត្រូវចោទដែលមិនមែនជាមូលដ្ឋានចាំបាច់ដែរត្រូវតែឃុំ។

### កថាខណ្ឌទី២៖ ការអនុវត្តនៅក្នុងពន្ធនាគារ

#### ២.១. ការប្រើប្រាស់ហិង្សា និងទារុណកម្ម

សិទ្ធិទទួលបានការការពារអំពីការធ្វើទារុណកម្ម គឺជាបញ្ហាប្រឈមមួយដែលត្រូវយកមកពិចារណានៅក្នុងនីតិវិធីឃុំខ្លួនបណ្ដោះអាសន្ន។ ការអនុវត្តរបស់មន្ត្រីទទួលបន្ទុកនៅក្នុងពន្ធនាគារមួយចំនួន ពុំបានអនុវត្តទៅតាមច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងការការពារសិទ្ធិរបស់ជនជាប់ឃុំនោះឡើយ។

ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាពការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូបអាហារ ការដាក់ទណ្ឌកម្មជាសមូហភាពដល់ជនជាប់ឃុំ និងការប្រើប្រាស់ជនជាប់ឃុំឱ្យធ្វើទារុណកម្មជនជាប់ឃុំដូចគ្នាត្រូវហាមឃាត់[116] ប៉ុន្តែយើងសង្កេតឃើញថាការអនុវត្តជាក់ស្ដែង របស់មន្ត្រីនៅពន្ធនាគារនៅមានភាពខ្វះខាតមួយចំនួន ទៅលើការគ្រប់គ្រងការធ្វើទារុណកម្ម ឬហិង្សាទៅលើអ្នកជាប់ឃុំ និងការធ្វើទារុណកម្ម ឬហិង្សារវាងអ្នកជាប់ឃុំដូចគ្នានៅឡើយ។

**ឧទាហរណ៍៖** ការធ្វើទារុណកម្មឱ្យធ្វើការងារលើសកំណត់នៅក្នុងពន្ធនាគារ និងការប្រើប្រាស់ហិង្សាដោយវាយនឹងលើជនជាប់ឃុំជាដើម។

#### ២.២. សិទ្ធិទទួលបានដំណឹង

សិទ្ធិទទួលបានដំណឹង គឺជាភាពចាំបាច់ណាស់របស់ជនជាប់ឃុំដែលត្រូវទទួលបានដំណឹងពាក់ព័ន្ធទៅនឹងលិខិតរបស់តុលាការ និងសិទ្ធិទទួលបានដំណឹងអំពីមេធាវីរបស់ខ្លួនដោយពុំមានការជ្រៀតជ្រែកពីសំណាក់មន្ត្រីពន្ធនាគារ។ មន្ត្រីពន្ធនាគារត្រូវជូនដំណឹងឱ្យបានទៀងទាត់ និងរហ័សអំពីការផ្ដល់ដំណឹងទៅកាន់ជនជាប់ឃុំ និងការផ្ដល់ដំណឹង ឬការដាក់ពាក្យបណ្ដឹងតវ៉ាណាមួយដែលកើតចេញពីឆន្ទៈរបស់ជនជាប់ឃុំទៅកាន់តុលាការដែលមានសមត្ថកិច្ច តាមរយៈមេធាវី ញាតិ និងគ្រួសារ។ ភាពយឺតយ៉ាវក្នុងការជូនដំណឹងដល់ជនជាប់ឃុំ គឺធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកជាប់ឃុំ។

#### ២.៣. សិទ្ធិទទួលបានមេធាវីការពារក្ដី

ការទទួលបានមេធាវី មិនត្រឹមតែជាការការពារដ៏សំខាន់សម្រាប់ការកាត់ក្ដីប្រកបដោយភាពយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការការពារការរំលោភបំពាននូវសិទ្ធិមួយចំនួនដែលអនុវត្តនៅក្នុងពន្ធនាគារផងដែរ។

---

[116] ច្បាប់ស្ដីពីពន្ធនាគារ, នស/រកម/១២១១/០២១, មាត្រា ៥៣។

ទោះយ៉ាងនេះក្តី ដើម្បីឱ្យការការពារនេះមានប្រសិទ្ធភាព អ្នកជាប់ឃុំបណ្តោះអាសន្នត្រូវមានលទ្ធភាពប្រាស្រ័យទាក់ទង និងបង្ហាញជម្រើសរបស់ពួកគេផ្ទាល់ក្នុងការសុំជំនួយផ្នែកច្បាប់ ឬស្វែងរកមេធាវីដោយខ្លួនឯង។ ប៉ុន្តែសំណួរសួរថាប្រសិនបើជនជាប់ឃុំពុំមានលទ្ធភាពក្នុងការជួលមេធាវី ក្នុងការប្រឹក្សាតាមផ្លូវច្បាប់ដើម្បីការពារប្រយោជន៍របស់ជននោះ តើយុត្តិធម៌នឹងមានចំពោះគាត់ទេ? ដូច្នេះហើយបានជាប្រធានតុលាការត្រូវពិនិត្យឱ្យបានល្អិតល្អន់លទ្ធភាពមធ្យោបាយរបស់ជនជាប់ឃុំ នៅក្នុងដំណាក់កាលឃុំខ្លួនជាបណ្តោះអាសន្ននេះ ដើម្បីចាត់តាំងនូវមេធាវីក្នុងការការពារនូវសិទ្ធិ[117]ចំពោះជនត្រូវចោទក្នុងករណីដែលជនជាប់ឃុំ ពុំមានលទ្ធភាពគ្រាប់គ្រាន់ក្នុងការជួលនូវមេធាវីដើម្បីការពារក្តីនៅក្នុងសំណុំរឿង។

យើងសង្កេតឃើញថា ការមិនទទួលបានការការពារពីមេធាវី ដោយឥតគិតថ្លៃចំពោះជនជាប់ឃុំដែលពុំមានលទ្ធភាព នោះផលវិបាក នឹងកើតមានឡើងដូចជាការរំលោភបំពានណាមួយដែលកើតមាននៅក្នុងពន្ធនាគារ ការរំលោភបំពានអំពីការអាក់ខានក្នុងការទទួលបានដំណឹងណាមួយពីតុលាការ សាច់ញាតិ ឬក្រុមគ្រួសារ និងការអាក់ខាននូវការយល់ដឹងអំពីសិទ្ធិរបស់ជនជាប់ឃុំ ក្នុងការធ្វើបណ្តឹងណាមួយ។ល។ ដូច្នេះហើយ ការជួយសម្រួលរបស់ប្រធានតុលាការដែលមានសមត្ថកិច្ច និងការសហការរបស់ប្រធានពន្ធនាគារពិតជាសំខាន់ណាស់ក្នុងការស្វែងរកមេធាវីដើម្បីការពារក្តីឱ្យជនជាប់ឃុំ។

បើទោះបីជាជនត្រូវចោទបានទទួលមេធាវីការពារក្តីឱ្យជនក្រីក្រ ដែលការពារសិទ្ធិជនត្រូវចោទដោយឥតគិតថ្លៃយ៉ាងណាក្តី ក៏មានមេធាវីស្ម័គ្រចិត្តមួយចំនួន ពុំបានសិក្សាអំពីអង្គហេតុ និងអង្គច្បាប់ដើម្បីការពារក្តីជូនកូនក្តីខ្លួនឱ្យអស់ពីលទ្ធភាពនោះដែរ ជាហេតុធ្វើឱ្យជនត្រូវចោទបាត់បង់នូវសិទ្ធិ និងខាតប្រយោជន៍មួយចំនួនរបស់ខ្លួន។ ដូចនេះគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា គួរសិក្សាអំពីបញ្ហានេះ នឹងចំណុចនេះដើម្បីឱ្យមេធាវីដែលស្ម័គ្រចិត្តចូលមកការពារក្តីដោយឥតគិតថ្លៃនោះ បំពេញភារៈកិច្ចឱ្យអស់ពីលទ្ធភាព។ តែយ៉ាងណា យើងក៏សូមថ្លែងអំណរគុណដល់មេធាវីស្ម័គ្រចិត្តជាច្រើនទៀត ដែលបានចំណាយពេលវេលាកម្លាំងកាយ និងកម្លាំងចិត្តការពារកូនក្តីរបស់ខ្លួន ដោយអស់ពីសមត្ថភាព បើទោះបីជាបានក្នុងកម្រិតថវិកាតិចតួចក្នុងការការពារក្តីនេះយ៉ាងណាក្តី។

### កថាខណ្ឌទី៣៖ ដំណោះស្រាយ

តាមន័យជាសាមញ្ញ មានហេតុ តែងមានផល មានទុក្ខ តែងមានដំណោះស្រាយ ថ្វីបើបញ្ហាប្រឈមត្រួសៗដូចបានរៀបរាប់ខាងលើនេះ ជាកំសោយ និងមានផលវិបាកយ៉ាងណាក្តី ក៏គង់តែមាន

[117] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១១ សីហា ឆ្នាំ២០០៧, មាត្រា ៣០១ កថាខណ្ឌទី២។

ដំណោះស្រាយ ដែលអាចដោះស្រាយនូវបញ្ហាទាំងអស់នេះបាន ថ្វីបើវាមិនទាំងស្រុង ក៏ប្រសើរជាងទុកវាចោលដែរ។

ហេតុដូចនេះហើយ យើងសូមលើកយកនូវដំណោះស្រាយសំខាន់ៗ ចំនួន ០២(ពីរ) រួមមាន៖ ការអនុវត្តនីតិវីធីរបស់ចៅក្រមស៊ើបសួរ (១.១) និងការអនុវត្តនៅក្នុងពន្ធនាគារ (១.២)។

## ៣.១. ការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា

### ៣.១.១. ការពង្រឹងច្បាប់

ការពង្រឹងច្បាប់ក្នុងការអនុវត្តនូវវិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញា គឺជាផ្នែកមួយ នៃដំណោះស្រាយមិនត្រឹមតែនៅក្នុងនីតិវិធីឃុំខ្លួនបណ្តោះអាសន្នប៉ុណ្ណោះទេ ថែមទាំងជាដំណោះស្រាយដ៏ល្អប្រសើរសម្រាប់នីតិវិធី នៃសំណុំរឿងក្តីទាំងមូលផងដែរ។ ការពង្រឹងច្បាប់នៅត្រង់នេះ សំដៅទៅដល់ការចូលរួមត្រួតពិនិត្យឱ្យបានហ្មត់ចត់អំពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដោយមានការចូលរួមសហការជាមួយក្រសួងពាក់ព័ន្ធនានា ដូចជាស្ថាប័នប្រឆាំងអំពើពុករលួយ នៅក្នុងនីតិវិធីអនុវត្តរបស់ចៅក្រម និងព្រះរាជអាជ្ញាឱ្យចៅក្រម និងព្រះរាជអាជ្ញាអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដោយប្រើប្រាស់នូវឆន្ទៈ ឯករាជ្យភាព ភាពស្អាតស្អំ និងសេចក្តីថ្លៃថ្នូរនៅក្នុងការអនុវត្តនូវវិជ្ជាជីវៈរបស់ខ្លួន។ ភាពមិនប្រក្រតីក្នុងការអនុវត្តនីតិវិធីរបស់ចៅក្រម និងព្រះរាជអាជ្ញា ដែលជាពិសេសនៅក្នុងនីតិវិធីឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនត្រូវចោទ ដោយផ្អែកទៅលើអំពើពុករលួយ ការឃោគយល់ ឬកត្តាផ្សេងៗទៀតដែលខុសនឹងច្បាប់ ត្រូវតែមានវិធានការចាត់ការទៅតាមនីតិវិធីផ្លូវច្បាប់ឱ្យបានរហ័សដោយឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ស្ថាប័នតុលាការក្នុងការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌដែលចៅក្រម និងព្រះរាជអាជ្ញាបានប្រព្រឹត្តនូវបទល្មើសនោះ និងការចូលរួមអំពីការពិចារណារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បន្ថែមពីនេះ ការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ចៅក្រម និងព្រះរាជអាជ្ញាត្រូវមានការពង្រឹងការអនុវត្តនូវទណ្ឌកម្មផ្នែកវិន័យ និងទណ្ឌកម្មផ្លូវច្បាប់ឱ្យមានកម្រិតកាន់តែខ្លាំងចំពោះការអនុវត្តនីតិវិធីដោយប្រហែសបែបនេះ ដោយហេតុថាការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ មិនមែនជាវិធានទូទៅសម្រាប់ចៅក្រមចេះតែឃុំខ្លួនជនត្រូវចោទនោះឡើយ ពោល គឺវិធាននេះអាចអនុវត្តចំពោះតែពេលដែលពុំអាចមានដំណោះស្រាយ និងអស់ជម្រើសតែប៉ុណ្ណោះ ព្រោះការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទមិនសមហេតុសមផលគឺពិតជាធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិ និងសេរីភាពរបស់ជនត្រូវចោទយ៉ាងខ្លាំង។

### ៣.១.២. ការបញ្ជូនរឿងទៅជំនុំជម្រះភ្លាម

កន្លងមកសំណុំរឿងព្រហ្មទណ្ឌភាគច្រើន តែងមានការកកស្ទះនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានផ្ញើលិខិត

មួយច្បាប់ទៅប្រធានសាលាដំបូងរាជធានីខេត្ត និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្ត ក្នុងគោលបំណងពន្លឿនរកយុត្តិធម៌ឱ្យបានឆាប់រហ័ស ព្រមទាំងលើកម្ពស់សមត្ថភាពស្ថាប័នតុលាការក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ ក៏ដូចជាចូលរួមកាត់បន្ថយការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងកាត់បន្ថយការចង្អៀតណែនក្នុងពន្ធនាគារ។

នៅក្នុងការបញ្ជៀសអំពីបញ្ហាទាំងអស់នេះ ឯកឧត្តមបានផ្តល់ជាអនុសាសន៍ថា «ក្នុងមាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិធីចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌរួមមាន៖ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាម។ ដូចនេះ ជាដំណោះស្រាយកុំឱ្យមានការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងការចង្អៀតណែនពន្ធនាគារ អយ្យការអមសាលាដំបូងរាជធានី-ខេត្តទាំងអស់ គប្បីយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការផ្តល់អាទិភាពប្រើវិធីចោទប្រកាន់ចំពោះបទមជ្ឈិម តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ការបង្ហាញខ្លួនភ្លាម ដោយផ្អែកតាមអង្គហេតុ នៅក្នុងសំណុំរឿងនីមួយៗ និងផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះ ការដាក់ឱ្យស្ថិតនៅក្នុងរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ជាជម្រើសមួយដែលអយ្យការគួរតែមានការយកមកពិចារណាជាជាងបង្កើតឱ្យមានជម្រើសតែមួយគត់គឺការឃុំខ្លួនជាបណ្តោះអាសន្ន»។[118]

### ៣.១.៣. ការដាក់ទណ្ឌកម្ម

នៅពេលដែលចៅក្រម និងព្រះរាជអាជ្ញាមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមវិជ្ជាជីវៈ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញាទេ[119] នោះស្ថាប័នដែលមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មខាងវិន័យ និងបទល្មើសព្រហ្មទណ្ឌដែលចៅក្រម និងព្រះរាជអាជ្ញាបានប្រព្រឹត្តគួរមានការដាក់ទណ្ឌកម្មឱ្យកាន់តែធ្ងន់ជាងទណ្ឌកម្ម និងទោសដូចមានចែងនៅក្នុងច្បាប់បច្ចុប្បន្ន។

ចំពោះទណ្ឌកម្មខាងវិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញាដែលអនុវត្តនីតិវិធីឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទដោយធ្វេសប្រហែស ច្បាប់គួរអនុវត្តវិធានការដាក់ទណ្ឌកម្ម ខាងវិន័យដល់ចៅក្រមដូចជា៖ ផ្អាកការបំពេញវិជ្ជាជីវៈរបស់ពួកគាត់ក្នុងរយៈពេលសមរម្យណាមួយ ហើយផ្តល់នូវការបណ្តុះបណ្តាលបន្ថែមដល់ពួកគាត់ ព្រមទាំងបញ្ញត្តិអំពីសំណង នៃការខូចខាតចំពោះជនត្រូវចោទទៅតាមព្យសនកម្មជាក់ស្តែង ដែលជននោះបានទទួលរងនៅក្នុងអំឡុងពេលឃុំខ្លួនបណ្តោះអាសន្ន។

[118] https://www.postkhmer.com

[119] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា លេខៈ នស/រកម/០៧១៤/០១៦, មាត្រា ៥៤។

ចំណែកឯ ទណ្ឌកម្មចោទចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវចោទចំពោះចៅក្រម និងព្រះរាជអាជ្ញាដែលស៊ីសំណូកវិញ ដូចដែលមានចែងនៅក្នុងមាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌ គឺផ្តន្ទាទោសចាប់ពី ០៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ។ ប៉ុន្តែការដាក់ទោសក្នុងរយៈពេល ០៧(ប្រាំពីរ)ឆ្នាំ ដល់ ១៥(ដប់ប្រាំ)ឆ្នាំ គឺមានលក្ខណៈមិនធ្ងន់ធ្ងរសម្រាប់ចៅក្រម ឬព្រះរាជអាជ្ញាដែលប្រព្រឹត្តអំពើពុករលួយនេះឡើយ។ ប្រសិនបើយើងក្រឡេកមើលច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសបារាំងវិញ គឺអនុវត្តចាប់ពី ១០(ដប់)ឆ្នាំឡើងទៅ ចំពោះការប្រព្រឹត្តអំពើពុករលួយនេះ។ ការដោះលែងជនជាប់ឃុំដោយមានលក្ខខណ្ឌ នៃការស៊ីសំណូក ឬឃុំខ្លួនដោយផ្អែកលើការលក្ខខណ្ឌខុសច្បាប់ណាមួយ នាំឱ្យមានភាពអស្ថេរភាពនៅក្នុងសង្គម និងកំណើន នៃបទល្មើសកាន់តែកើនច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះច្បាប់ត្រូវដាក់ទោសឱ្យធ្ងន់ចំពោះចៅក្រម និងព្រះរាជអាជ្ញាដែលឃុំខ្លួន ឬដោះលែងជនជាប់ឃុំដោយប្រព្រឹត្តអំពើស៊ីសំណូកស៊ូកប៉ាន់នោះ។ អ្វីដែលរឹតតែគួរឱ្យចាប់អារម្មណ៍ចំពោះបទល្មើស និងទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនោះ គឺចែងអំពីបទស៊ីសំណូក[120] និងបទស៊ូកប៉ាន់[121]។ ប៉ុន្តែនៅក្នុងការចែងចំពោះបទល្មើសបែបនេះ យើងយល់ឃើញថាកាលបើដាក់ទោសចំពោះជនទាំងសងខាង នឹងផ្តល់នូវផលវិបាកមួយចំនួន ដូចជាការជួយលាក់បាំងចំពោះបទល្មើសប្រព្រឹត្តជាដើមរវាងចៅក្រម ព្រះរាជអាជ្ញា និងជនស៊ូកប៉ាន់ ព្រោះច្បាប់បានចែងអំពីទោសដែលត្រូវអនុវត្តចំពោះជនទាំងសងខាង។ ប្រសិនបើច្បាប់ព្រហ្មទណ្ឌចែងតែអំពីបទល្មើសស៊ីសំណូកដែលប្រព្រឹត្តដោយចៅក្រម ហើយមិនបានចែងអំពីបទល្មើសស៊ូកប៉ាន់វិញ នោះការអនុវត្តរបស់ចៅក្រម និងព្រះរាជអាជ្ញានឹងកាន់តែមានតម្លាភាព និងប្រសិទ្ធិភាពជាងមុន។

## ៣.២. ការអនុវត្តនៅក្នុងពន្ធនាគារ

### ៣.២.១. ការពង្រឹងច្បាប់

ការពង្រឹងឱ្យមានការអនុវត្តច្បាប់នៅក្នុងពន្ធនាគារដែលជនជាប់ឃុំស្ថិតនៅ គឺជាការចាំបាច់ក្នុងការយកចិត្តទុកដាក់ និងការពារនូវសិទ្ធិរបស់ជនជាប់ឃុំដែលត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ដូចដែលយើងបានដឹងមកហើយអំពីគោលការណ៍សេរីភាពរបស់ជនត្រូវចោទ មិនត្រូវបានឃុំខ្លួនស្រេចតែអំណាចរបស់ចៅក្រមស៊ើបសួរនោះឡើយ លើកលែងតែ គ្មានដំណោះស្រាយអ្វីក្រៅពីការឃុំខ្លួនជាបណ្តោះអាសន្ន ដែលគេធ្វើឡើងដើម្បីការពារនូវសណ្តាប់ធ្នាប់សាធារណៈ រក្សាភស្តុតាង ជួយសម្រួលដល់នីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងផ្សេងៗទៀត។ ការឃុំខ្លួនបណ្តោះអាសន្នបានធ្វើឱ្យ

[120] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៩៤។

[121] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦០៥។

ជនត្រូវចោទបាត់បង់នូវសេរីភាពមួយទៅហើយ ប៉ុន្តែការដកហូតនូវសេរីភាពរបស់ជនត្រូវចោទនេះជាលក្ខខណ្ឌនីត្យានុកូលភាពដែលតម្រូវឱ្យធ្វើការឃុំខ្លួនជននោះជាបណ្តោះអាសន្ន។ ដូច្នេះហើយបានជាច្បាប់ត្រូវឱ្យមានវិធានការយ៉ាងតឹងរឹង ដើម្បីការពារនូវសិទ្ធិរបស់ជនជាប់ឃុំនោះឱ្យបានល្អ ជៀសវាងនូវការរំលោភបំពាននូវសិទ្ធិរបស់ពួកគាត់ដែលនៅជាប់ឃុំ ការផ្គត់ផ្គង់នូវម្ហូបអាហារឱ្យបានសមរម្យ មជ្ឈដ្ឋានរស់នៅក្នុងពន្ធនាគារសមរម្យ និងមានមន្ត្រីពេទ្យពន្ធនាគារ[122]ក្នុងការពិនិត្យតាមដានសុខភាពរបស់ជនជាប់ឃុំនៅពេលឈឺស្កាត់ណាមួយកើតឡើង។

### ៣.២.២. ការដាក់ទណ្ឌកម្ម

ជនដែលជាប់ឃុំ ត្រូវបានគាំពារនូវសិទ្ធិ និងសេរីភាពរបស់ពួកគេ តាមរយៈការបណ្តុះបណ្តាល ការអប់រំ និងស្តារនីតិសម្បទារបស់ពួកគាត់ឱ្យចូលរស់នៅក្នុងសង្គមវិញ ដើម្បីក្លាយជាពលរដ្ឋល្អ។ ដូច្នេះអំពើអមនុស្សធម៌ អំពើរំលោភបំពាន អំពើឃុំខ្លួនខុសច្បាប់ ឬអំពើស៊ីសំណូកផ្សេងៗទៀត ដែលកើតមាននៅក្នុងពន្ធនាគារត្រូវមានវិធានការដោះស្រាយឱ្យបានឆាប់រហ័ស។ ក្រសួងមហាផ្ទៃដែលជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងពន្ធនាគារ ដែលមានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិកាឱ្យក្រសួងមហាផ្ទៃ ត្រូវពិនិត្យចំពោះសកម្មភាពរបស់មន្ត្រីពន្ធនាគារនូវចំណេះដឹង និងសីលធម៌ក្នុងការគ្រប់គ្រងជនជាប់ឃុំនៅក្នុងពន្ធនាគារ។ ការអនុវត្តខុសច្បាប់របស់មន្ត្រីពន្ធនាគារ និងមន្ត្រីពាក់ព័ន្ធត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីពន្ធនាគារ និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

[122] មន្ត្រីពេទ្យពន្ធនាគារ គឺជាសំដៅដល់មន្ត្រី ដែលត្រូវបានតែងតាំងឱ្យផ្តល់សេវាថែរទាំសុខភាពជនជាប់ឃុំនៅក្នុងពន្ធនាគារ និងត្រូវបានទទួលស្គាល់ ឬត្រូវចុះបញ្ជីជាគ្រូពេទ្យ ឬមន្ត្រីពេទ្យនៅក្រសួងសុខាភិបាល។ (យោងតាម ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៤)។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវ និងសរសេរចងក្រងនូវសារណាដែលមានប្រធានបទស្តីពី "**ការឃុំខ្លួនបណ្តោះអាសន្ន**" រួចហើយ យើងអាចធ្វើការយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅអំពីនីតិវិធីក្នុងការឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ ការឃុំខ្លួនចំពោះជនណាម្នាក់ដោយខុសច្បាប់មិនត្រូវបានអនុញ្ញាតដោយច្បាប់បច្ចុប្បន្នឡើយ ព្រោះប្រទេសកម្ពុជាមិនជ្រកក្រោមរបបពីអតីតកាលដែលធ្វើការចាប់ចង និងឃុំខ្លួនមនុស្សដោយស្រេចតែអំពើចិត្តនោះទេ។ បច្ចុប្បន្នការឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនណាម្នាក់ តម្រូវឱ្យមានការឆ្លងកាត់នូវការវិនិច្ឆ័យឱ្យបានហ្មត់ចត់ និងត្រឹមត្រូវអំពីសំណាក់អ្នកជំនាញវិជ្ជាជីវៈច្បាប់ ពោលគឺចៅក្រមស៊ើបសួរនេះតែម្តង។ ដូច្នេះការទទួលការឃុំខ្លួនចំពោះជនណាម្នាក់ដោយប្រធានពន្ធនាគារ តម្រូវឱ្យមានដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នពីចៅក្រមស៊ើបសួរដែលទទួលបន្ទុកស៊ើបសួរចំពោះជននោះជាមុនសិន មុននឹងទទួលឃុំខ្លួនជនត្រូវចោទ។ ការសម្រេចអំពីការឃុំ ឬមិនឃុំខ្លួនជាបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវមានការឆ្លងពិនិត្យ និងឱ្យយោបល់អំពីតំណាងអយ្យការដែលទទួលបន្ទុកនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ បន្ទាប់ពីព្រះរាជអាជ្ញាបានស្នើសុំទៅកាន់ចៅក្រមស៊ើបសួរអំពីសេចក្តីសម្រេចឃុំ ឬមិនឃុំចំពោះជនត្រូវចោទ ចៅក្រមស៊ើបសួរមានសិទ្ធិប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬក៏មិនសម្រេចតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដោយឈរលើមូលដ្ឋានច្បាប់ជាធំ ឬឃើញថាពុំចាំបាច់ឃុំ ព្រោះច្បាប់មិនតម្រូវឱ្យចៅក្រមស៊ើបសួរជាប់ទៅនឹងកាតព្វកិច្ចស្នើសុំរបស់ព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែច្បាប់បើកសិទ្ធិឱ្យព្រះរាជអាជ្ញាប្តឹងប្រឆាំងទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃទៅកាន់សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍។ ត្រង់នេះសរបញ្ជាក់ឱ្យឃើញថា ចៅក្រមស៊ើបសួរ គឺជារាស្ត្រាសាមញ្ញដូចប្រជាជនដទៃដែរ ការកើតមានកំហុសគឺរមែងតែមាន ហើយការសម្រេចសេចក្តីរបស់ចៅក្រមស៊ើបសួរមិនមែនសុទ្ធតែត្រូវទាំងអស់នោះដែរ ប៉ុន្តែគ្រាន់តែកម្រិតក្នុងការរៀនសូត្របណ្តុះបណ្តាល និងទទួលបានចំណេះដឹងផ្នែកច្បាប់គឺមានលក្ខណៈខ្ពស់ជាងជនទូទៅ ដោយហេតុថា ចៅក្រមស៊ើបសួរ គឺជាអ្នកមានប្រាជ្ញា ឈ្លាសវៃ វែកញែករកខុសត្រូវ និងជាអ្នកជម្រះក្តី។ ដូច្នេះហើយបានជាច្បាប់ទុកសិទ្ធិឱ្យមាន អគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញា និងជនត្រូវចោទ ដែលមិនសុខចិត្តនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ អាចប្តឹងទៅសភាស៊ើបសួរបាន ដើម្បីឱ្យសភាស៊ើបសួរធ្វើការពិនិត្យអំពីសេចក្តីសម្រេចរបស់ចៅក្រមឡើងវិញ ហើយសម្រេចដោយសាលដីកាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ។ ផ្ទុយទៅវិញ កាលបើបានប្តឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ហើយ ភាគីនៅតែពុំសុខចិត្តចំពោះសេចក្តីសម្រេចនេះទៀត នោះក្រមនីតិវិធី នៃព្រះរាជាណាចក្រកម្ពុជាបានទុកសិទ្ធិឱ្យភាគីប្តឹង

សាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរទៅតុលាការកំពូលបានក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ។ ហើយតុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ០៦(ប្រាំមួយ)ខែ គិតពីពេលទទួលសំណុំរឿង លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។

បន្ថែមពីនេះទៅទៀត ការស្រាវជ្រាវអំពីប្រធានបទខាងលើនេះ បានធ្វើឱ្យយើងយល់កាន់តែច្បាស់អំពីការទទួលបានសិទ្ធិ និងការគាំពារដោយច្បាប់ចំពោះជនជាប់ឃុំនៅពេលដែលចៅក្រមស៊ើបសួរសម្រេចអំពីការឃុំខ្លួនជាបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ។ នៅពេលដែលជនជាប់ឃុំមិនបានស្វែងយល់អំពីច្បាប់នីតិវិធីក្នុងការឃុំខ្លួន និងសិទ្ធិរបស់ពួកគាត់នៅក្នុងអំឡុងពេល នៃការឃុំខ្លួនជាបណ្ដោះអាសន្ននៅក្នុងពន្ធនាគារទេ នោះនឹងផ្ដល់នូវផលលំបាកយ៉ាងច្រើនចំពោះពួកគាត់នៅពេលដែលមានការរំលោភបំពានសិទ្ធិណាមួយកើតមានឡើងជាយថាហេតុនៅក្នុងកំឡុងពេលជាប់ឃុំ និងជាហេតុធ្វើឱ្យជនត្រូវចោទពុំទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌ឡើយ។ ច្បាប់ការពារ និងផ្ដល់សិទ្ធិឱ្យជនគ្រប់រូបស្មើៗគ្នា មិនថាជននោះជាជនរងគ្រោះ ឬជាជនល្មើស ដូច្នេះការយល់ដឹងអំពីច្បាប់ពិតជាមានសារៈសំខាន់ណាស់ ក្នុងការរស់នៅប្រចាំថ្ងៃ។ ក្នុងករណីដែលមានការបិទបាំងនូវការទទួលបានដំណឹងណាមួយ ឬការហាមឃាត់មិនឱ្យជួប ឬពឹងពាក់មេធាវី ពីមន្ត្រីពន្ធនាគារជាដើម ជនជាប់ឃុំត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីប្ដឹងប្រឆាំងចំពោះការរំលោភបំពានទាំងអស់នេះ។

ដូច្នេះហើយ ការស្រាវជ្រាវ និងចងក្រងនូវប្រធានបទខាងលើ ពិតជាផ្ដល់នូវពុទ្ធិ និងសារៈប្រយោជន៍ជាច្រើនដែលទាក់ទងអំពីគោលការណ៍ទូទៅ នៃការឃុំខ្លួនជាបណ្ដោះអាសន្ន និងគោលការណ៍ នៃសិទ្ធិសេរីភាពរបស់ជនគ្រប់រូបដែលត្រូវទទួលបាន នៅក្នុងអំឡុងពេល នៃការអនុវត្តនូវនីតិវិធីរបស់តុលាការ។

# អនុសាសន៍

# អនុសាសន៍

ដើម្បីឱ្យមានការអនុវត្តនូវ នីតិវិធី ស្តីពី ការឃុំខ្លួនជាបណ្តោះសន្ននៅក្នុងដំណាក់កាលស៊ើបសួរឱ្យកាន់តែមានសុក្រឹត្យភាព និងតម្លាភាពទៅតាមនីតិវិធីផ្លូវច្បាប់ យើងខ្ញុំសូមសំណូមពរដូចខាងក្រោមៈ

១-**ចៅក្រមស៊ើបសួរៈ** ក្នុងនាមជាយុត្តាធិការដែលមានអំណាចក្នុងការចេញនូវសេចក្តីសម្រេចឃុំខ្លួន ឬមិនឃុំខ្លួន ជនត្រូវចោទជាបណ្តោះអាសន្ន គប្បីមានការពិចារណាឱ្យបានដិតដល់ លើគ្រប់ស្ថានភាព និងគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទ ជាជាងអនុវត្តទៅតាមការសន្និដ្ឋានរបស់តំណាងអយ្យការ ដោយពុំបានពិចារណាទៅលើមូលហេតុឱ្យបានច្បាស់លាស់។ ក្រៅពីការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏មានវិធានការនិរន្តរាយ៍មួយចំនួន ដែលអាចសម្រួលដល់នីតិវិធីនៅក្នុងដំណាក់កាលស៊ើបសួរផងដែរ ដែលគប្បីចៅក្រមស៊ើបសួរយកមកពិចារណា ដោយពុំមែនចាត់ទុកថា ការឃុំខ្លួនជាបណ្តោះអាសន្នជាវិធានការចុងក្រោយ និងតែមួយគត់បានឡើយ។

២-**ព្រះរាជអាជ្ញាៈ** ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា គប្បីធ្វើការពិចារណាឱ្យបានល្អិតល្អន់ ថាតើគួរធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ឬមិនគួរ? ជាជាងការដែលឱ្យតែមានបទឧក្រិដ្ឋ និងមជ្ឈិម ដែលត្រូវផ្តន្ទាទោសចាប់ពី០១(មួយ)ឆ្នាំឡើង គឺត្រូវតែធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទនោះឡើយ ជាហេតុធ្វើឱ្យមានការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងធ្វើឱ្យមានការចង្អៀតណែន នៃពន្ធនាគារ។

៣-**មេធាវីការពារក្តីជនក្រីក្រៈ** ក្នុងនាមជាអ្នកវិជ្ជាជីវៈច្បាប់ យល់ដឹងច្បាស់អំពីនីតិវិធីតុលាការ និងសិទ្ធិរបស់ជនត្រូវចោទ គប្បីបើទទួលការពារក្តីឱ្យអ្នកណាហើយ គួរតែធ្វើ និងសិក្សាឱ្យអស់ពីលទ្ធភាព ជៀសវាងការមិនសិក្សារឿងក្តីឱ្យបានគ្រប់ជ្រុងជ្រោយ ហើយទៅការពារក្តីដោយគ្មានការយកចិត្តទុកដាក់ខ្ពស់ ជាហេតុនាំឱ្យខាតបង់ប្រយោជន៍ និងបាត់បង់នូវសិទ្ធិរបស់កូនក្តីខ្លួន។ ថ្វីបើច្បាប់បានបង្កើតឱ្យមានមេធាវីស្ម័គ្រចិត្តការពារជនក្រីក្រដោយឥតគិតថ្លៃយ៉ាងណាក្តី ហើយថវិកាដែលរដ្ឋបានផ្តល់ឱ្យមេធាវីក្នុងការការពារជនក្រីក្រមានលក្ខណៈស្តួចស្តើងក៏ពិតមែន ប៉ុន្តែក្នុងនាមជាអ្នកប្រាជ្ញា មេធាវីគប្បីត្រូវមានគុណធម៌ការពារឱ្យអស់ពីចិត្តសម្រាប់កូនក្តីរបស់ខ្លួន ទោះបីជាមានផលតបស្នងបន្តិចបន្តួច ឬក៏គ្មានសោះក៏ដោយ ព្រោះសិទ្ធិ និងប្រយោជន៍របស់កូនក្តីអាចត្រូវទទួលបាន ឬបាត់បង់ទៅវិញ គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់មេធាវីដែលការពារក្តីឱ្យខ្លួននេះហើយ។ ទោះបីជាយ៉ាងនេះក្តី ក៏មានមេធាវីមួយចំនួនធំ បានបំពេញនូវ

កាតព្វកិច្ចរបស់ខ្លួនយ៉ាងពេញលេញ និងស្មើដៃស្មើជើងផងដែរ។ ហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមេធាវីដែលមានគុណធម៌ក្នុងការការពារសិទ្ធិជូនក្តីរបស់ខ្លួនដោយអស់ពីចិត្តដូចនេះ។

**៤-ក្រសួងយុត្តិធម៌** គប្បីធ្វើយ៉ាងណាជួយសម្រួល និងផ្តល់ជាអនុសាសន៍ឱ្យបានកាន់ច្រើនពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ព្រោះកន្លងមកស្ទើរគ្រប់សំណុំរឿងព្រហ្មទណ្ឌ គឺសុទ្ធតែមានការឃុំខ្លួនជាបណ្តោះអាសន្ន ជាហេតុធ្វើឱ្យមានការកកស្ទះសំណុំរឿង នៅដំណាក់កាលស៊ើបសួរ និងចង្អៀតណែនពន្ធនាគារជាខ្លាំង។ ម្យ៉ាងវិញទៀត ការចង្អៀតណែននៃពន្ធនាគារ គឺជាការព្រួយបារម្ភមួយផងដែរ ពាក់ព័ន្ធនឹងជម្ងឺកូវីត-១៩ ដែលអាចឆ្លៀតឱកាសឆ្លងរីករាលដាលនៅក្នុងពន្ធនាគារបាន។ មួយវិញទៀត ការសម្រេចឃុំខ្លួនជនត្រូវចោទនៅក្នុងពន្ធនាគារច្រើនពេក គឺជាការនាំឱ្យខាតប្រយោជន៍ទៅដល់រដ្ឋក្នុងការចំណាយថវិកាកាន់តែច្រើនចំពោះសម្លៀកបំពាក់អ្នកជាប់ឃុំ ទឹកភ្លើង និងចំណីអាហារ។ល។ជាហេតុនាំឱ្យខាតបង់នូវថវិកា និងពេលវេលារបស់រដ្ឋ។ ក្នុងមួយចំនួនប្រសិនបើមានភស្តុតាងគ្រប់គ្រាន់អាចជំនុំជម្រះបាន គួរប្រើប្រាស់វិធានបញ្ជូនរឿងទៅជម្រះភ្លាម ជាជាងការសម្រេចឱ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ដោយឡែកចំពោះបទមជ្ឈិមដែលពុំមានលក្ខណៈធ្ងន់ធ្ងរ បើអាចគប្បីពិចារណាទៅលើ វិធានការដាក់ជនត្រូវចោទ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសវិញ ជាជាងយល់ឃើញថាការឃុំខ្លួនជាបណ្តោះអាសន្ន គឺជាជម្រើសទូទៅ។

**៥-ក្រសួង និង ស្ថាប័នដែលមានសមត្ថកិច្ច ក្នុងការចូលរួមអនុវត្តកំចាត់អំពើពុករលួយ** ដែលមានដូចជាក្រសួងយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ស្ថាប័នតុលាការដែលមានសមត្ថកិច្ចចំពោះរឿងក្តី និងក្រសួងមហាផ្ទៃជាដើម ដើម្បីចូលរួមសហការក្នុងការអនុវត្តចំពោះជនទុច្ចរិតណាដែលបានប្រព្រឹត្តអំពើពុករលួយ និងការប្រព្រឹត្តអំពើពុករលួយមានលក្ខណៈជាប្រព័ន្ធ។ ជាពិសេស ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាដែលសម្រេចឃុំខ្លួនជនត្រូវចោទដោយមានលក្ខណៈមិនប្រក្រតីដោយមិនមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវនោះ ត្រូវមានការត្រួតពិនិត្យពីក្រសួងយុត្តិធម៌ឲ្យបានច្បាស់អំពីដំណើរការ នៃសំណុំរឿងនេះ ការដាក់ទណ្ឌកម្ម និងវិន័យឲ្យបានតឹងរឹងពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។ បន្ថែមពីនេះ ព្រះរាជអាជ្ញាត្រូវចូលរួមសហការឲ្យបានហ្មត់ចត់ និងតម្លាភាព ដោយមិនបិទបាំងលក្ខណៈជាប្រព័ន្ធចំពោះបទល្មើសពុករលួយណាដែលត្រូវបានប្រព្រឹត្តដោយចៅក្រមរូបណាមួយឡើយ។

# វាក្យស័ព្ទគតិយុត្ត

# វាក្យតតិយុត្តិ

« ក »

- **ការត្រួតពិនិត្យតាមផ្លូវតុលាការ** គឺជាវិធានការរឹតត្បិតសេរីភាពមួយចំនួន ចំពោះជនត្រូវចោទ។ វិធានការនេះ មានលក្ខណៈស្រាលជាងវិធានការឃុំខ្លួនជាបណ្ដោះអាសន្ន។ ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រៅឃុំ តែត្រូវគោរពកាតព្វកិច្ចមួយចំនួន ឬច្រើនដូចមានកំណត់ក្នុងមាត្រា២២៣ (កាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនកំណត់ពេលវេលា។ ចៅក្រមស៊ើបសួរ គឺជាអ្នកមានសិទ្ធិអំណាចក្នុងការសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីមានការសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការហើយ តែជនត្រូវចោទមិនគោរពកាតព្វកិច្ចដែលបានកំណត់ នោះចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការកែប្រែ ឬលុបចោលការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសម្រេចឃុំខ្លួនជននោះជាបណ្ដោះអាសន្នវិញបានគ្រប់ពេលវេលា។

« គ »

- **គោលការណ៍កាលានុវត្តភាព** គឺជាគោលការណ៍មួយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលផ្ដល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការជ្រើសរើសចោទប្រកាន់ ឬមិនចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ។

« ច »

- **ចៅក្រមអាសនៈ** គឺជាចៅក្រមជំនុំជម្រះ និងចៅក្រមស៊ើបសួរ។
- **ចៅក្រមស៊ើបសួរ** គឺជាចៅក្រមដែលទទួលបន្ទុកស៊ើបសួររឿងព្រហ្មទណ្ឌ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

« ឆ »

- **ឆន្ទានុសិទ្ធិ** គឺជាអំណាច ដែលប្រគល់ឱ្យចៅក្រមរើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួន មកដោះស្រាយបញ្ហាណាមួយ។ គឺជាអំណាចរបស់ចៅក្រម ក្នុងការធ្វើសកម្មភាព ក្នុងនីតិវិធី នៃបណ្ដឹងដោយមិនបាច់មានពាក្យសុំរបស់ភាគី។

« ជ »

- **ជនល្មើស** គឺជាអ្នកប្រព្រឹត្តិអំពើខុសច្បាប់។
- **ជនត្រូវចោទ** គឺជាឈ្មោះសម្រាប់ហៅសម្គាល់អ្នកដែលប្រព្រឹត្តបទល្មើស នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ។

« ប »

- **បទល្មើស** គឺជាអំពើប្រឆាំង និងអំពើល្មើសចំពោះច្បាប់ព្រហ្មទណ្ឌ ជាអំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម និងប៉ះពាល់ទៅដល់សណ្ដាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយជនល្មើស ដោយអំពើល្មើសនោះ អាចជាកំហុសរបស់ចារីផ្ទាល់ ឬ/និងសហចារី (កាលបើអ្នកប្រព្រឹត្តបទល្មើសមានចាប់ពីពីរនាក់ឡើងទៅ)។
- **បណ្ដឹងទាមទារ** គឺជាបណ្ដឹងដែលធ្វើឡើងដោយជនរងគ្រោះប្ដឹងទៅសមត្ថកិច្ច (មន្ត្រីនគរបាលយុត្តិធម៌) ឱ្យជួយដោះស្រាយនូវសំណង នៃការខូចខាត សំណងជម្ងឺចិត្ត និងផ្ដន្ទាទោសតាមផ្លូវច្បាប់។
- **បណ្ដឹងបរិហារ** គឺជាបណ្ដឹងដែលធ្វើឡើងដោយតតិយជន មន្ត្រីសាធារណៈ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ប្ដឹងទៅសមត្ថកិច្ចដើម្បីស្វែងរកភស្ដុតាង និងឈានទៅដល់ការរកមុខចាប់ជនល្មើសមកផ្ដន្ទាទោស។
- **បណ្ដឹងអាជ្ញា** គឺជាបណ្ដឹងដែលធ្វើឡើងដោយអយ្យការ និងអាចដាក់ឱ្យមានចលនាដោយជនរងគ្រោះ មានគោលបំណងនៅក្នុងការពិនិត្យអត្ថិភាព នៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជននោះតាមច្បាប់កំណត់។ បណ្ដឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពផ្សេងៗ។
- **បណ្ដឹងសាទុក្ខ** គឺជាបណ្ដឹងដែលធ្វើឡើងដោយបុគ្គលដែលមិនសុខចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ហើយគេធ្វើបណ្ដឹងសាទុក្ខនេះឡើង ក្នុងគោលបំណងឱ្យតុលាការកំពូលពិនិត្យពិច័យ និងពិចារណាឡើងវិញ ចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដោយធ្វើនូវសេចក្ដីសម្រេចបិទបញ្ចប់។

« ដ »

- **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** គឺជាដីកាមួយរបស់ព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់ចំពោះមជ្ឈិម ឬបទឧក្រិដ្ឋ ដោយមានសេចក្តីសន្និដ្ឋានអំពីអង្គហេតុ និងអង្គច្បាប់ ហើយបញ្ជូនឱ្យចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរអំពីអង្គហេតុនោះ ដូចមាននៅក្នុងដីកាសេចក្តីសន្និដ្ឋាន។
- **ដីកាបញ្ជូនរឿងឱ្យជំនុំជម្រះ** គឺជាដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមួយប្រភេទ ដែលចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដោយមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ថា ជននោះបានប្រព្រឹត្តអំពើដែលជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។
- **ដីកាឃុំខ្លួនបណ្តោះអាសន្ន** គឺជាដីកាមួយប្រភេទ ដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នក្នុងរយៈពេលណាមួយដែលកំណត់ដោយច្បាប់ តាមរយៈឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរផ្ទាល់ ឬតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

« ព »

- **ពន្ធនាគារ** សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំ តាមដីកាឃុំខ្លួន ចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង។
- **ពិរុទ្ធភាព** គឺសំដៅទៅលើជនដែលតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ប៉ុន្តែសេចក្តីសម្រេចនោះមិនទាន់ចូលជាស្ថាពរនៅឡើយ។

« ភ »

- **ភស្តុតាង** គឺជាតឹកតាងជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងចំណុចវិវាទគូភាគីដែលជាមូលដ្ឋាន នៃការសម្រេចសេចក្តីរបស់តុលាការ។

« ម »

- **មន្ត្រីនគរបាលយុត្តិធម៌** គឺជាមុខងារមួយរបស់នគរបាលយុត្តិធម៌ មានតួនាទីជាជំនួយរបស់អំណាចតុលាការ ពោលគឺមានន័យថាជាជំនួយរបស់អំណាចព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ នគរបាលយុត្តិធម៌រួមមាន មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។

« យ »

– **យុត្តាធិការស៊ើបសួរ** គឺជាស្ថាប័នស៊ើបសួរ រួមមានចៅក្រមស៊ើបសួរ។ យុត្តាធិការជំនុំជម្រះ គឺជាស្ថាប័នទទួលបន្ទុកខាងជំនុំជម្រះក្ដី។ តុលាការរួមមានចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ។

« រ »

– **រូបវន្តបុគ្គល** គឺជាមនុស្សពិតតាមធម្មជាតិដែលផ្ទុយនឹងនីតិបុគ្គល។ ហើយនីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់ នៃសិទ្ធិ និងកាតព្វកិច្ច។

« ល »

– **លិខិតយថាភូត** គឺជាលិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយណាដែលរៀបចំដោយសារការី។

– **មន្ត្រីពន្ធនាគារ** សំដៅដល់មន្ត្រីដែលស្ថិតនៅក្នុងក្របខណ្ឌពន្ធនាគារ។

« ស »

– **សុពលភាព** គឺជាភាវៈមានអានុភាពអនុវត្តតាមផ្លូវច្បាប់។
– **សាលក្រម** ថាគឺជាសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ទាប។
– **សាលដីកា** ថាគឺជាសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ខ្ពស់។
– **សភាស៊ើបសួរ** គឺជាសភាពិសេសមួយរបស់សាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចធ្វើការជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍ដែលប្ដឹងប្រឆាំងនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ។
– **សភាព្រហ្មទណ្ឌ** គឺជាសភាមួយរបស់តុលាការជាន់ខ្ពស់ដែលពិនិត្យទៅលើរឿងក្ដីព្រហ្មទណ្ឌ។
– **សារណា** គឺជាសេចក្ដីថ្លែងការណ៍មួយដែលធ្វើឡើងដោយជនដែលប្ដឹងនឹងសេចក្ដីសម្រេចដូចជាសាលក្រម ឬសាលដីកា ដាក់ជូនតុលាការជាន់ខ្ពស់ ឬជាន់ទាបពិនិត្យ។

« អ »

– **អត្ថិភាព** គឺជាភាពនៃអ្វីៗដែលមាន ភាវៈមាន ការមាន។ ហើយពាក្យដែលផ្ទុយនឹងអត្ថិភាព គឺនត្ថិភាព ដែលពាក្យនេះមានន័យថា ភាពគ្មាន ភាវៈគ្មាន អ្វីដែលគ្មាន។ ឧ. កាលដើមឡើយគាត់ធ្លាក់ក្នុងនត្ថិភាព តែឥឡូវគាត់បានចូលក្នុងអត្ថិភាពវិញហើយ។

– **អនីតិជន** គឺជាជនដែលមានអាយុក្រោម១៨ឆ្នាំ។

- **អ្នកជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិត ដែលត្រូវបានបញ្ជូនមកឃុំខ្លួន នៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួន ចេញដោយអាជ្ញាធរតុលាការ។
- **អង្គការអយ្យការ** គឺជាស្ថាប័នមួយ ដែលមាននៅអមគ្រប់សាលាជម្រះក្តីទាំងអស់ ដែលជាអ្នកតំណាងឱ្យសង្គម និងជាអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ ហើយមានតួនាទីជាអ្នកធ្វើការចោទប្រកាន់ខាងផ្នែកបទល្មើសព្រហ្មទណ្ឌ ជាអ្នកធ្វើបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ព្រមទាំងជាអ្នកធានារ៉ាប់រងការអនុវត្តនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។

# ឥន្ទនិទ្ទេស

# គន្ថនិទ្ទេស

## ១. ឯកសារជាភាសាខ្មែរ

### ១.១. លិខិតបទដ្ឋានគតិយុត្ត

#### ក. អំពីរដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សភាធម្មនុញ្ញអនុម័តថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

#### ខ. អំពីក្រម

- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

#### គ. អំពីច្បាប់

- ច្បាប់ ស្តីពី លក្ខន្តិកៈមេធាវី
- ច្បាប់ ស្តីពី ពន្ធនាគារ
- ច្បាប់ ស្តីពី យុត្តិធម៌អនីតិជន
- ច្បាប់ ស្តីពី លក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា

#### ឃ. អំពីអនុសញ្ញា និងកតិកាសញ្ញា

- អនុសញ្ញា ស្តីពី សិទ្ធិកុមារ
- កតិកាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

#### ង. អំពីសារាចរ

- សារាចរ ស្តីពី ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ០១/គយសរ/១៤ របស់ក្រសួងយុត្តិធម៌។

#### ច. អំពីឯកសារជាសៀវភៅ និងអត្ថបទ

- សៀវភៅ ដំណើរការរឿងក្តីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន របស់ លោក វរសេនីយ៍ឯក អានសូរីដា ឆ្នាំ២០១៤។
- សៀវភៅមុគ្គទេសក៍ ស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការអង្កេតការណ៍សវនាការ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១២។

- សៀវភៅនីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១៣។
- សៀវភៅមុគ្គទេសក៍ ស្ដីពី នីតិវិធីព្រហ្មទណ្ឌ នៅតុលាការកម្ពុជា របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១៣។
- សៀវភៅ នីតិវិធី នៃការអនុវត្តជាក់ស្ដែងក្នុងរឿងក្ដីព្រហ្មទណ្ឌ របស់មជ្ឈមណ្ឌលបណ្ដុះ-បណ្ដាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០១៥។
- សៀវភៅ សន្និសីទ ស្ដីពី ការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន និងសារាចរនានា ស្ដីពីជំរើសផ្សេងទៀត ក្រៅពីការឃុំខ្លួន របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។
- សៀវភៅ ក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ និតិកោសល ឆ្នាំ២០២០។
- សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧។
- សេចក្ដីសម្រេចលេខ៖ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសំណុំរឿងលេខ៖ ១៣១/០០៣/២០០៧ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧។
- កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក្នុងការអនុវត្តន៍ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងតុលាការកម្ពុជា ឆ្នាំ២០១៣។
- អត្ថបទខ្លី ស្ដីអំពី ការឃុំខ្លួនជាបណ្ដោះអាសន្នមាននៅក្នុងគេហទំព័រ https://ciclg.com/en/ article/128
- អត្ថបទព័ត៌មានភ្នំពេញប៉ុស្ដិ៍ https://www.postkhmer.com
- អត្ថបទព័ត៌មានកោះសន្តិភាព https://kohsantepheapdaily.com.kh/
- អត្ថបទច្បាប់ នៃគេហទំព័រ https://law-asia.blogspot.com/2017/03/presumption-and-legitimate.html?fbclid=IwAR3H5fhZFl7ZcOlTw7PCePJes3jw5uA_orkLn WSR DngDmrYQsdkjFGAQ1tA)
- សេចក្ដីពន្យល់ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, សេចក្ដីពន្យល់ចំពោះករណីយុត្តិសាស្ត្រអវតក និងអន្តរជាត់សម្រាំង, ឆ្នាំ២០១៤។
- នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣។

## ឆ. អំពីវចនានុក្រម និងសន្ទានុក្រមច្បាប់

- វចនានុក្រមច្បាប់ ខ្មែរ អង់គ្លេស រៀបរៀងដោយ លោក ភូ ឡាយស៊ុន និងលោក ភូ វួចចេង។
- សន្ទានុក្រមច្បាប់បារាំងខ្មែរ នៃពាក្យច្បាប់ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០០៥។
- សន្ទានុក្រម នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំឱ្យបំពេញកិច្ច

ឧបសម្ព័ន្ធទី២៖ ដីកាសម្រេចមិនអនុញ្ញាតឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី៣៖ ពាក្យស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី៤៖ ដីកាបង្គាប់ឱ្យដោះលែង

ឧបសម្ព័ន្ធទី៥៖ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័ន្ធទី៦៖ ពាក្យពឹងពាក់មេធាវី

ឧបសម្ព័ន្ធទី៧៖ ពាក្យសុំអនុញ្ញាតជួបកូនក្ដី

ឧបសម្ព័ន្ធទី៨៖ ពាក្យបណ្ដឹងដិតចិត្ត

ឧបសម្ព័ន្ធទី៩៖ ច្បាប់ ស្ដីពី លក្ខន្តិកៈមេធាវី

ឧបសម្ព័ន្ធទី១០៖ លិខិតជូនដំណឹង ស្ដីពី ការបញ្ជូនរឿងទៅជំនុំជម្រះ

ឧបសម្ព័ន្ធទី១១៖ ដីកាបង្គាប់ឱ្យចូលខ្លួន

ឧបសម្ព័ន្ធទី១២៖ ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័ន្ធទី១៣៖ សេចក្ដីប្ដឹងឧទ្ធរណ៍

ឧបសម្ព័ន្ធទី១៤៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ឧបសម្ព័ន្ធទី១៥៖ គម្រូពាក្យស្នើសុំដោះលែងកូនក្ដីឱ្យនៅក្រៅឃុំ

ឧបសម្ព័ន្ធទី១៦៖ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី១៧៖ ដីកាបង្គាប់ឱ្យឃុំខ្លួន

ឧបសម្ព័ន្ធទី១៨៖ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី១៩៖ ពាក្យបណ្ដឹងឧទ្ធរណ៍

ឧបសម្ព័ន្ធទី២០៖ គម្រូពាក្យបណ្ដឹងសាទុក្ខ

ឧបសម្ព័ន្ធទី២១៖ គម្រូលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្ដឹងសាទុក្ខ

ឧបសម្ព័ន្ធទី២២៖ លិខិតជូនដំណឹងឱ្យដាក់សារណាការពារ

ឧបសម្ព័ន្ធទី២៣៖ ដីកាបញ្ជូន (ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ)

ឧបសម្ព័ន្ធទី២៤៖ ដីកាបញ្ជូន (ប្រធានពន្ធនាគារ)

ឧបសម្ព័ន្ធទី២៥៖ សាលដីការបស់សភាព្រហ្មទណ្ឌ នៃតុលាការកំពូល

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យស្នើសុំឱ្យបំពេញកិច្ច</u>**

ខ្ញុំបាទ/នាងខ្ញុំមេធាវី...........................អត្តលេខ............ជាសមាជិកមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីប្រចាំក្រុមហ៊ុនមេធាវី/ក្រុមមេធាវី/ការិយាល័យមេធាវី.............និង ជាមេធាវីការពារក្ដីឱ្យឈ្មោះ..........................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ...............................ចុះ ថ្ងៃទី..........ខែ...............ឆ្នាំ..............របស់សាលាដំបូងរាជធានី-ខេត្ត....................។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តម ប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុៈ** សំណើរសុំឱ្យបំពេញកិច្ច កោះហៅដើមបណ្ដឹង មកសួរតទល់គ្នា ជាមួយជនត្រូវចោទ។

**យោងៈ** ពាក្យពឹងពាក់មេធាវី ចុះថ្ងៃទី.........ខែ..........ឆ្នាំ............របស់លោក/លោកស្រី............។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម ប្រធាន** មេត្តាជ្រាប ថាៈ លោក/លោកស្រី.....................បានពឹងពាក់ខ្ញុំបាទ/នាងខ្ញុំ ដើម្បីធ្វើពាក្យសុំ កោះហៅដើមបណ្ដឹងមក សួរតទល់គ្នា។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ប្រធាន** មេត្តាកោះហៅដើមបណ្ដឹង មកសួរតទល់ជាមួយ ជនត្រូវចោទ តាមកម្មវត្ថុ នៃពាក្យសុំ ដោយសេចក្ដីអនុគ្រោះ។

សូម **ឯកឧត្តម ប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ៕

ធ្វើនៅថ្ងៃទី........ខែ.............ឆ្នាំ...............

**ហត្ថលេខា និងត្រា**

**មេធាវី**

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការខេត្ត-ក្រុង** ជាតិ សាសនា ព្រះមហាក្សត្រ

...........................

**********

**********

លេខ[១] ......................

# ដីកាសម្រេចមិនអនុញ្ញាតឱ្យជនល្មើសនៅក្រៅឃុំជាបណ្ដោះអាសន្ន

**********

យើង.................................................... ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង........................................ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ...................... ចុះថ្ងៃទី ............ ខែ......................... ឆ្នាំ....................... ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ..................ចុះថ្ងៃទី...........ខែ........................ឆ្នាំ.................... របស់ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង.................................................... ។

បានឃើញដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ .................. ចុះថ្ងៃទី ............ ខែ .................. ឆ្នាំ ............ និងដីកាសម្រេចបន្ដរយៈពេលឃុំខ្លួនជាបណ្ដោះអាសន្នលេខ....................... ចុះថ្ងៃទី ................ ខែ ................ ឆ្នាំ ................ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ............................................ ។

បានឃើញពាក្យសុំចុះថ្ងៃទី................................របស់ឈ្មោះ..........................................................................ត្រូវជា ..........................................................................ជនជាប់ចោទឈ្មោះ ........................................................ បានសុំឱ្យឈ្មោះ ........................................................ បាននៅក្រៅឃុំជាបណ្ដោះអាសន្ន ។

ក្រោយពីបានពិនិត្យលើសំណុំរឿង និងពាក្យសុំនេះចប់សព្វគ្រប់

យល់ឃើញថា[២] ...........................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

## ហេតុដូច្នេះ សម្រេច

១-មិនអនុញ្ញាតឱ្យឈ្មោះ...................................................អាយុ.............ឆ្នាំភេទ..............ជាតិ ....................... របររកស៊ី...........................................ទីលំនៅបច្ចុប្បន្ននៅភូមិ .................................ឃុំ-សង្កាត់ ......................... ស្រុក-ខណ្ឌ ............................ខេត្ត-ក្រុង...........................ដែលជាប់ចោទពីបទ ................................................ ប្រព្រឹត្តនៅភូមិ ................................ ឃុំ-សង្កាត់ ..................................... ស្រុក-ខណ្ឌ ................................. ខេត្ត-ក្រុង ............................... កាលពីថ្ងៃទី ............ ខែ................. ឆ្នាំ..................... ហើយដែលត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងខេត្ត-ក្រុង ...............................លេខឃុំខ្លួន ...................... ចុះថ្ងៃទី............... ខែ........................ ឆ្នាំ...................... នៅក្រៅឃុំជាបណ្ដោះអាសន្នទេ ។

២-បង្គាប់ឱ្យក្រឡាបញ្ជីជូនដំណឹងទៅឈ្មោះ ........................................... ត្រូវជា........................................... ដើម្បីជ្រាប ។

ធ្វើនៅ....................... ថ្ងៃទី......... ខែ......... ឆ្នាំ ២០០...

**ចៅក្រមស៊ើបអង្កេត**

បានទទួលដំណឹងរួចហើយ

នៅថ្ងៃទី............ ខែ............. ឆ្នាំ ២០០...

**ព្រះរាជអាជ្ញា**

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានរដ្ឋបាល សាលាដំបូងខេត្តកំពត
លេខ: ......
ថ្ងៃទី ១៤ ខែ ១១ ឆ្នាំ ២០១៩
ម៉ោង ១០:៤០ នាទី

**ពាក្យសុំនៅក្រៅឃុំបណ្ដោះអាសន្ន**

នាងខ្ញុំឈ្មោះ អាយុ៣៩ឆ្នាំ បច្ចុប្បន្នកំពុងជាប់ឃុំឃាំងនៅ ពន្ធនាគារខេត្តកំពតតាមអំណាចដីកាបង្គាប់អោយឃុំខ្លួនលេខ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៩របស់សាលាដំបូងខេត្តកំពត ។

**សូមគោរពចូលមក**

**លោក ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត**

សូមទានជ្រាប ។

ដោយនាងខ្ញុំ ត្រូវជាប់ចោទពីបទៈ រួមគំនិតក្បត់ ហើយនាងខ្ញុំ សុំនៅក្រៅឃុំ ដើម្បីបានទៅរួមរស់ជាមួយប្ដី និងកូន ព្រមទាំងមានទីលំនៅ ពិតប្រាកដដែលស្ថិតនៅភូមិ ទឹកក្រហម ឃុំកណ្ដាលស្រុក ទឹកឈូ ខេត្តកំពត ។

ដូច្នេះនាងខ្ញុំ សំណូមពរលោកចៅក្រម មេត្តាអនុញ្ញាតអោយនាងខ្ញុំ បាននៅក្រៅឃុំបណ្ដោះអាសន្ន ដើម្បីបានទៅរួមរស់ជាមួយប្ដី និងកូន ហើយនាងខ្ញុំ សូមសន្យាថាចូលខ្លួនមកតុលាការគ្រប់ពេលនៅពេលដែលតុលាការកោះហៅ ។

អាស្រ័យហេតុនេះ សូមលោកចៅក្រមស៊ើបសួរ មេត្តាជួយដោះស្រាយសំណូមពរ របស់នាងខ្ញុំដោយក្ដីអនុគ្រោះ ។

សូមលោក ចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ!

ថ្ងៃព្រហស្បតិ៍៣រោចខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពត.ថ្ងៃទី១៤ខែ វិច្ឆិកា ឆ្នាំ ២០១៩

**ស្នាមមេដៃស្ដាំ**

លេខ

បានឃើញ និង បញ្ជាក់ថា

ស្នាមមេដៃនេះពិតជារបស់ឈ្មោះ

កំពុងឃុំឃាំងនៅក្នុងពន្ធនាគារប្រាកដមែន ។

ថ្ងៃ ព្រហស្បតិ៍៣រោច ខែកត្តិក ឆ្នាំកុរឯកស័ក ព.ស ២៥៦៣

កំពត.ថ្ងៃទី១៤ខែ វិច្ឆិកា ឆ្នាំ ២០១៩

**ប្រធានពន្ធនាគារ**

**ឧបសម្ព័ន្ធទី៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ " ម "

លេខ

## ដីកាបង្គាប់ឱ្យដោះលែង

យើង អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ។

- បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ៈថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់មេធាវី
- បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

### ហេតុដូច្នេះសម្រេច

បង្គាប់មកលោកប្រធានមណ្ឌលអប់រំកែប្រែទី២ "ម២" ឱ្យដោះលែងឈ្មោះ ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ និស្សិត ទីកន្លែងកំណើតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្ន ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ ពីបទ ញុះញង់ឱ្យមានការរំខានធ្ងន់ធ្ងរដល់សន្តិសុខសង្គម? លួចមានស្ថានទម្ងន់ទោស ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ជាបន្ទាន់ បើជននេះមិនជាប់ពាក់ព័ន្ធនឹងដីកាឃុំ ខ្លួននៃបទល្មើសផ្សេងទៀតទេនោះ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២១
ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

បន្ទប់ស៊ើបសួរ
លេខ:

## ដីកាសម្រេច
## ដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោកស្រី ជាក្រឡាបញ្ជី។

-បានឃើញមាត្រា ២២៣ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ។
-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី

-បានឃើញសំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី
-បានឃើញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ: តព ចុះថ្ងៃទី

### សំអាងហេតុ

-ជនត្រូវចោទតុលាការបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **រំលោភលើសេចក្តីទុកចិត្ត និងក្លែងលិខិតឯកជន** ដែលជាបទមជ្ឈិម ហើយមានកំណត់ទោសដាក់ពន្ធនាគារ។

-ជនត្រូវចោទតុលាការបានសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែតម្រូវឲ្យជនត្រូវចោទបំពេញកាតព្វកិច្ចមួយចំនួន ដើម្បីធានាដល់នីតិវិធីនៃការស៊ើបសួរ។

-ជនត្រូវចោទបានតម្កល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ចុះថ្ងៃទី ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ដើម្បីធានាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញលិខិតអះអាង ចុះថ្ងៃទី របស់ឈ្មោះ អះអាងថា លំនៅដ្ឋាន សង់លើដីមួយកន្លែងទំហំ ដែលមានប័ណ្ណកាន់កាប់អចលនវត្ថុលេខ: ចុះថ្ងៃទី ជារបស់ខ្លួននោះមានតម្លៃសរុបប្រហែល ( ដុល្លារអាមេរិក) ជាតម្លៃសព្វថ្ងៃ។

-ដើម្បីធានាជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះដល់ការស៊ើបសួរ គប្បីសម្រេចដាក់ជនត្រូវចោទឲ្យជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យ តាមផ្លូវតុលាការ។

### ហេតុដូច្នេះសម្រេច:

១-ដាក់ជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិ កើតនៅថ្ងៃទី ខែ ឆ្នាំ មុខរបរ កើតនៅ

ទីលំនៅបច្ចុប្បន្ននៅ

ឪពុកឈ្មោះ ស្លា ម្តាយឈ្មោះ រស់ ប្រពន្ធឈ្មោះ រស់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ដែលត្រូវចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅ កាលពីឆ្នាំ ដល់ឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៦ និងមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ឲ្យគោរពកាតព្វកិច្ចដូចខាងក្រោម:

ក-មិនត្រូវផ្លាស់ប្តូរទីលំនៅដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

ខ-ត្រូវចូលមកបង្ហាញខ្លួននៅពេលមានការកោះហៅរបស់ចៅក្រមស៊ើបសួរ។

គ-ត្រូវចូលបង្ហាញខ្លួនតាមកាលកំណត់នៅនគរបាលប៉ុស្តិ៍ រៀងរាល់ថ្ងៃសុក្រ។

២-លោកប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវអនុវត្តដីកាសម្រេចនេះ និងរាយការណ៍ជូនចៅក្រមស៊ើបសួរ ក្នុងករណីជនត្រូវចោទមិនគោរពតាមកាតព្វកិច្ចខាងលើ។ ប្រសិនបើជនត្រូវចោទ គេចវេស ដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំ ខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន។

បានទទួលដំណឹង

រាជធានីភ្នំពេញ, ថ្ងៃទី

ជ. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ, ថ្ងៃទី

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យពឹងពាក់មេធាវី</u>

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................ថ្ងៃខែឆ្នាំកំណើត........................ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖......................................ចុះថ្ងៃទី.............................មានទីលំនៅស្ថិតនៅ .........................ទូរស័ព្ទលេខ៖....................................................។

## <u>សូមពឹងពាក់</u>

**ក្រុមហ៊ុនមេធាវី/ក្រុមមេធាវី/ការិយាល័យមេធាវី**...........................................មានទីតាំងស្ថិតនៅ...................................................ដើម្បីធ្វើជាមេធាវីការពារក្ដីឱ្យខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ....................នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖....................................ចុះថ្ងៃទី.......ខែ..................ឆ្នាំ........................របស់សាលាដំបូងរាជធានី-ខេត្ត................................និងមានសិទ្ធិពេញលេញក្នុងការតែងតាំងមេធាវីដែលជាសមាជិកនៃ ក្រុមហ៊ុនមេធាវី/ក្រុមមេធាវី/ការិយាល័យមេធាវី.............................ជាអនុតំណាងឱ្យការពារក្នុងរឿងក្ដីនេះ បានគ្រប់ដំណាក់កាល នៅសាលាដំបូងរាជធានី-ខេត្ត..................តាមនិតិវិធីច្បាប់។

ពាក្យពឹងពាក់នេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃផ្តិតមេដៃ ឬចុះហត្ថលេខានេះតទៅ៕

ធ្វើថ្ងៃទី.......... ខែ............. ឆ្នាំ២០២២

**ស្នាមមេដៃស្ដាំ**

**អ្នកប្រគល់សិទ្ធិ**

យល់ព្រមទទួល និងការពារក្ដីឲ្យ

លោក/លោកស្រី..................................

នៅសាលាដំបូងរាជធានី-ខេត្ត ......................

តាមនីតិវិធីច្បាប់។

ថ្ងៃទី......... ខែ.................. ឆ្នាំ២០២២

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យមេធាវី.............

លេខ:............................

**<u>ពាក្យសុំអនុញ្ញាតជួបកូនក្តី</u>**

ខ្ញុំមេធាវី.................... អត្តលេខ:..............សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ............................ត្រូវជា..........................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ .................ចុះថ្ងៃទី......ខែ.........ឆ្នាំ...........របស់សាលាដំបូង.......................................។

**<u>សូមគោរពជូន</u>**

.....................................................................

<u>កម្មវត្ថុ:</u> - សុំអនុញ្ញាតជួបកូនក្តី ឈ្មោះ..............................................................។

<u>យោង:</u> - ពាក្យការពារក្តីចុះថ្ងៃទី.........ខែ..............ឆ្នាំ..............

- មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន..................................................... .....................................................................................................................។

អាស្រ័យហេតុនេះ

សូម........................................មេត្តាអនុញ្ញាតឱ្យខ្ញុំបានជួបកូនក្តីតាមនីតិវិធីច្បាប់។

សូម...................................... ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ.........................., ថ្ងៃទី......... ខែ......... ឆ្នាំ............

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធទី៨**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ......

ថ្ងៃទី...០៦ខែ.០៨ឆ្នាំ២០១៩

ម៉ោង.១៣ ...នាទី.១៥

## ពាក្យបណ្ដឹងដកចិត្ត

ខ្ញុំបាទឈ្មោះ អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ស្រុកល្វាឯម ខេត្តកណ្ដាល។

នាងខ្ញុំឈ្មោះ អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ១៣៦ ភូមិ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ខ្ញុំបាទឈ្មោះ អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិ២៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ខ្ញុំបាទឈ្មោះ អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះ៤៦៦ ភូមិ៦ សង្កាត់បឹងក្រពើ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូង រាជធានីភ្នំពេញ**

***សូមជ្រាបថា!***

**កម្មវត្ថុ ៖** សុំប្ដឹងដកចិត្តលោកចៅក្រម ចេញពីសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូង រាជធានីភ្នំពេញ ។

**យោង ៖** សំណុំរឿងលេខ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

- ដីការកោះ ចុះថ្ងៃទី២៦ ខែ៧ ឆ្នាំ២០១៩ របស់លោកចៅក្រមស៊ើបសួរ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់ សូមជម្រាបជូន**លោកប្រធានសាលាដំបូង រាជធានីភ្នំពេញ** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ លោកចៅក្រមស៊ើបសួរ បានចេញដីការកោះហៅពួកខ្ញុំបាទ/នាងខ្ញុំ ទាំងបួននាក់មកឆ្លើយបំភ្លឺនៅសាលាដំបូង រាជធានីភ្នំពេញ តែដោយសារពួកខ្ញុំបាទ/នាងខ្ញុំទាំងអស់គ្នាជាដើមបណ្ដឹងទាំងបួននាក់យល់ឃើញថា ដោយសារលោកចៅក្រម អ្នកទទួលបន្ទុកជាចៅក្រមស៊ើបនៅក្នុងរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ មិនអាចផ្ដល់ភាពយុត្តិធម៌ជូនពួកខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់បាន ដោយសារលោកចៅក្រមស៊ើបសួរ ធ្លាប់មានទំនាក់ទំនងជាមិត្តភ័ក្ដិជាមួយឈ្មោះ (ដែលជាជនត្រូវចោទ) ហើយកាលរឿងនៅដំណាក់កាលអយ្យការលោកចៅក្រមស៊ើបសួរ បាននាំឈ្មោះ ទៅឆ្លើយនៅតំណាងអយ្យការថែមទៀតផង ដែលជាហេតុនាំមកឱ្យពួកខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់ពុំមានជំនឿទុកចិត្តថាលោកចៅក្រមស៊ើបសួរ និងផ្ដល់ភាពយុត្តិធម៌ជូនពួកខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់បាន។

ហេតុហើយទើបខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់ សុំប្ដឹងដកចិត្តលោកចៅក្រមស៊ើបសួរ ចេញពីសំណុំរឿងព្រហ្មលេខ ២២០៩ ចាប់តាំងពីពេលនេះតទៅ ។ ដោយមានខ្ញុំបាទឈ្មោះ ជាអ្នកតំណាងឱ្យដើមបណ្ដឹង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**លោកប្រធានសាលាដំបូង រាជធានីភ្នំពេញ** មេត្តាជួយពិនិត្យ និងសម្រេចដកលោកចៅក្រមស៊ើបសួរ ចេញពីសំណុំរឿងព្រហ្មខាងលើ តាមការស្នើសុំរបស់ពួកខ្ញុំបាទ/នាងខ្ញុំទាំងបួននាក់ដោយក្ដីអនុគ្រោះផង។

សូម**លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ/នាងខ្ញុំទាំងអស់គ្នា ។

រាជធានីភ្នំពេញ,ថ្ងៃទី...០៨...ខែ..កញ្ញា..ឆ្នាំ២០១៩

**ស្នាមមេដៃស្ដាំ**

ឧបសម្ព័ន្ធទី៩

# ច្បាប់

ស្តីពី

# លក្ខន្តិកៈមេធាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៨៩៥/០៦

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនិងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈមេធាវី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# លក្ខន្តិកៈមេធាវី

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.-

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំពេញវិស័យយុត្តិធម៌ ។

វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី ។

មាត្រា ២.-

មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់ សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿង រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។

ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជន ជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់ ។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ ។

មាត្រា ៣.-

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត ។

មេធាវីអាចត្រូវបានចាត់តាំងដោយតុក្តី ឬចៅក្រមឲ្យបំពេញមុខងារជាអ្នក

ផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាល បាន លុះត្រាតែមាន ច្បាប់អនុញ្ញាត ។

មាត្រា ៤.-

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការ ពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត ។

មាត្រា ៥.-

មេធាវីបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីប្រទេសក្រៅ ឬដែលប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈមេធាវី មានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរហើយអមមេធាវីខ្មែរនៅចំពោះមុខតុលាការ ឬស្ថាប័នដទៃទៀតនៃព្រះរាជាណាចក្រ-កម្ពុជា ។ មេធាវីទាំងនោះពុំអាចតំណាងកូនក្តីបានឡើយ ។

មាត្រា ៦.-

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាគណៈមេធាវីខ្មែរ ផ្អែកលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់មេធាវីនោះ ហើយលុះត្រាតែប្រទេសដើមរបស់មេធាវីបរទេសនោះ ផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរផងដែរ ។ ការយល់ព្រមអាចត្រូវដកហូតវិញបាន បើមានការប្រព្រឹត្តិខុសក្នុងការ ប្រកបវិជ្ជាជីវៈលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីសម្រេចមិនអនុញ្ញាត ឬដកហូតការអនុញ្ញាតរបស់ក្រុមប្រឹក្សាគណៈមេធាវី មិនឲ្យប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងក្នុងរយៈពេល ១៥ ថ្ងៃ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងទៅសាមីខ្លួន ។ សេចក្តីសម្រេចនេះអាចប្តឹងឧទ្ធរណ៍បាន ក្នុងរយៈពេល ២ ខែ ក្រោយពីបានទទួលដំណឹង ។

មាត្រា ៧.-

មេធាវីបរទេសដែលត្រូវបានអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនេះ ពុំអាចធ្វើសកម្មភាព ទាក់ទាញកូនក្តី ឬផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ ។

## ជំពូកទី ២
## ការរៀបចំវិជ្ជាជីវៈមេធាវី
### ផ្នែកទី ១
### គណៈមេធាវី

មាត្រា ៨.-

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មេធាវីម្នាក់ៗត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវី ក្រោយពីចុះឈ្មោះក្នុងបញ្ជី គណៈមេធាវី ។

មាត្រា ៩.-

គណៈមេធាវីត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី ។ ប្រធានគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ២ ឆ្នាំ ។ អាណត្តិនេះអាចត្រូវបានបន្តតែមួយអាណត្តិទៀតដោយវិធីបោះឆ្នោត ។

មាត្រា ១០.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីមាន :

- ចំនួន ៥ នាក់ ក្នុងករណីគណៈមេធាវី មានសមាជិកមិនលើសពី ៣០ នាក់
- ចំនួន ៩ នាក់ បើមានសមាជិកពី ៣១ នាក់ ទៅ ៥០ នាក់
- ចំនួន ១៣ នាក់បើមានសមាជិកពី ៥១ នាក់ទៅ ២០០ នាក់
- ចំនួន ១៩ នាក់ បើមាន សមាជិកពី ២០១ នាក់ ទៅដល់ ៥០០ នាក់
- ចំនួន ២៧ នាក់ បើមានសមាជិកពី ៥០១ នាក់ទៅ ១.០០០ នាក់
- ចំនួន ៣៣ នាក់ បើមានសមាជិកលើសពី ១០០១ នាក់ ។

មាត្រា ១១.-

សមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបន្តម្តងទៀតបាន ប៉ុន្តែមិនអាចបន្តភ្ជាប់ពីចប់អាណត្តក្លាមនោះទេ ។ ផុតរយៈពេល ៣ ឆ្នាំ ក្រោយពីចប់អាណត្តិ ទើបអតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាថ្មីបាន ។ ប្រធានគណៈមេធាវី អាចត្រូវបានបោះឆ្នោតជ្រើសតាំងឲ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីបានក្រោយបានចប់អាណត្តិរបស់ខ្លួន ដោយមិន បាច់រង់ចាំផុតរយៈពេល ៣ ឆ្នាំទេ ។

មាត្រា ១២.-

បើប្រធានគណៈមេធាវី ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាគណៈមេធាវីទទួលមរណភាពឬឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន នោះត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងអ្នកជំនួស ដើម្បីបញ្ចប់អាណត្តិនោះ ។

មាត្រា ១៣.-

គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការសាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ ។

ការសម្តែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់ ។

គណៈមេធាវីមានថវិកាស្វយ័ត ប៉ុន្តែមិនអាចធ្វើសកម្មភាពយកផលចំណេញបានឡើយ ។

## ផ្នែកទី ២

## ការបោះឆ្នោត

មាត្រា ១៤.-

ប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា ក្នុងមហាសន្និបាតនៃគណៈមេធាវី ។ អ្នកដែលមានសិទ្ធិបោះឆ្នោត គឺមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃ

គណៈមេធាវី ហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្ម វិន័យណាមួយឡើយ ។

មាត្រា ១៥.-

អ្នកដែលអាចឈរឈ្មោះឲ្យគេបោះឆ្នោត ជ្រើសតាំងជាប្រធានគណៈមេធាវីបានគឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ៣ ឆ្នាំ យ៉ាងតិច ហើយដែលឥត បានបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយឡើយ ។

អ្នកដែលអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីបាន គឺមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីបានរយៈពេល ២ ឆ្នាំយ៉ាងតិចហើយដែលឥតបានបាត់បង់សិទ្ធិបោះឆ្នោតទាំងនោះ ។

មាត្រា ១៦.-

ការបោះឆ្នោតត្រូវបានរៀបចំឡើងដោយមហាសន្និបាតនៃគណៈមេធាវី ២ ឆ្នាំម្តង ចំពោះប្រធានគណៈមេធាវី និង ៣ ឆ្នាំម្តង ចំពោះសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ។

ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តជាសម្ងាត់ និងជាឯកនាមហើយអាចធ្វើជាពីរលើកបាន ។ ការបោះឆ្នោតលើកទី១ប្រព្រឹត្តទៅដោយយកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិក គណៈមេធាវីទាំងមូល និងលើកទី ២ ដោយយកតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា មេធាវីដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង ។

មាត្រា ១៧.-

បែបបទនៃការបោះឆ្នោត ការកោះអញ្ជើញមករួមប្រជុំ និងកូរ៉ុមត្រូវបានកំណត់ ដោយបទបញ្ជាផ្ទៃក្នុង ។ មេធាវីដែលមានសិទ្ធិបោះឆ្នោត ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងតវ៉ាអំពីការបោះឆ្នោតនេះ ទៅសាលាឧទ្ធរណ៍បាន ។

ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងដោយមេធាវីក្នុងរយៈពេល ១៥ ថ្ងៃក្រោយការបោះឆ្នោត ឬដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ ថ្ងៃ

គិតពីថ្ងៃទទួល ជំណាំងស្តីពីលទ្ធផលនៃការបោះឆ្នោតនោះ ។

## ផ្នែកទី ៣
## មហាសន្និបាត

មាត្រា ១៨.-

មហាសន្និបាតសាមញ្ញនៃគណៈមេធាវីប្រព្រឹត្តទៅមួយឆ្នាំម្តង ដែលផ្តើមធ្វើឡើងដោយប្រធានគណៈមេធាវីតាមរបៀបវារៈដែល ត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ។

មហាសន្និបាតអាចធ្វើសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ ខែ ។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន បើមានមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជី ចំនួន ៣០% បានស្នើសុំដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតគណៈមេធាវី ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។

## ផ្នែកទី ៤
## ក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ១៩.-

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តន៍វិជ្ជាជីវៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ច និងការពារសិទ្ធិរបស់មេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចជាអាទិ៍ដូចតទៅ ៖

- ធ្វើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌
- សំរេចឲ្យចុះឈ្មោះធ្វើកម្មសិក្សា និងចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី

- សំរេចលើការស្នើសុំអនុញ្ញាតទាំងឡាយដែលធ្វើឡើងដោយមេធាវី
- ពិនិត្យកិច្ចព្រមព្រៀងនិងឯកសារទាំងឡាយដែលមេធាវីមានកាតព្វកិច្ចត្រូវដាក់ឲ្យពិនិត្យហើយបញ្ចេញមតិណែនាំលើកិច្ចព្រមព្រៀង និងឯកសារ ទាំងនោះ
- ត្រួតពិនិត្យការកាន់កាប់ទៀងទាត់នៃបញ្ជីគណៈមេធាវីរបស់មេធាវី
- ធានាការគោរពវិន័យ និងការដាក់វិន័យ
- ធានារ៉ាប់រងការរៀបចំ និងការគ្រប់គ្រងសេវាទូទៅរបស់គណៈមេធាវី
- គ្រប់គ្រងទ្រព្យសម្បត្តិ និងថវិការបស់គណៈមេធាវី កំណត់ចំនួនទឹកប្រាក់ភាគទានរបស់មេធាវីម្នាក់ៗ និងបង់ប្រាក់ធានារ៉ូបសំរាប់វិជ្ជាជីវៈមេធាវី
- គ្រប់គ្រងបេឡានៃមូលនិធិរបស់គណៈមេធាវី
- បញ្ចេញមតិលើបញ្ហាទាំងឡាយដែលទាក់ទងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវី ក្នុងវិស័យការពារ ជាអាទិ៍នៅពេលដែលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ ។

មាត្រា ២០.-

ក្រុមប្រឹក្សាគណៈមេធាវីអាចរួមប្រជុំបាន លុះត្រាតែមានសមាជិករបស់ខ្លួនចូលរួម លើសពីពាក់កណ្តាល ។ ក្រុមប្រឹក្សាគណៈមេធាវីសំរេចសេចក្តីតាមមតិភាគច្រើន ។

មាត្រា ២១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានលក្ខណៈជាបទបញ្ជាត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយ មានចុះសេចក្តីថាបានទទួល ។ ចំពោះសេចក្តីសំរេចដាក់វិន័យក៏ដូចជាសេចក្តីសំរេចលើការចុះឈ្មោះ ឬការសុំឲ្យនៅក្រៅបញ្ជីរបស់មេធាវី ក៏ត្រូវធ្វើដូច្នេះដែរ ។ សេចក្តីសំរេចចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវផ្តល់ជាពត៌មានដល់សមាជិកនៃគណៈមេធាវី តាមមធ្យោបាយសមស្រប ។

មាត្រា ២២.-

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីលើមេធាវីណាម្នាក់ ត្រូវជូនដំណឹងទៅមេធាវីនោះតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ២៣.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលមិនមែនជាមុខនាទីរបស់ខ្លួនឬផ្ទុយនឹងបទបញ្ញត្តិច្បាប់ជាធរមានឬបទបញ្ជាអាចត្រូវបដិសេធចោល ដោយសាលាឧទ្ធរណ៍ក្រោយពីមានការប្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មាត្រា ២៤.-

មេធាវីអាចប្តឹងអំពីសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលធ្វើឲ្យ ខាតប្រយោជន៍ដល់វិជ្ជាជីវៈរបស់ខ្លួនបាន ។ បើសេចក្តីសំរេចឥតត្រូវបានឲ្យដំណឹងដល់មេធាវី មេធាវីនោះត្រូវសុំឲ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យសេចក្តីសំរេចនោះសាជាថ្មីម្តងទៀតមុននឹងប្តឹង ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវសំរេចលើសេចក្តីស្នើសុំនោះក្នុងរយៈពេល ២ ខែ ក្រោយពីបានអញ្ជើញមេធាវីនោះឲ្យបញ្ចេញយោបល់របស់ខ្លួន ។ សេចក្តីសំរេចថ្មីត្រូវបានជូនដំណឹងទៅសាមីខ្លួន ។ បើគ្មានការសំរេចសាជាថ្មីក្នុងរយៈពេលដូចកំណត់ខាងលើនេះទេ ត្រូវចាត់ទុកសេចក្តីសំរេចមុននោះជាអសាបង់ ។

មាត្រា ២៥.-

ពាក្យបណ្តឹងទាំងឡាយមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ។ គេអាចដាក់ពាក្យបណ្តឹងទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬតាមលិខិតអនុសិដ្ឋមានចុះសេចក្តីថាបានទទួល ។ រយៈពេលប្តឹងឧទ្ធរណ៍គឺ ២ ខែ ចាប់ពីថ្ងៃទទួលដំណឹង ។

មាត្រា ២៦.-

ក្រុមប្រឹក្សាគណៈមេធាវីត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ

និងផ្សព្វផ្សាយជាសាធារណៈជារៀងរាល់ឆ្នាំ នូវរបាយការណ៍លំអិតស្តីពីសកម្មភាពការងាររបស់គណៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីត្រូវបង្ហាញស្ថានភាពហិរញ្ញវត្ថុនិងផ្តល់ព័ត៌មានផ្សេងៗជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បើមានសំណូមពរពីក្រសួងនេះ ។

## ផ្នែកទី ៥
## ប្រធានគណៈមេធាវី

**មាត្រា ២៧.-**

ប្រធានគណៈមេធាវីមានតួនាទី ៖

- ជាអ្នកដឹកនាំគណៈមេធាវី
- ជាអធិបតីនៃមហាសន្និបាតគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី
- ជាអ្នកធានាផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិកទាំងអស់
- ជាអ្នកផ្សះផ្សា ហើយបើមានការចាំបាច់និងតាមសំណើរបស់គូក្តី ធ្វើអាជ្ញាកណ្តាល ក្នុងវិវាទដែលកើតឡើងរវាងមេធាវីនិងមេធាវី រវាងមេធាវីនិងអតិថិជន
- ជាតំណាងវិជ្ជាជីវៈមេធាវីចំពោះមុខតតិយជននិងអាជ្ញាធរសាធារណៈ
- ជាតំណាងគណៈមេធាវីក្នុងរឿងក្តីដែលទាក់ទងគណៈមេធាវីក្រោយពីមានការអនុញ្ញាតពីក្រុមប្រឹក្សាគណៈមេធាវី ។

ក្នុងការបោះឆ្នោត សំឡេងរបស់ប្រធានគណៈមេធាវីឥតមានឧត្តមានុភាពទេ ។

**មាត្រា ២៨.-**

ប្រធានគណៈមេធាវីអាចផ្ទេរអំណាចណាមួយ ឬអំណាចទាំងអស់ទៅឲ្យសមាជិកណាម្នាក់ ឬច្រើននាក់នៃក្រុមប្រឹក្សាគណៈមេធាវីបាន ក្នុងរយៈពេលមានកំណត់ ។

ក្នុងករណីមានធុរៈ ប្រធានគណៈមេធាវីត្រូវជំនួសដោយសមាជិកនៃ

ក្រុមប្រឹក្សា គណៈមេធាវី ដែលមានវ័យចាស់ជាងគេ ។

## ផ្នែកទី ៦
## មូលនិធិនៃគណៈមេធាវី

មាត្រា ២៩.-

មូលនិធិនៃគណៈមេធាវីបានមកពីការបង់ភាគទាននៃសមាជិកទាំងអស់ និង វិភាគទានផ្សេងៗ ។ នៅក្នុងមូលនិធិនេះត្រូវបង្កើតឲ្យមានបេឡាពិសេសមួយ សំរាប់ផ្តល់ប្រាក់កំរៃ ដល់មេធាវីដែលការពារជនក្រីក្រ ។

បេឡាពិសេសនេះអាចទទួលអំណោយ ឬប្រាក់ជំនួយដែលឯកជន អង្គការ អន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឲ្យដើម្បីការពារជនក្រីក្រ ។

មេធាវីទាំងអស់មានភារកិច្ចជួយការពារជនក្រីក្រ តាមបែបបទនៃបទបញ្ជាផ្ទៃក្នុង ហើយឲ្យដូចជាជួយការពារអតិថិជនរបស់ខ្លួន ។

មាត្រា ៣០.-

ដែលហៅថាជនក្រីក្រ គឺជនដែលគ្មានទ្រព្យសម្បត្តិ គ្មានប្រាក់ចំណូល ឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព ។

ការកំណត់អំពីភាពក្រីក្រ ត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន ។

# ជំពូកទី ៣
# ការទទួលឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី បញ្ជីគណៈមេធាវី

## វគ្គទី ១
## លក្ខខណ្ឌ

មាត្រា ៣១.-

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១- ត្រូវមានសញ្ជាតិជាខ្មែរ

២- ត្រូវមានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល ។

៣- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឲ្យដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

មាត្រា ៣២.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់ ៖

- ចៅក្រម ដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រម ដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ ។

មិនចាំបាច់មានវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈមេធាវី ៖

- អ្នកមានបរិញ្ញាបត្រច្បាប់ ហើយដែលបានបំពេញការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេស ក្រៅ
- អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់ ។

## ផ្នែកទី ២
## ការទទួលឱ្យប្រកបវិជ្ជាជីវៈមេធាវី

មាត្រា ៣៣.-

ការយល់ព្រមឲ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសំរេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីបានត្រួតពិនិត្យលើការបំពេញល័ក្ខខ័ណ្ឌសព្វគ្រប់ដែលមានកំណត់ក្នុងច្បាប់នេះនិងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

សេចក្តីសំរេចត្រូវឲ្យដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្រុមប្រឹក្សាគណៈមេធាវីមិនអាចសំរេចមិនយល់ព្រមដោយគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច១០ថ្ងៃបានឡើយ ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានសេចក្តីបញ្ជាក់ថាបានទទួល ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ ។

មាត្រា ៣៤.-

មេធាវីដែលត្រូវបានទទួលឲ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវី ហើយដែលមានសេចក្តីដូច តទៅ ៖

"ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌

ដោយស្មារតីឯករាជ្យ និងដោយគោរពវិជ្ជាជីវៈនិងក្រមសីលធម៌ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣
## កម្មសិក្សា

មាត្រា ៣៥.-

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ ឆ្នាំ តាមបែបបទ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី លើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឲ្យរួចផុតពីកម្មសិក្សា ។ បែបបទនៃកម្មសិក្សាមានជាអាទិ៍ដូចតទៅ ៖

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ត្រូវចូលរួមបំពេញការងារឲ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ ។

មាត្រា ៣៦.-

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ ។

មាត្រា ៣៧.-

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជី គណៈមេធាវីដោយផ្អែកលើរបាយការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា ។ ក្រុមប្រឹក្សាគណៈមេធាវី អាចសំរេចឲ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឲ្យលើសពី ១ ឆ្នាំ ឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី ចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល ។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជី ឬការ បន្តកម្មសិក្សា ពុំអាចធ្វើទៅបានឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យមកបញ្ចេញយោបល់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៣

សេចក្តីសំរេចនេះអាចនឹងប្តឹងតវ៉ាបានតាមល័ក្ខខ័ណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រា ២៤ និង ២៥ ។

មាត្រា ៣៨.-

រៀលរាល់ឆ្នាំ ក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសិក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្តីទាំងអស់ ។

បញ្ជីនោះមានដូចតទៅ ៖

- ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី និងអាស័យដ្ឋានរបស់មេធាវីនោះ
- ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា ។

មាត្រា ៣៩.-

លេខរៀងនៃការចុះឈ្មោះរបស់មេធាវី ត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធានហើយត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាគណៈមេធាវីដែលបានសំរេចឲ្យចុះឈ្មោះ ។

## ផ្នែកទី ៤
## ការដាក់នៅក្រៅបញ្ជី

មាត្រា ៤០.-

ដោយមានមូលហេតុសមស្រប មេធាវីអាចសុំនៅក្រៅបញ្ជីនៃគណៈមេធាវីបាន សំរាប់រយៈពេលពីរឆ្នាំម្តងៗជាអតិបរមា ។

មាត្រា ៤១.-

ក្រុមប្រឹក្សាគណៈមេធាវីអាចសំរេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជីបើមេធាវីនោះ ស្ថិតនៅក្នុងស្ថានភាពវិសមិតភាព ឬបើមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈ របស់ខ្លួនបាន ។

ក្នុងករណីមានបណ្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេចខាងលើនោះ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

មាត្រា ៤២.-

មេធាវីដែលត្រូវបានដាក់ឲ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ចទាំងឡាយដែលទាក់ទងទៅ នឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី ។

ការដាក់ឲ្យនៅក្រៅបញ្ជីពុំអាចរាំងការចោទប្រកាន់ខាងវិន័យឡើយ ។

## ផ្នែកទី ៥
## ឋានៈជាមេធាវីកិត្តិយស

មាត្រា ៤៣.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្ដល់ងារជាមេធាវីកិត្តិយសជូនមេធាវីដែលឈប់ប្រកបវិជ្ជាជីវៈមេធាវី ក្រោយពីបានប្រកបវិជ្ជាជីវៈរយៈពេល ១៥ ឆ្នាំយ៉ាងតិច ។

មាត្រា ៤៤.-

មេធាវីកិត្តិយសនៅតែជាសមាជិកនៃគណៈមេធាវីដដែល ហើយអាចចូលរួមក្នុងមហាសន្និបាតមេធាវី មានសិទ្ធិផ្ដល់យោបល់ ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗ ។

ដោយឡែក មេធាវីកិត្តិយសអាចផ្ដល់យោបល់ដល់អតិថិជន ហើយអាចត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ជាអ្នកសម្រុះសម្រួល ឬជាអ្នកអាជ្ញាកណ្ដាល ។

មាត្រា ៤៥.-

ក្រុមប្រឹក្សាគណៈមេធាវី អាចដកហូតងារជាមេធាវីកិត្តិយសនេះបាន បើមានហេតុដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬសេចក្ដីថ្លៃថ្នូររបស់មេធាវីនោះ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិ វិធី ដែលមានចែងក្នុងមាត្រា ៣៣ ។

## ជំពូកទី ៤
## បែបបទនៃការប្រកបវិជ្ជាជីវៈ

### ផ្នែកទី ១
### ការប្រកបវិជ្ជាជីវៈមេធាវីជាឯកត្តជន ឬជាសមូហភាព

**មាត្រា ៤៦.-**

មេធាវីអាចប្រកបវិជ្ជាជីវៈជាឯកត្តជនបាន ឬនៅក្នុងក្របខ័ណ្ឌជាក្រុម ឬក្រុមហ៊ុនមេធាវីណាមួយដែលបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ។

ក្រុមហ៊ុននេះត្រូវមានលក្ខណៈជាក្រុមហ៊ុនស៊ីវិល ហើយមានសុទ្ធតែមេធាវីជាសមាជិក ។ មេធាវីកិត្តិយសអាចនៅជាសមាជិកនៃក្រុមហ៊ុនដើមរបស់ខ្លួនបាន ។

សិទ្ធិវន្ត គឺអ្នកដែលមានសិទ្ធិទទួលមរតកពីមេធាវី ដែលបានទទួលមរណភាពអាចបន្តកាន់កាប់ភាគហ៊ុននោះបានក្នុងរយៈពេល ៣ ឆ្នាំជាអតិបរមា ។ ផុតរយៈពេល ៣ ឆ្នាំ នោះ ត្រូវលក់ភាគហ៊ុននោះទៅឲ្យមេធាវីណាម្នាក់ឬទៅឲ្យក្រុមហ៊ុននោះវិញ ។

**មាត្រា ៤៧.-**

ក្រុម និងក្រុមហ៊ុនមេធាវីទាំងឡាយ ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រប់គ្រងក្រុមនិងក្រុមហ៊ុន លើកលែងតែបទបញ្ញត្តិនៃបទបញ្ជានោះប៉ះពាល់ដល់គោលការណ៍គ្រប់គ្រងវិជ្ជាជីវៈមេធាវី ។

**មាត្រា ៤៨.-**

មេធាវីទាំងឡាយត្រូវបានអនុញ្ញាតឲ្យចុះកិច្ចព្រមព្រៀងជាមួយសមាជិកនៃវិជ្ជាជីវៈសេរីដទៃទៀត ដើម្បីប្រមូលផ្តុំមធ្យោបាយជាមួយគ្នា ។ ការធ្វើកិច្ចព្រមព្រៀងនេះមិនត្រូវឲ្យប៉ះពាល់ដល់វិធាននៃវិជ្ជាជីវៈមេធាវី ជាអាទិ៍ប៉ះពាល់ដល់ការគោរពការសម្ងាត់នៃវិជ្ជាជីវៈនេះ ។

មាត្រា ៤៩.-

រាល់កិច្ចព្រមព្រៀងដែលមេធាវីខ្មែរណាម្នាក់បានចុះជាមួយមេធាវីខ្មែរណាម្នាក់ទៀត ឬជាមួយមេធាវីបរទេស ឬក៏ជាមួយសមាជិកនៃវិជ្ជាជីវៈសេរីណាមួយ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ហើយជូនពត៌មានដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្នុងករណីនេះត្រូវអនុវត្តនីតិវិធីដែលមានចែងក្នុងមាត្រា ៣៣ ។

## ផ្នែកទី ២
## កិច្ចសហការ

មាត្រា ៥០.-

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងលក្ខណៈជាសហការីរបស់មេធាវីម្នាក់ទៀត ។

មាត្រា ៥១.-

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាគា ។ គេពុំអាចបំពេញកិច្ចការបានទេ បើគ្មានការយល់ព្រមពីសហភាគា ប៉ុន្តែគេមានសិទ្ធិពេញទីក្នុងការជ្រើសរើសមធ្យោបាយធ្វើការងាររបស់គេ។គេអាចសុំមិនទទួលបំពេញ បេសកកម្មណាមួយ ដែលគេយល់ថាផ្ទុយនឹងសម្បជញ្ញៈរបស់គេ ។

មាត្រា ៥២.-

ក្នុងករណីណាក៏ដោយ កិច្ចសហការមិនអាចរារាំងមិនឲ្យសហការីមេធាវីបង្កើតការិយាល័យផ្ទាល់របស់គេ ឬរាំងមិនឲ្យគោរពកាតព្វកិច្ចនិងវិធាននៃវិជ្ជាជីវៈមេធាវីបានឡើយ ។ គេធ្វើការក្នុងនាមគេផ្ទាល់ កាលណាគេការពារកូនក្តីគេផ្ទាល់ខ្លួន ។

កិច្ចសន្យានៃកិច្ចសហការត្រូវរៀបចំឡើង ហើយផ្ញើជូនក្រុមប្រឹក្សាគណៈមេធាវី ។

## ជំពូកទី ៥
## វិធាននៃវិជ្ជាជីវៈ បទវិន័យ

### ផ្នែកទី ១
### វិសមិតភាព

មាត្រា ៥៣.-

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរពាណិជ្ជកម្ម ទោះការប្រកបនោះដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ។

មាត្រា ៥៤.-

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។

មាត្រា ៥៥.-

មេធាវីដែលជាអតីតមន្ត្រីរាជការ អាចធ្វើបទអន្តរាគមន៍ការពារក្តីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនបាន លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃឈប់ពីមុខងាររបស់ខ្លួន ។

### ផ្នែកទី ២
### បទវិន័យ

មាត្រា ៥៦.-

វិធាននៃវិជ្ជាជីវៈមេធាវីត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈ-មេធាវី ។ វិធាននេះធានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន ។

មាត្រា ៥៧.-

គ្រប់អំពើទាក់ទាញ ប្រកាសផ្សាយជាឯកត្តជន ឬទទូចសុំការពាររបស់មេធាវី ចំពោះអតិថិជនត្រូវហាមឃាត់ ។

មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឲ្យធ្វើបាន ។ ការប្រកាសផ្សាយនេះ ត្រូវធ្វើឲ្យបានត្រឹមត្រូវ ហើយមិនត្រូវឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មេធាវី ឡើយ ។

មាត្រា ៥៨.-

មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត ។ មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារ ផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក ។

មេធាវីពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាច ត្រូវបានបង្ខំឲ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួនទោះបីនៅមុខតុលាការក៏ដោយ ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្ដល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជន របស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជន ផ្ញើទាក់ទងគ្នា ។

## ផ្នែកទី ៣
## ទណ្ឌកម្មជាបទវិន័យ

មាត្រា ៥៩.-

ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

មាត្រា ៦០.-

ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាគណៈមេធាវីខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវីចាត់មេធាវីម្នាក់ឲ្យធ្វើជាអ្នករាយការណ៍ ។ ការប្តឹងត្រូវជូនដំណឹងជាមុនទៅសាមីខ្លួនដែលត្រូវដឹងពីសំណុំរឿងនៃការប្តឹងនោះ និងអាចបញ្ចេញយោបល់ការពារខ្លួនបាន ។ បើមានការស៊ើបអង្កេត ក៏ត្រូវផ្តល់ពត៌មាននោះទៅសាមីខ្លួនដែរ ។ របាយការណ៍ត្រូវផ្ញើជូនសាមីខ្លួនជាមួយនឹងលិខិតកោះអញ្ជើញ ហើយសំណុំរឿងក៏ត្រូវដាក់ឲ្យ សាមីខ្លួនពិនិត្យដែរ ។ លិខិតកោះអញ្ជើញត្រូវតែផ្ញើតាមលិខិតអនុសិដ្ឋដោយមានចុះសេចក្តីថា បានទទួល ឬជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងតិចមុនថ្ងៃប្រជុំ ។ សាមីខ្លួនអាចជ្រើសរើសយកមេធាវីម្នាក់ឲ្យការពារខ្លួនបាន ។ ប៉ុន្តែសាមីខ្លួនពុំអាចអវត្តមានដោយ ឲ្យជនណាម្នាក់ធ្វើជាតំណាងជួសខ្លួនបានឡើយ បើគ្មានការអនុគ្រោះយល់ព្រមជាពិសេស ជាមុនដោយមានមូលហេតុសមស្របទេ ។

បើគ្មានការឆ្លើយតបទៅនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ឬរបស់តតិយជនក្នុង រយៈពេល ២ ខែទេ ការមិនឆ្លើយតបពីក្រុមប្រឹក្សាគណៈមេធាវីត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃផុតរយៈ ពេល ២ ខែខាងលើ ។

មាត្រា ៦១.-

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីដែលមានមូលហេតុច្បាស់លាស់ត្រូវបានជូនដំណឹងទៅសាមីខ្លួន និងអគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេចតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួល ។

មាត្រា ៦២.-

ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយសាមីខ្លួន ឬដោយអគ្គព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ក្នុងថិរៈវេលា និងតាមទម្រង់ដែលមានចែងក្នុងមាត្រា ២៥ ។ បណ្តឹងឧទ្ធរណ៍ត្រូវជំនុំជំរះជាសម្ងាត់ លើកលែងតែមានសេចក្តីសំរេចផ្ទុយ

ពីនេះរបស់សេចក្ដីសម្រេចវិន័យ តាមការស្នើសុំច្បាស់លាស់ពីមេធាវីដែលត្រូវចោទ ។ គណៈមេធាវីមិនមែនជាភាគីក្នុងរឿងក្ដីនេះទេ ប៉ុន្តែប្រធានគណៈមេធាវីត្រូវតែបញ្ចេញយោបល់កត់សំគាល់របស់ខ្លួន ហើយអគ្គព្រះរាជអាជ្ញាត្រូវធ្វើការសន្និដ្ឋាននៅពេលនោះ ។

មាត្រា ៦៣.-

ទណ្ឌកម្មជាបទវិន័យ មានដូចតទៅ ៖

- ការព្រមាន
- ការស្ដីបន្ទោស
- ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ២ ឆ្នាំ
- ការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការ ហូតងារកិត្តិយស ។

មាត្រា ៦៤.-

ទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលអាចព្យួរបាន ។ ប៉ុន្តែបើក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីបានប្រកាសទោសព្យួរនេះ មេធាវីនោះត្រូវបានផ្ដន្ទាទោសវិន័យថ្មីមួយទៀត ក្នុងករណីនេះត្រូវអនុវត្តទោសហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈដោយយកទោសថ្មីទៅបូកជាមួយ ទោសចាស់ដែលបានព្យួរ ។

មាត្រា ៦៥.-

គ្រប់ទណ្ឌកម្ម អាចត្រូវបានបន្ថែមទណ្ឌកម្មហាមឃាត់មិនឲ្យបំពេញជាប្រធានគណៈមេធាវី ឬជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។ សេចក្ដីសំរេចដាក់ទណ្ឌកម្មនេះត្រូវកំណត់ផងដែរ អំពីការផ្សាយជាសាធារណៈ បើជាការចាំបាច់ត្រូវផ្សាយ ។

មាត្រា ៦៦.-

ក្រុមប្រឹក្សាគណៈមេធាវីអាចផ្អាកពីមុខងារជាបណ្ដោះអាសន្ន ចំពោះមេធាវីណា ដែលបានត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬពីបទវិន័យណាមួយ ដោយបញ្ញត្តិ ឬតាមបណ្ដឹងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បើគ្មាន

សេចក្តីសំរេចពីក្រុមប្រឹក្សាគណៈមេធាវីឆ្លើយ តបទៅនឹងការការប្តឹងរបស់អគ្គព្រះរាជអាជ្ញាក្នុងរយៈពេល ២០ ថ្ងៃ នោះនឹងត្រូវចាត់ទុកជាការបដិសេធបណ្តឹងនោះ ។

មាត្រា ៦៧.-

ការផ្អាកពីមុខងារជាបណ្តោះអាសន្នពុំអាចសំរេចបានឡើយ បើគ្មានការកោះអញ្ជើញសាមីខ្លួនឲ្យចូលមកបញ្ចេញយោបល់របស់ខ្លួន ។ ការកោះអញ្ជើញត្រូវធ្វើឡើងតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានចុះសេចក្តីថាបានទទួលហើយដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៥ ថ្ងៃ មុនថ្ងៃប្រជុំ ។ ការផ្អាកពីមុខងារជាបណ្តោះអាសន្នអាច ត្រូវប្តឹងឧទ្ធរណ៍បានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦២ ។ ការប្តឹងឧទ្ធរណ៍ពុំអាចផ្អាកការអនុវត្តន៍សេចក្តីសំរេចខាងលើបានឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជានា និងឃ្លាំមើលការអនុវត្តន៍ទណ្ឌកម្មខាងវិន័យ និងការផ្អាកពីមុខងារជាបណ្តោះអាសន្ន ។

## ផ្នែកទី ៤
## កំរៃ

មាត្រា ៦៨.-

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារតាមទំហំ សមត្ថភាពដែលបានបញ្ចេញក្នុងការងារនោះ តាមការលំបាកនៃការងារតាមលទ្ធផលដែលសំរេចបាន ឬតាមតារាងប្រាក់ម៉ោងកំណត់ដោយ គណៈមេធាវីរៀងរាល់ឆ្នាំ ។ មេធាវីត្រូវចេញបង្កាន់ដៃ ឲ្យអតិថិជននៅពេលបានប្រាក់កំរៃ ។

មាត្រា ៦៩.-

ការតវ៉ាអំពីកំរៃ ក្រៅពីប្តឹងទៅតាមនីតិវិធីរដ្ឋប្បវេណី អាចប្តឹងទៅប្រធានគណៈមេធាវីជាអាជ្ញាកណ្តាលសំរេចបាន បើមានការយល់ព្រមពីភាគីទំនាស់ ។ សេចក្តីសំរេចត្រូវឲ្យដំណឹងទៅសាមីខ្លួន តាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់

ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួល ។ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើក្នុងរយៈពេល ២ ខែ ក្រោយថ្ងៃទទួលបណ្ដឹង ។ ពាក្យបណ្ដឹងត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឬផ្ញើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ ផ្ទាល់ដៃដោយមានចុះសេចក្ដីថាបានទទួល ។ បណ្ដឹងឧទ្ធរណ៍នេះត្រូវជំនុំជំរះដោយប្រធានសាលាឧទ្ធរណ៍ ឬដោយអ្នកទទួលសិទ្ធិពីប្រធានសាលាឧទ្ធរណ៍ ។

## ជំពូកទី ៦
## គណនេយ្យ ការប្រើប្រាស់មូលនិធិ
## ការធានា ប្រាក់ធានារ៉ាប់រង

មាត្រា ៧០.-

មេធាវីដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវី មិនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់មូលនិធិរបស់អតិថិជន ឬមូលនិធិទុកសំរាប់អតិថិជនក្នុងពេលដែលខ្លួនបំពេញបេសកកម្មឲ្យអតិថិជនទេ ។ មូលនិធិនេះបានមកពីប្រាក់ធានាក្ដី និងបានមកពីប្រាក់សំណងដែលឈ្នះក្ដី ។ មេធាវីត្រូវដាក់មូលនិធិនេះក្នុងគណនីពិសេសមួយដែលបើកឡើងដោយគណៈមេធាវី ហើយមាន ឈ្មោះថា «បេឡាទូទាត់របស់គណៈមេធាវី» ។

មេធាវីពុំអាចរក្សាទុកមូលនិធិនេះនៅក្នុងបេឡានោះឲ្យលើសពីថិរៈវេលាចាំបាច់ ដើម្បីសំរេចកិច្ចការដែលអតិថិជនប្រគល់ឲ្យនោះទេ ។ គេពុំអាចកាត់យកកំរៃដែលគេត្រូវទទួល ក្នុងការសំរេចលទ្ធផលការងារពីមូលនិធិខាងលើនេះឡើយ លើកលែងតែមានការយល់ព្រមជា លាយលក្ខណ៍អក្សរពីអតិថិជន ។

មេធាវីអាចយកមូលនិធិដែលអតិថិជនបានតម្កល់ទុកសំរាប់បង់ប្រដាប់ក្ដី និងកំរៃ អ្នកជំនួយការយុត្តិធម៌ទៅបង់ជំនួសអតិថិជនបាន ។

មាត្រា ៧១.-

មេធាវីអាចត្រូវបានតែងតាំងជាអ្នកទទួលទុកបញ្ញើ តាមការព្រមព្រៀងពីភាគី ឬពីចៅក្រម ។ កិច្ចព្រមព្រៀង ឬសេចក្ដីសំរេចអំពីការទទួលទុកបញ្ញើត្រូវកំណត់បែបបទ ជាពិសេស បែបបទនៃការប្រាក់ ព្រមទាំងបែបបទបញ្ចប់ទទួល

ទុកបញ្ញើ ។ មូលនិធិ ឬវត្ថុទាំងឡាយ ត្រូវរក្សាទុកក្នុងបេឡាទូទាត់របស់គណៈមេធាវី ។

មាត្រា ៧២.-

មេធាវីត្រូវមានគណនេយ្យវិជ្ជាជីវៈមួយដោយឡែកស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ ការទូទាត់ប្រើមូលនិធិ ឬវត្ថុបញ្ញើត្រូវធ្វើឡើងក្នុងគណនេយ្យមួយដោយឡែក ។

មេធាវីត្រូវបង្ហាញបញ្ជីគណនេយ្យវិជ្ជាជីវៈរបស់ខ្លួន និងត្រូវបង្ហាញបញ្ជីគណនេយ្យផ្ទាល់ខ្លួនប្រសិនបើមាន ដល់អ្នកត្រួតពិនិត្យ ចាត់តាំងឡើងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា ៧៣.-

មេធាវីត្រូវបង្ហាញថាខ្លួនបានបង់ប្រាក់ធានារ៉ាប់រងតាមរយៈគណៈមេធាវី សំរាប់ ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ និងធានារ៉ាប់រងការសងមូលនិធិ និងរបស់មានតម្លៃទាំងឡាយដែលខ្លួនបានទទួលទុក ។ ប្រាក់ធានានោះត្រូវគិតបញ្ចូលក្នុងប្រាក់បង់វិភាគ-ទាន ដែលកំណត់ដោយគណៈមេធាវី ។

## ជំពូកទី ៧

## ការជំនួស ការខាររដ្ឋបាល

មាត្រា ៧៤.-

មេធាវីដែលអាក់ខានប្រកបវិជ្ជាជីវៈរបស់ខ្លួនជាបណ្ដោះអាសន្ន អាចចាត់តាំងអ្នកជំនួសម្នាក់ដោយមានការយល់ព្រមពីប្រធានគណៈមេធាវី ។ បើគ្មានការចាត់តាំងជំនួសទេនោះ ប្រធានគណៈមេធាវីចាត់តាំងអ្នកជំនួសដោយបញ្ញត្តិ ។

មាត្រា ៧៥ -

សេចក្ដីសំរេចហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈកាល ឬផ្អាកការប្រកប

វិជ្ជាជីវៈជាបណ្តោះអាសន្ន ឬដាក់នៅក្រៅបញ្ជីគណៈមេធាវី ត្រូវចាត់តាំងមេធាវីម្នាក់ឲ្យគ្រប់គ្រងការិយាល័យមេធាវីជំនួស ។ បើអ្នកគ្រប់គ្រងការិយាល័យនោះមានធុរៈ ប្រធានគណៈមេធាវីត្រូវចេញសេចក្តីសំរេចចាត់តាំងអ្នកជំនួស ។

មាត្រា ៧៦ -

បើមេធាវីម្នាក់ទទួលមរណភាព ឬឈប់ប្រកបវិជ្ជាជីវៈរបស់ខ្លួន ប្រធានគណៈមេធាវីចាត់តាំងមេធាវីម្នាក់ឲ្យទទួលបន្ទុកចាត់ការលើសំណុំរឿង ដែលនៅសល់ និងជម្រះបញ្ជីគណនេយ្យ រួចបិទការិយាល័យ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

មាត្រា ៧៧.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១ ២ ៣ ៤ ៥ ៦ ៧ ១៣ និង ៥៧ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀលទៅដល់ ៥.០០០.០០០ រៀល ។ បើបទល្មើសនោះ ប្រព្រឹត្តឡើងដោយជនបរទេស ជននោះអាចត្រូវបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាថែមទៀត ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យទ្វេមួយជាពីរ និងអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ដល់ ៦ ខែ ។

បើមានបទល្មើសខាងលើនេះ ក្រុមប្រឹក្សាគណៈមេធាវីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ។

មាត្រា ៧៨.

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ។

# ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

មាត្រា ៧៩.-

តួនាទីការពារកូនក្ដីរបស់មេធាវីក្នុងរឿងព្រហ្មទណ្ឌអាចត្រូវបំពេញបានដោយអ្នកការពារក្ដី ដែលមិនមែនជាមេធាវី តាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

មាត្រា ៨០.-

អាចត្រូវបានជ្រើសរើសឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលមេធាវី ៖

- អ្នកការពារកូនក្ដីដែលមានលទ្ធភាពបំពេញមុខងារនេះ ហើយដែលបំពេញមុខងារនេះពិតប្រាកដ និងជាប់រហូត ២ ឆ្នាំមក នៅតាមតុលាការខេត្ត ក្រុង ។ អ្នកការពារកូនក្ដីទាំងនេះ ត្រូវមានកម្រិតចេះដឹងឧត្ដមសិក្សាពី ២ ឆ្នាំឡើងទៅ ។
- មន្ត្រីរាជការដែលបានបម្រើការងាររដ្ឋ ២ ឆ្នាំ យ៉ាងតិច ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សានីតិសាស្ត្រ ។

អ្នកដែលមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល មិនចាំបាច់ប្រឡងទេ ។

មាត្រា ៨១.-

អាចទទួលឲ្យចុះឈ្មោះ ក្នុងបញ្ជីសំរាប់ឲ្យប្រឡងចូលរៀនក្នុងវគ្គបណ្ដុះបណ្ដាលមេធាវីបាន ស្របតាមមាត្រាខាងលើ អ្នកដែលមិនដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ

មាត្រា ៨២.-

វគ្គបណ្ដុះបណ្ដាលមានរយៈពេលយ៉ាងតិច ៨ ខែ ។ កម្មវិធី និងបែបបទនៃវគ្គបណ្ដុះបណ្ដាលព្រមទាំងកម្មវិធី និងបែបបទនៃការប្រឡង ដើម្បីត្រួតពិនិត្យ លទ្ធផលនៃការបណ្ដុះ បណ្ដាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាគណៈមេធាវី ។

អ្នកដែលប្រឡងជាប់ និងត្រូវទទួលវិញ្ញាបនប័ត្រសមត្ថភាព សំរាប់ប្រកបវិជ្ជាជីវៈមេធាវី ។

មាត្រា ៨៣.-

មិនចាំបាច់មានវិញ្ញាបនប័ត្រសមត្ថភាពខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់ធ្វើកម្មសិក្សា ចំពោះ ៖

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ឬអ្នកមានសញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល ហើយបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការរយៈពេល ២ ឆ្នាំ យ៉ាងតិច
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់
- ចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរយៈពេលយ៉ាងតិច ២ ឆ្នាំ ។

មាត្រា ៨៤.-

មុនពេលបង្កើតបានគណៈមេធាវី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានភារកិច្ចទទួលនិងពិនិត្យពាក្យសុំប្រកបវិជ្ជាជីវៈមេធាវី ហើយកោះអញ្ជើញអ្នកដែលបានបំពេញលក្ខខណ្ឌសព្វគ្រប់ ឲ្យមកធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ដើម្បីបំពេញឋានៈជាមេធាវី និងចូលរួមមហាសន្និបាតបង្កើតគណៈមេធាវី ។

មាត្រា ៨៥.-

មហាសន្និបាតត្រូវរៀបចំបោះឆ្នោត ក្រោមការទទួលខុសត្រូវរបស់មេធាវីដែលមានវ័យចាស់ជាងគេ ដើម្បីជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី

មាត្រា ៨៦.

មួយឆ្នាំក្រោយមកទៀត ត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មីម្នាក់ និងក្រុមប្រឹក្សាគណៈមេធាវីថ្មីមួយ ដោយមេធាវីទាំងអស់ដែលបានចុះឈ្មោះក្នុងបញ្ជីគណ;មេធាវី ។

មាត្រា ៨៧.-

ក្នុងករណីចាំបាច់ អាណត្តិនៃក្រុមប្រឹក្សាគណៈមេធាវី និងប្រធានគណៈមេធាវីដែល ជាប់ឆ្នោតលើកដំបូង ត្រូវបន្តរហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីថ្មី និងក្រុមប្រឹក្សាគណៈមេធាវីថ្មី ។

មាត្រា ៨៨.-

ដោយមិនទាន់គិតដល់មាត្រា ១៤ និងមាត្រា ១៥ អ្នកដែលមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតដូចមានចែងក្នុងមាត្រា ៨៤ គឺមេធាវីទាំងឡាយដែលបានចុះឈ្មោះក្នុងបញ្ជីនៃគណៈមេធាវី និងក្នុងបញ្ជីកម្មសិក្សាដោយមិនគិតពីអតីតភាព ។

មាត្រា ៨៩.-

អនុក្រឹត្យ... 

# ជំពូកទី ១០
## អវសានប្បញ្ញត្តិ

មាត្រា ៩០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥
ព្រះហស្តលេខា
នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា
ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខា
ចែម ស្ងួន

លេខ ..ន.ស.ច.ល.

[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ១៩៩៥
[illegible]
[illegible] សាន់

**ឧបសម្ព័ន្ធទី១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

*លេខ:*

**លិខិតជូនដំណឹងស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះ**

យើង ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧, មាត្រា ៣៦៨, មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៦១៣/០០៩ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៨។

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

ជម្រាបមក ៖ ឈ្មោះ ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ ជា ជនត្រូវចោទ។ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ:

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើ យើងបានស៊ើបសួរចប់សព្វគ្រប់ហើយ និងបានសម្រេចបញ្ជូនរឿងនេះទៅជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ តាមនីតិវិធីរួចហើយ។

ហេតុដូច្នេះ សូម ជ្រាបជាដំណឹង។

*ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២*

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

ចៅក្រមស៊ើបសួរ

យើង .................................. បានប្រគល់លិខិតជូនដំណឹងនេះឱ្យឈ្មោះ .................................. មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះលេខ: ........... ផ្លូវលេខ: ........... ក្រុមទី ........... ភូមិ .................. ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ .................. ខេត្ត/ក្រុង/រាជធានី .................. នៅថ្ងៃទី ......... ខែ ............ ឆ្នាំ ............. ដោយផ្ទាល់ដៃរួចហើយ។

| | |
|---|---|
| **អ្នកទទួល** | **អ្នកប្រគល់** |
| (ហត្ថលេខា ឬស្នាមមេដៃស្តាំ) | |

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**********

**តុលាការខេត្ត-ក្រុង**

..........................

*********

លេខ ......................

# ដីកាបង្គាប់ឱ្យចូលខ្លួន(១)

********

យើង .......................................... ចៅក្រមស៊ើបអង្កេតនៃ តុលាការខេត្ត-ក្រុង ...................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ..................... ចុះថ្ងៃទី ............. ខែ ..................... ឆ្នាំ...................។

បានឃើញដីកាកោះលេខៈ .................. ចុះថ្ងៃទី ............... ខែ ..................ឆ្នាំ .......................... ដែលឈ្មោះ ............................................ បានទទួលរួចហើយ កាលពីថ្ងៃទី ............... ខែ ................... ឆ្នាំ ................. ប៉ុន្តែឈ្មោះនេះ មិនបានចូលខ្លួនមកបំភ្លឺនៅចំពោះមុខតុលាការតាមកាលកំណត់ទេ។

បង្គាប់មកឈ្មោះ ...................................... ភេទ.............. អាយុ ........... ឆ្នាំ ជាតិ ............................... ទីលំនៅបច្ចុប្បន្ន នៅភូមិ.......................ឃុំ-សង្កាត់ ................................ ស្រុក-ខណ្ឌ ......................................... ខេត្ត-ក្រុង ............................................ឱ្យចូលខ្លួនទៅកាន់តុលាការខេត្ត-ក្រុង ................................................ នៅថ្ងៃទី............ ខែ ..................... ឆ្នាំ .................... វេលាម៉ោង ............................... ដើម្បី .........................

..................................................................................................................................................................

ពីដំណើររឿងដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខៈ ................ ចុះថ្ងៃទី ......... ខែ .................ឆ្នាំ .................។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ *យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន* ។

ធ្វើនៅ....................... ថ្ងៃទី......... ខែ.......... ឆ្នាំ .........

**ចៅក្រមស៊ើបអង្កេត**

**ឧបសម្ព័ន្ធទី១២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**

សំណុំរឿងព្រហ្មទណ្ឌ
លេខ
លេខ:......

# ដីកាសន្និដ្ឋានស្ថាពរ

**យើង** **តំណាងអយ្យការអមសាលាដំបូង**

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី

បានឃើញសំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី
របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង

បានឃើញដីកាបញ្ជូនរឿងឲ្យពិនិត្យលេខ ចុះថ្ងៃទី
ឆ្នាំ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា :**

១-នាមត្រកូល និងនាមខ្លួន ភេទ អាយុ ឆ្នាំ ជាតិ
មុខរបរ ទីកន្លែងកំណើតនៅ
ទីលំនៅបច្ចុប្បន្ននៅ
ទោសពីមុន
គ្មាន ឪពុកឈ្មោះ ស ម្ដាយឈ្មោះ រ ប្រពន្ធឈ្មោះ
រ និតិជន ☑ ឬអនីតិជន☐ ។

១-នាមត្រកូល និងនាមខ្លួន ហៅ ភេទ អាយុ
ឆ្នាំ ជាតិ មុខរបរ ទីកន្លែងកំណើតនៅ
ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ
ទោសពីមុន គ្មាន ឪពុក
ឈ្មោះ រ ម្ដាយឈ្មោះ រ ប្រពន្ធឈ្មោះ រ
មានកូន នាក់ និតិជន ☑ ឬអនីតិជន☐ ។

**យល់ឃើញថា**[២] :

-តាមចម្លើយរបស់ឈ្មោះ ដោះសារថា ខ្លួនពុំបញ្ជាឲ្យឈ្មោះ ឲ្យធ្វើឯកសារខ្យល់ទេ ហើយរាល់ឯកសារដែលខ្លួនចុះហត្ថលេខាឲ្យដកប្រាក់ គឺសុទ្ធតែមានអតិថិជនត្រឹមត្រូវ និងមានចុះហត្ថលេខាពីអាជ្ញាធរភូមិ-សង្កាត់ដឹងឮ ហើយឆ្លងកាត់បុគ្គលិក និងឈ្មោះ ជាអ្នកពិនិត្យ និងបញ្ជាក់ ថាគ្រប់គ្រាន់រួចបញ្ជូនមកឲ្យខ្លួនចុះហត្ថលេខា ទើបឈ្មោះ យកប្រាក់ប្រគល់ឲ្យអតិថិជន ។ ការដោះសារគ្មានភស្តុតាងណាបញ្ជាក់ ពុំអាចឲ្យតំណាងអយ្យការជឿបានឡើយ ។

-តាមចម្លើយរបស់ឈ្មោះ ហៅ អះអាងថា ខ្លួនពិតជាបានប្រាប់មន្ត្រីឥណទានឈ្មោះ , ឈ្មោះ និងឈ្មោះ ឲ្យធ្វើឯកសារក្លែងប្រាកដមែន ដោយឈ្មោះ ជាអ្នកបញ្ជាឲ្យធ្វើ ហើយគាត់ប្រាប់ថាគាត់ជាអ្នកទទួលខុសត្រូវទាំងអស់ ។ ចំពោះឯកសារ ក្លែងក្លាយរៀបចំហើយ ខ្លួនបានបញ្ជូនទៅឲ្យឈ្មោះ ហើយគាត់ក៏ចុះហត្ថលេខាលើឯកសារទាំងនេះ រួចបញ្ជាឲ្យខ្លួនដកប្រាក់តាមឯកសារក្លែងទាំងអស់។

-តាមចម្លើយរបស់ឈ្មោះ , ឈ្មោះ ឈ្មោះ ឈ្មោះ , ឈ្មោះ , ឈ្មោះ , និងឈ្មោះ សារភាពថា ឈ្មោះ និងឈ្មោះ ជាអ្នកបញ្ជាឲ្យពួកខ្លួនរៀបចំឯកសារខ្យល់សំរាប់បញ្ចេញប្រាក់ឲ្យអតិថិជនខ្ចី ដោយពុំមានអតិថិជនណាខ្ចីប្រាក់ទេ គឺបានរកស្នាមមេដៃអ្នកផ្សេងដទៃមកផ្តិត ដើម្បីបូកបញ្ចីប្រាក់ឲ្យបានត្រឹមត្រូវកុំឲ្យធ្លាក់លើស្មួរនាំពួកគេ ។ ចម្លើយអះអាងនេះមានលក្ខណៈស៊ីសង្វាក់ នឹងចម្លើយអះអាងរបស់ឈ្មោះ អាចឲ្យតំណាងអយ្យការពិចារណាបាន ។

-យោងតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចែងពីការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង បានកំណត់ថា បទបញ្ញត្តិថ្មីដែលចែងអំពីទោស ដែលស្រាលជាងត្រូវអនុវត្តភ្លាម ដូច្នេះគប្បីតំណាងអយ្យការកែប្រែបទចោទប្រកាន់លើឈ្មោះ ភេទ អាយុ ឆ្នាំ និងឈ្មោះ ភេទ អាយុ ឆ្នាំ ពីបទ: **រំលោភលើសេចក្តីទុកចិត្ត និងក្លែងលិខិតឯកជន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ ដល់ឆ្នាំ តាមមាត្រា ៤៦ និងមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកបទ រំលោភលើ

[២] សំអាងហេតុ សំអាងច្បាប់

ដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ២៩ មាត្រា ៣៩១ និ. មាត្រា ៣៩២ . មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

## ហេតុដូច្នេះ

**ប្តឹងសុំឲ្យចៅក្រមស៊ើបសួរ សម្រេច:**

☑ បញ្ជូនជនត្រូវចោទឈ្មោះ ៖

១- ភេទ អាយុ ឆ្នាំ

២- ភេទ អាយុ ឆ្នាំ

៣- ភេទ អាយុ ឆ្នាំ

៤- ភេទ អាយុ ឆ្នាំ

៥- ភេទ អាយុ ឆ្នាំ

៦- ភេទ អាយុ ឆ្នាំ

៧- ភេទ អាយុ ឆ្នាំ

៨- ភេទ អាយុ ឆ្នាំ

៩- ភេទ អាយុ ឆ្នាំ ទៅជំនុំជម្រះ។

ធ្វើនៅអយ្យការ, ថ្ងៃទី

**តំណាងអយ្យការ**

**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី១៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ:.......
ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៥
សំណុំរឿងព្រហ្មទណ្ឌ

**សេចក្តីប្តឹងឧទ្ធរណ៍**

លេខ:... ....... ឆ្នាំ[illegible] ខែ...វិច្ឆិកា ......ថ្ងៃ ព្រហស្បតិ៍.........
ចុះថ្ងៃទី១៥ ខែ[illegible] ឆ្នាំ២០១[illegible] វេលាម៉ោង...... ព្រឹក.....................។
របស់សាលាដំបូងរាជធានីភ្នំពេញ

យើង. ..........អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាល
សាលាឧទ្ធរណ៍ភ្នំពេញ។

បានឃើញ [illegible]..........................
.....................................................................................។
ចូលមកចំពោះមុខយើង ដែលប្តឹងឧទ្ធរណ៍នឹង [illegible] ចុះថ្ងៃទី ១០ ខែ
តុលា ឆ្នាំ ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។..........
.....................................................................................
ត្រង់ចំណុច [illegible] ។..........
.....................................................................................
.....................................................................................
.....................................................................................
.........................................។

ជ. អគ្គព្រះរាជអាជ្ញា
អគ្គព្រះរាជអាជ្ញារង
[signature]

អគ្គលេខាធិការ
[signature]

**ឧបសម្ព័ន្ធទី១៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ២៤០១
ចុះថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ២០១៦
លេខ៖

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

## យើង តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញរបាយការណ៍សំយោគលេខ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ[1]។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា ៖

នាម-គោត្តនាមៈ កឹម សុខា ភេទប្រុស អាយុ ៦៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម កើតនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៥៣ ទីកន្លែងកំណើត ឃុំខ្ពបស្វាយ ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [illegible] ។

អង្គហេតុនៃសំណុំរឿងមានដូចតទៅ[2]៖ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បាននិងកំពុងចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៨.០៣.២០១៦ ទាក់ទងនឹងអំពើពេស្យាកម្ម ។ នៅក្នុងសំណុំរឿងនេះ តំណាងអយ្យការធ្វើការកោះហៅ ចំនួនពីរលើក ៖

- កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានធ្វើការកោះហៅ ក្នុងឋានៈជាសាក្សី ដើម្បីចូលមកបំភ្លឺនៅចំពោះមុខតំណាងអយ្យការ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ៨ ព្រឹក ប៉ុន្តែ មិនបានចូលខ្លួនមកបំភ្លឺក្នុងឋានៈជាសាក្សី តាមដីកាកោះហៅរបស់តំណាងអយ្យការឡើយ។

- នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ តំណាងអយ្យការបានចេញដីកាកោះហៅជាលើកទី ២ ម្តងទៀត ដើម្បីអញ្ជើញ មកឆ្លើយបំភ្លឺក្នុងឋានៈជាសាក្សី នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ៨ ព្រឹក ប៉ុន្តែ នៅតែមិនចូលខ្លួនមក បំភ្លឺនៅចំពោះមុខតំណាងអយ្យការដដែល ដោយគ្រាន់តែ

ស្រមោចារីរបស់ខ្លួនចំនួន ៥ រូប បញ្ចូលលិខិតមួយច្បាប់មក អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយមាន បញ្ជាក់មូលហេតុមិនសមស្រប ។

អង្គហេតុខាងលើ ជាបទល្មើសជាក់ស្តែង គឺ បទបដិសេធក្នុងការចូលខ្លួន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា *"ការបដិសេធរបស់អ្នកដែលត្រូវបានកោះហៅឲ្យមកធ្វើជាសាក្សីនៅមុខអយ្យការ ឬ ចៅក្រមស៊ើបសួរ ឬ មុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល"* ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**សម្រេច**

បើកការស៊ើបសួរចំពោះអង្គហេតុខាងលើ និង ឃ្មីសុំ៖

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ [3]

-ឈ្មោះ ភេទប្រុស អាយុ ៦៣ ឆ្នាំ (គ្មានខ្លួន) ។

☑ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ [4]

*ធ្វើនៅអយ្យការ, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦*

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី១៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គម្រូពាក្យស្នើសុំដោះលែងកូនក្តីឱ្យនៅក្រៅឃុំ**

បាទ/នាងខ្ញុំមេធាវី................ អត្តលេខ............... ជាសមាជិកមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី....................................... មានទីតាំងស្ថិតនៅផ្ទះលេខ............... ផ្លូវ.................. ភូមិ................. ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................. ខេត្ត/រាជធានី................................ ទូរស័ព្ទលេខ .............................។

**សូមគោរពចូលមក**

**លោក ............... ចៅក្រមទទួលបន្ទុករឿងក្តី សាលាដំបូង.................**

**កម្មវត្ថុ:** សំណើសុំឱ្យកូនក្តីឈ្មោះ............ ជាប់ចោទពីបទ .................... ឱ្យ នៅក្រៅឃុំបណ្តោះអាសន្ន ។

**យោង:** -សំណុំរឿងព្រហ្មទណ្ឌលេខ......... ចុះថ្ងៃទី....... ខែ...... ឆ្នាំ....... របស់សាលាដំបូង............

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ............ ថ្ងៃទី......... ខែ.......... ឆ្នាំ.......... របស់សាលាដំបូង..........

-ពាក្យការពារក្តី ចុះថ្ងៃទី...... ខែ...... ឆ្នាំ......... ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជំរាបជូន **លោក ចៅក្រម** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី..........ខែ................ឆ្នាំ.........កូនក្តីខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................................... ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូង .............. សម្រេចឃុំខ្លួនបណ្តោះអាសន្ន ពីបទ............... តាមបញ្ញត្តិមាត្រា............ នៃក្រមព្រហ្មទណ្ឌ។

ដោយសារកូនក្តីខ្ញុំបាទ/នាងខ្ញុំ ..........................................................................។

យោងតាមមាត្រា **២០៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា **ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព" ដូចនេះ** ក្នុងនាមនាងខ្ញុំ ជាមេធាវីការពារជនត្រូវចោទទាំងពីរនាក់ខាងលើ ស្នើសុំ **លោក ចៅក្រម** ដោះលែង កូនក្តី ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន **ដោយមូលហេតុ ដូចខាងក្រោម** ៖

១/- កូនក្តីខ្ញុំបាទ/នាងខ្ញុំ មានទីលំនៅច្បាស់លាស់ អាចបង្ហាញខ្លួនតាមការកោះហៅ របស់តុលាការ និងអាចអនុវត្តកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលា ។

២/- នីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌បានបញ្ចប់ ហេតុនេះ ការសម្រេចឱ្យកូនក្តីនាងខ្ញុំ បាននៅក្រៅឃុំ គឺមិនប៉ះពាល់ដល់ការប្រមូលភស្តុតាងឡើយ ។

៣/- កូនក្តីខ្ញុំបាទ/នាងខ្ញុំ ជាជនស្លូតត្រង់ និងពុំធ្លាប់ប្រព្រឹត្តបទល្មើស ឬបង្កឱ្យ មានសកម្មភាពប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈពីមុនមកនោះទេ។

៤/- កូនក្តីខ្ញុំបាទ/នាងខ្ញុំ នឹងមិនប្រព្រឹត្ត ឬបង្កការលំបាក ឬរាំង ដល់ការស៊ើបសួររបស់ ចៅក្រមស៊ើបសួរ ដោយប្រការណាមួយឡើយ។

៥/- កូនក្តីខ្ញុំបាទ/នាងខ្ញុំ សុំដាក់ប្រាក់តម្កល់ចំនួន........................ ដើម្បីធានាខ្លួននៅក្រៅឃុំ។

អាស្រ័យហេតុនេះ សូម **លោក ចៅក្រម** មេត្តាពិនិត្យ និងសំរេចតាមការស្នើសុំដូចមាននៅក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ ។

សូម **លោក ចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ/ខ្ញុំបាទ ។

ធ្វើថ្ងៃទី........ ខែ......... ឆ្នាំ.............

**ហត្ថលេខា និងត្រា**

**មេធាវី**

**ឧបសម្ព័ន្ធទី១៦**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

## ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

បន្ទប់ស៊ើបសួរ យើង ចៅក្រមស៊ើបសួរសាលាដំបូង

លេខ ដ.ព.ស អមដោយលោកស្រី ជាក្រឡាបញ្ជីសាលាដំបូង

-បានឃើញ មាត្រា២០៣, ២០៤, ២០៥ និងមាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ អ.យ.យ ចុះថ្ងៃទី

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី ដែលទាក់ទងនឹង:

-នាមត្រកូល និងនាមខ្លួន ( ) ភេទប្រុស អាយុ ឆ្នាំ ជនជាតិ សាសនា មុខរបរបុគ្គលិកក្លឹបរាត្រី ទីកន្លែងកំណើតនៅភូមិ

ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ

ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" ប្រពន្ធឈ្មោះ កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច កាលពីថ្ងៃទី

បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ និងការកត់សម្គាល់របស់ភាគី

## I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១. នៅក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ ត្រូវចោទពីបទ រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជាបទឧក្រិដ្ឋ។

២. ប្រព្រឹត្តនៅចំណុច កាលពីថ្ងៃទី

**សង្ខេបអង្គហេតុនៃរឿង៖** កាលពីថ្ងៃទី មន្ត្រីអង្គការ ប្រចាំនៅ ឈ្មោះ ជនជាតិ បានផ្តល់ព័ត៌មានមកនាយកដ្ឋានកណ្តាលសន្តិសុខ នៃក្រសួងមហាផ្ទៃថា មានករណីជួញដូរគ្រឿងញៀនឆ្លងដែនចំនួន គីឡូក្រាម ពីប្រទេស ចូលមក ដោយធ្វើចរាចរណ៍ឆ្លងកាត់ ហើយត្រូវបញ្ជូនបន្តទៅ ការជួញដូរគ្រឿងញៀនដ៏ធំនេះ គឺធ្វើឡើងដោយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ហើយដែលមានជនសង្ស័យ ជាប្រើប្រាស់លេខទូរស័ព្ទ គឺជាអ្នកចាំទទួលទំនិញ និងមានក្រុមជនសង្ស័យផ្សេងទៀតជាអ្នករៀបចំបញ្ជូនទំនិញនៅប្រទេស ឆ្លងកាត់ ។ ក្រោយពីទទួលបានពត៌មាននេះសមត្ថកិច្ចក៏បានធ្វើការស៊ើបអង្កេតស្រាវជ្រាវរហូតកំណត់មុខសញ្ញាមួយចំនួន ដែលពាក់ព័ន្ធក្នុងករណីប្រគល់ ទទួលគ្រឿងញៀននេះ ទើបនៅថ្ងៃទី សមត្ថកិច្ចនាយកដ្ឋានកណ្តាលសន្តិសុខ នៃក្រសួងមហាផ្ទៃ បានឃាត់ជន

សង្ស័យឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ នៅចំណុច ដោយបានដកហូតវត្ថុតាងរួមមាន ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀន ប្រភេទ មានទម្ងន់ ក្រាម ( រ៉ៃក្រាម) និងរថយន្តចំនួន ០១គ្រឿងម៉ាក ឆ្នាំ ពណ៌ផ្ទៃមេឃ ពាក់ផ្លាកលេខ បន្ទាប់មកដោយមានកិច្ចសហការណ៍ពីជននេះនៅថ្ងៃទី សមត្ថកិច្ចក៏បានបន្តឃាត់ខ្លួនឈ្មោះ ភេទប្រុស អាយុ ជនជាតិ ចំណុចផ្លូវលេខ ចូលវត្ត ហើយបាននាំជនសង្ស័យទៅឆែកឆេរនៅ ដោយបានដកហូតវត្ថុតាងរួមមាន សារធាតុរាវជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ក្រាម ក្រាមសជាសារធាតុញៀនប្រភេទ ក្រាម សារធាតុញៀនប្រភេទ ទម្ងន់ ក្រាម ម្សៅម៉ត់ពណ៌សសង្ស័យជាសារធាតុញៀន (មិនច្បាស់) ទម្ងន់ ក្រាម ម្សៅម៉ត់ពណ៌លឿងសង្ស័យជាសារធាតុញៀន (មិនច្បាស់) ទម្ងន់ ក្រាម ម្សៅគ្រៀមពណ៌សសង្ស័យជាសារធាតុញៀន (មិនច្បាស់) ទម្ងន់ ក្រាម សារធាតុ ទម្ងន់ ក្រាម ទម្ងន់ ក្រាម, ទម្ងន់ ក្រាម, សារធាតុរាវសង្ស័យជាសារធាតុញៀន (មិនច្បាស់) ទម្ងន់ ក្រាម, ថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យជាសារធាតុញៀន ទម្ងន់ ក្រាម, ជញ្ជីងសម្រាប់ថ្លឹងសារធាតុញៀនចំនួន ០១គ្រឿង, កុំព្យូទ័រយួរដៃពណ៌ខ្មៅចំនួន ០១គ្រឿង និងឧបករណ៍សម្ភារៈ ព្រមទាំងសារធាតុគីមីសម្រាប់ផលិត កែច្នៃគ្រឿងញៀនមួយចំនួនធំ និងរថយន្តចំនួន ០១គ្រឿងម៉ាក ឆ្នាំ ពណ៌ខ្មៅ ពាក់ផ្លាកលេខ បន្ទាប់មកទៀតដោយមានការចង្អុលបង្ហាញពីឈ្មោះ នៅថ្ងៃទី សមត្ថកិច្ចក៏បានបន្តធ្វើការឆែកឆេរនៅចំណុចផ្ទះលេខ

ដោយបានដកហូតវត្ថុតាងរួមមានៈ សារធាតុរាវពណ៌ខ្មៅចំនួន ធុង -១A(ពណ៌ថ្លា) ចំនួន ២ ធុង ទម្ងន់ គីឡូក្រាម (មិនច្បាស់) និង -១B សារធាតុរាវពណ៌ខ្មៅ ១ធុង ទម្ងន់ គីឡូក្រាម (មិនច្បាស់), សារធាតុរាវថ្លាប្រភេទ មាន ធុងជ័រខៀវ និង ប៊ីដុង ទម្ងន់សរុប គីឡូក្រាម, សារធាតុរាវ កាន ទម្ងន់ គីឡូងក្រាម, សារធាតុរាវ ប៊ីដុង ពណ៌ប្រផេះ ចំនួន ទម្ងន់ គីឡូក្រាម, សារធាតុរាវ ចំនួន ដប ទម្ងន់ គីឡូក្រាម, សារធាតុរាវ (ដបសថ្លា) ចំនួន ដប ទម្ងន់ គីឡូក្រាម (មិនច្បាស់) ក្រាមស , ចំនួន បាវ ទម្ងន់ គីឡូក្រាម, ម្សៅម៉ត់ស ទម្ងន់ គីឡូក្រាម (មិនច្បាស់), ម្សៅម៉ត់ខ្មៅ (កាបូន) ចំនួន បាវ ទម្ងន់ គីឡូក្រាម និងអំបិលម៉ត់ស ទម្ងន់ គីឡូក្រាម ហើយនៅថ្ងៃដដែលសមត្ថកិច្ចក៏បន្តទៅឆែកឆេរនៅចំណុចទីតាំងឃ្លាំងគ្មានលេខ ផ្លូវលេខ

ដោយដកហូតវត្ថុតាងបានមួយចំនួនរួមមានៈ ឧបករណ៍បង្គោលពុម្ពសម្រាប់វាយគ្រាប់ថ្នាំចំនួន កំប្លេ(ឡូហ្គោរូប ចំនួន ឡូហ្គោរូប ចំនួន និងឡូហ្គោរូបសញ្ញា ចំនួន ), ម៉ាស៊ីនសម្រាប់អុកគ្រាប់ថ្នាំចំនួន គ្រឿង និងម៉ូទ័រចំនួន គ្រឿង បញ្ជូនមកអយ្យការអមសាលាដំបូង

ដើម្បីចាត់ការតាមចបាប់ ដោយឡែកមេក្លោងផ្សេងៗទៀតរួមមានៈ ឈ្មោះ ភេទប្រុស ជនជាតិ ថៅកែមិនស្គាល់អត្តសញ្ញាណ ស្នាក់នៅ , ថៅកែមិនស្គាល់អត្តសញ្ញាណ ស្នាក់នៅប្រទេសឡាវ, ថៅកែមិនស្គាល់អត្តសញ្ញាណ ភេទ ជនជាតិ

ឈ្មោះ ភេទ ជនជាតិ សញ្ជាតិ ថៅកែក្រុមហ៊ុនដឹកជញ្ជូន ឈ្មោះ ភេទប្រុស ជនជាតិ និងអ្នកគ្រប់គ្រងសណ្ឋាគារ បានរត់គេចខ្លួនបាត់។

៣. តំណាងអយ្យការបានស្នើសុំឱ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិខ្មែរ ដោយហេតុថា ដើម្បី៖

ក. បញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី

ខ. ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

គ. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

ឃ. ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

៤. ជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ ស្នើសុំតុលាការមេត្តាកុំសម្រេចឃុំខ្លួនលើរូបខ្លួន ហើយសុំតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង។

## II. សំអាងហេតុនៃសេចក្ដីសម្រេច

៥. ជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ ត្រូវចោទពីបទឧក្រិដ្ឋ ដែលច្បាប់កំណត់ដាក់ពន្ធនាគារលើសពី ០១(មួយ)ឆ្នាំ (មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦. ការឃុំខ្លួនជនត្រូវចោទចាំបាច់គឺ៖

ក. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី បើទុកជនត្រូវចោទឱ្យនៅក្រៅឃុំ ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសសារជាថ្មី។

ខ. ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត បើមិនឃុំខ្លួនជនត្រូវចោទ ជនត្រូវចោទអាចនឹងផ្ដល់ព័ត៌មានដល់បក្ខពួកឲ្យរត់គេចខ្លួន។

គ. ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ដោយហេតុថា បើទុកជនត្រូវចោទឱ្យនៅក្រៅឃុំ ជនត្រូវចោទអាចនឹងរត់គេចខ្លួន។

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរ៉ឹង និងមានប្រសិទ្ធិភាពអាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចនូវគោលដៅខាងលើ។

### ហេតុដូច្នេះសម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ ដែលមានសាវតាជាតិដូចខាងលើជាបណ្ដោះអាសន្នរយៈពេលអតិបរមា ០៦ (ប្រាំមួយ) ខែ។

ថ្ងៃ

រាជធានីភ្នំពេញ

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

**ឧបសម្ព័ន្ធទី១៧**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

## ដីកាបង្គាប់ឱ្យឃុំខ្លួន

មន្ទីរឃុំឃាំង                យើង                ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

លេខ                ដ.ឃ.ជ

-បានឃើញ មាត្រា២០៦, ២១៩, ២២០, ២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ          ចុះថ្ងៃទី                    ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ                ចុះថ្ងៃទី

-បានឃើញ សំណុំរឿងស៊ើបសួរលេខ          ចុះថ្ងៃទី                ដែលទាក់ទងនឹង:

-នាមត្រកូល និងនាមខ្លួន                    ភេទ      អាយុ      ឆ្នាំ ជនជាតិ      សាសនា

មុខរបរបុគ្គលិ                    ទីកន្លែងកំណើតនៅភូមិ

ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ

ឪពុកឈ្មោះ          "រស់" ម្ដាយឈ្មោះ          "រស់" ប្រពន្ធឈ្មោះ                កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច                ) កាលពីថ្ងៃទី                បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ .          . "ល" ដ.ព.ស ចុះថ្ងៃទី

## បង្គាប់

១-ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ (                ) ភេទ      អាយុ      ឆ្នាំ ជនជាតិ      ទៅ **មណ្ឌលអប់រំកែប្រែទី១ (ម១)** ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

២-ឱ្យ **ប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១)** ទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈ    ទាំងអស់សហការអនុវត្តឱ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃ

រាជធានីភ្នំពេញ ថ្ងៃទី

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៨**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

បន្ទប់ស៊ើបសួរ
លេខ:

## ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូង

អមដោយលោកស្រី ជាក្រឡាបញ្ជី។

-បានឃើញមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី

-បានឃើញដីកាបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី

-បានឃើញកំណត់ហេតុពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី

យោបល់របស់តំណាងអយ្យការថា: មិនមានមូលហេតុឃុំខ្លួនតាមមាត្រា ២០៥ ទេ គប្បីដាក់ជនត្រូវចោទឲ្យជាប់កាតព្វកិច្ចតាមផ្លូវតុលាការ។

-បានឃើញកំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទឈ្មោះ ចុះថ្ងៃទី របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ចុះថ្ងៃទី ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ដើម្បីធានាសំណងដល់ដើមបណ្ដឹងរដ្ឋប្បវេណី។

-បានឃើញលិខិតអះអាង ចុះថ្ងៃទី របស់ឈ្មោះ អះអាងថា ល់នៅផ្ទាន

ដែលមានប័ណ្ណកាន់កាប់អចលនវត្ថុលេខ: ចុះថ្ងៃទី ជារបស់ខ្លួននោះមានតម្លៃសរុបប្រហែល ( អាមេរិក) ជាតម្លៃសព្វថ្ងៃ។

ក្រោយពីបានសាកសួរចម្លើយជនត្រូវចោទចប់សព្វគ្រប់ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

### ហេតុដូច្នេះសម្រេច:

មិនឃុំខ្លួនឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិ កើតនៅថ្ងៃទី មុខរបរ កើតនៅ

ទីលំនៅបច្ចុប្បន្ននៅ

ឪពុកឈ្មោះ -ស- ម្ដាយឈ្មោះ -ទ- ប្រពន្ធឈ្មោះ

* ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ដែលត្រូវចោទប្រកាន់ពីបទ **រំលោភលើសេចក្តីទុកចិត្ត និងក្លែងលិខិតឯកជន** ប្រព្រឹត្តនៅ កាលពីឆ្នាំ ដល់ឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៤៦ និងមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

រាជធានីភ្នំពេញ ថ្ងៃទី

| បានទទួលដំណឹង | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |
|---|---|---|
| រាជធានីភ្នំពេញ ថ្ងៃទី | | |
| **ជ.ព្រះរាជអាជ្ញា** | | |
| ព្រះរាជអាជ្ញារង | | |

**ឧបសម្ព័ន្ធទី១៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ៛ ៚

សាលាដំបូងរាជធានីភ្នំពេញ
ចូល
ក្រឡាបញ្ជី
លេខ...
ថ្ងៃទី០១ ខែ០៤ ឆ្នាំ២០២០
ម៉ោង ១០ និង ...នាទី

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ០៣ ខែ 04 ឆ្នាំ 2020
ក្រឡាបញ្ជី

**ពាក្យបណ្តឹងឧទ្ធរណ៍**

**ព្រះរាជអាជ្ញារង** នៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ ៖** សុំប្តឹងឧទ្ធរណ៍ នឹង ដីកាសម្រេចមិនឃុំខ្លួន លេខ: ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរ នៃ សាលាដំបូងរាជធានីភ្នំពេញ គ្រប់សេចក្តីសម្រេចទាំងមូល ។

**យោង ៖** - សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០ ចៅក្រមស៊ើបសួរ នៃ សាលាដំបូងរាជធានីភ្នំពេញ បានដីកាសម្រេចមិនឃុំខ្លួន លេខ: ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០ ដូចក្រោម ៖

មិនឃុំខ្លួនឈ្មោះ ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិស្តុះ ឃុំស្តុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ៨១ ផ្លូវលេខ២៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរអ្នកជំនួញ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ប្រពន្ធឈ្មោះ "រ" មានកូន ០៤ នាក់ ទោសពីមុន៖ គ្មាន ជាទីគិជន ។

ដែលចោទប្រកាន់ពីបទ៖ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ.២០១៩ និងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

តំណាងអយ្យការយល់ឃើញថាការសម្រេច របស់ ចៅក្រមស៊ើបសួរ លើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៥១ឆ្នាំ ផ្ទុយទៅនឹងមាត្រា ២៣១ នៃ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ចែងថា បុគ្គលណាដែល ៖

-មានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ដោយការដកហូត ឬ ការដកប្រាក់ពីគណនីសម្រាប់ទូទាត់មូលប្បទានប័ត្រ

-ជាប់បំណុលលើឧបករណ៍អាចជួញដូរបាន ដោយមានចេតនាមិនទូទាត់សងឧបករណ៍នោះនៅពេលដល់កាលប្រតិទាន

-មិនបំពេញកាតព្វចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់កាលប្រតិទាន ដោយមានបំណង និងដោយមានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ពីរ (០២) លាន ដល់ ប្រាំមួយ (០៦) លាន រៀល និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ពី មួយ (០២) ឆ្នាំ ទៅ បី (០៣) ឆ្នាំ ដោយមិនទាន់គិតដល់កាតព្វកិច្ចទូទាត់សងចំនួន ប្រាក់ នៃឧបករណ៍អាចជួញដូរបាននោះទៅអ្នកកាន់ ។

ដូចនេះ ការសម្រេចរបស់ចៅក្រមស៊ើបសួរ មិនឃុំខ្លួនជនត្រូវចោទ ឈ្មោះ ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ ផ្ទុយទៅនឹងមាត្រា ២៣១ នៃ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាទទួលយកពាក្យបណ្តឹងឧទ្ធរណ៍ និងចាត់ការទៅតាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការគោរពអំពីខ្ញុំបាទ ។

ថ្ងៃ ពុធ ០៩ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០

តំណាងអយ្យការ

ព្រះរាជអាជ្ញារង

**បានឃើញ និងឯកភាព**

**ព្រះរាជអាជ្ញា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 03 ខែ 04 ឆ្នាំ 2020

ក្រឡាបញ្ជី

**ឧបសម្ព័ន្ធទី២០**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គម្រូពាក្យបណ្ដឹងសាទុក្ខ**

បាទ/នាងខ្ញុំមេធាវី................ អត្តលេខ............... ជាសមាជិកមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី........................................ មានទីតាំងស្ថិតនៅផ្ទះលេខ............... ផ្លូវ.................. ភូមិ.................. ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................. ខេត្ត/រាជធានី................................ ទូរស័ព្ទលេខ .............................ជាមេធាវីការពារក្ដីឱ្យឈ្មោះ.................។

**សូមគោរពចូលមក**

**ឯកឧត្តម ប្រធាន សាលាឧទ្ធរណ៍**.................

**កម្មវត្ថុ:** ប្ដឹងសាទុក្ខនឹងសាលដីកាលេខះ........................ចុះថ្ងៃទី.........ខែ..........ឆ្នាំ...................របស់សភាស៊ើបសួរ ត្រង់សេចក្ដីសម្រេចទាំងមូល។

**យោង:** -សំណុំរឿងព្រហ្មទណ្ឌលេខ......... ចុះថ្ងៃទី....... ខែ...... ឆ្នាំ....... របស់.............................។

-លិខិតប្រគល់សិទ្ធិឱ្យប្ដឹងសាទុក្ខ ចុះថ្ងៃទី...........ខែ.............ឆ្នាំ..................។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម ប្រធាន** មេត្តាជ្រាបថាៈ លោក/លោកស្រី........................បានប្រគល់សិទ្ធិឱ្យខ្ញុំបាទ/នាងខ្ញុំធ្វើបណ្ដឹងសាទុក្ខនឹងសាលដីកាលេខះ..........ចុះថ្ងៃទី............ខែ...............ឆ្នាំ.............របស់សភាស៊ើបសួរ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ប្រធាន** ទទួលយកនូវបណ្ដឹងសាទុក្ខរបស់ខ្ញុំបាទ/នាងខ្ញុំដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម ប្រធាន** ទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបានទ/នាងខ្ញុំ៕

ធ្វើថ្ងៃទី.......... ខែ............. ឆ្នាំ២០២២

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធទី២១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## គម្រូលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................ថ្ងៃខែឆ្នាំកំណើត........................ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖.......................................ចុះថ្ងៃទី.............................មានទីលំនៅស្ថិតនៅ .........................ទូរស័ព្ទលេខ៖.....................................................។

## សូមប្រគល់សិទ្ធិជូន

**ក្រុមហ៊ុនមេធាវី/ក្រុមមេធាវី/ការិយាល័យមេធាវី**...........................................មានទីតាំងស្ថិតនៅ......................................................ដើម្បីធ្វើបណ្តឹងសាទុក្ខនឹងសាលដីកាសម្រេចរបស់សភាស៊ើបលេខ៖.......................ចុះថ្ងៃទី........ខែ..........ឆ្នាំ..............របស់សាលាឧទ្ធរណ៍............ជំនួសនាងខ្ញុំ/ខ្ញុំបាទឈ្មោះ..................................នៅសាលាឧទ្ធរណ៍..............តាមនីតិច្បាប់៕

លិខិតប្រគល់សិទ្ធិនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃផ្តិតមេដៃ ឬចុះហត្ថលេខានេះតទៅ៕

ធ្វើថ្ងៃទី.......... ខែ............. ឆ្នាំ២០២២

**ស្នាមមេដៃស្តាំ**
**អ្នកប្រគល់សិទ្ធិ**

ព្រមទទួលធ្វើបណ្តឹងសារទុក្ខ
ជូនលោក/លោកស្រី..............
ថ្ងៃទី......... ខែ.................. ឆ្នាំ២០២២
**ហត្ថលេខា និងត្រា**
**មេធាវី**

**ឧបសម្ព័ន្ធទី២២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**លិខិតជូនដំណឹង**
**ឱ្យដាក់សារណាការពារ**

**តុលាការកំពូល**

**ប្រាប់មក**

ឈ្មោះ ........

អាយុ ......... ឆ្នាំ សញ្ជាតិ .................. អាសយដ្ឋានផ្ទះលេខ ................... ផ្លូវលេខ ............ ភូមិ ...[illegible]... ឃុំ/សង្កាត់ ...[illegible]... ស្រុក/ខណ្ឌ .......................... រាជធានីភ្នំពេញ/ខេត្ត ......កណ្ដាល...ជាអ្នកប្ដឹងសាទុក្ខ ឱ្យដាក់សារណាជូនមកប្រធាន (សភាព្រហ្មទណ្ឌ/សភាពេញអង្គ) តុលាការកំពូល ដោយរៀបរាប់អំពីមូលហេតុ និងមធ្យោបាយខាងផ្លូវច្បាប់ ដែលខ្លួនប្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ចុះថ្ងៃទី...០៤...ខែ...តុលា...ឆ្នាំ...២០២១ របស់(សភាស៊ើបសួរ/សភាព្រហ្មទណ្ឌ) នៃសាលាឧទ្ធរណ៍...ភ្នំពេញ...ក្នុងរយៈពេល **២០ថ្ងៃ** ជាកំណត់ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះតទៅ តាមមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃ...[illegible]... ខែ...[illegible]... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១

**ត.ប. ប្រធានតុលាការកំពូល**

[signature]

**ឧបសម្ព័ន្ធទី២៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការ អមតុលាការកំពូល

លេខ :..........

លោកព្រះរាជអាជ្ញារង....................ពិនិត្យ

រាជធានីភ្នំពេញ. ថ្ងៃទី២៧ ខែ១០ ឆ្នាំ២០២០
ព្រះរាជអាជ្ញា

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ..........
ថ្ងៃទី27 ខែ10 ឆ្នាំ២០20
ម៉ោង 1530 នាទី

# ដីកាបញ្ជូន

ជម្រាបមក. ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | -ដីកាបង្គាប់ឲ្យដោះលែងឈ្មោះ របស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ | ០១ច្បាប់ | (ដើម្បីអនុវត្ត) |
| ២ | -សាលដីកាព្រហ្មទណ្ឌលេខ លេខ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌតុលាការកំពូល។ | ០១ច្បាប់ | |

សរុបៈ ០២ ច្បាប់

ថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

អគ្គព្រះរាជអាជ្ញា

មហាវិថី សម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-២១២ ៨២៦ ទូរសារ : ៨៥៥-២៣-២១២ ៨២៦
Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia Tel : 855-23-212 826 Fax : 855-23-212-826

# ឧបសម្ព័ន្ធទី២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ [redacted]

## ដីកាបញ្ជូន

**គោរពជូន: លោកប្រធានពន្ធនាគាររាជធានីភ្នំពេញ**

| ល.រ | រាយនាមលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាបង្គាប់ឱ្យដោះលែងឈ្មោះ [redacted] របស់អគ្គព្រះរាជអាជ្ញាអម តុលាការកំពូល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ។<br>-សាលដីកាព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌ តុលាការកំពូល ។<br>-ដីកាបញ្ជូនលេខ [redacted] ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់មហាអយ្យការអម តុលាការកំពូល ។ | ០១ ច្បាប់ | "ដើម្បីចាត់បញ្ជូនសំណុំឯកសារ ស្តីពីដីកាបង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌ តុលាការកំពូល" ដែលបង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ខាងលើ ចេញពីមណ្ឌលឃុំខ្លួន ប្រសិនបើបុគ្គលឈ្មោះនេះ មិនត្រូវបានឃុំខ្លួននៅក្នុងរឿងក្តីផ្សេងទៀតនោះទេ ។ |
| | សរុប | ១២ សន្លឹក | |

ថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២០
**តំណាងអយ្យការ**

បានទទួល 28.10.20

[redacted]

[redacted]

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ [redacted]

ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

សាលដីកា

លេខ [redacted]

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.លោកជំទាវ [redacted] ចៅក្រម

៥.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើពាក្យបណ្តឹងសាទុក្ខលេខ [redacted] ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចំពោះសាលដីកាព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

- **ជនត្រូវចោទឈ្មោះ** [redacted] "អ្នកប្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរពាណិជ្ជករ ទីកន្លែងកំណើត ភូមិស្រែតាកោ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ ៣៧២ ក្រុម ០៣ ផ្លូវបេតុង ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០) ។
- លោក [redacted] ជាមេធាវីការពារសិទ្ធិ

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទប្រុស កើតឆ្នាំ១៩៥៨ ជនជាតិកូរ៉េ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ មានទីលំនៅបច្ចុប្បន្ន ផ្លូវទំនប់កប់ស្រូវ ភូមិត្រពាំងពោធិ៍ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ (ដង្កោ) រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ ៖**

កាលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោះ [redacted] បានប្រើឧបាយកលទុច្ចរិត ដោយបានចុះកិច្ចសន្យាទិញលក់ដីជាមួយឈ្មោះ [redacted] ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន [redacted] ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ (ដង្កោ) រាជធានីភ្នំពេញ ក្នុងតម្លៃ ១៥ លានដុល្លារអាមេរិក ។ ក្រោយមកថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ [redacted] បានឱ្យឈ្មោះ [redacted] ផ្ទេរភាគហ៊ុន ១០០% ឱ្យខ្លួន ហើយក្នុងអំឡុងពេលនោះដែរ ឈ្មោះ [redacted] បានលួចផ្ទេរអចលនទ្រព្យទាំងអស់នោះចេញពីក្រុមហ៊ុន មកជាទ្រព្យឯកជនរបស់ខ្លួនតែម្តង និងយកទៅបញ្ចាំនៅធនាគារ យកប្រាក់ចាយវាយជាប្រយោជន៍ផ្ទាល់ខ្លួន ពុំបានយកប្រាក់មកទូទាត់ឱ្យមកឈ្មោះ [redacted] តាមការសន្យាឡើយ ។ ដើម្បីលាក់បាំងអំពីចេតនាទុច្ចរិតជាមួយនឹងជនរងគ្រោះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ឈ្មោះ [redacted] បានធ្វើជាចុះកិច្ចព្រមព្រៀងប្រគល់ដីទាំងអស់ឱ្យជនរងគ្រោះវិញ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ ។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងប្រគល់ដីខាងលើឱ្យមកជនរងគ្រោះវិញនោះ ឈ្មោះ [redacted] បានដំណើរការតាមនីតិវិធីផ្ទេរអចលនទ្រព្យទាំងនោះឱ្យមកជនរងគ្រោះវិញឡើយ ។

- បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នលេខ [redacted] ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

មិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន លើជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរពាណិជ្ជករ ទីកន្លែងកំណើតភូមិស្រែតាកោ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៣៧២ ក្រុម ០៣ ផ្លូវបេតុង ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] "វ" មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] "វ" ជាទីតាំង ។

ដែលត្រូវជាប់ចោទពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ [redacted] ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ របស់ជនត្រូវចោទឈ្មោះ [redacted] ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នលេខ [redacted] ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ [redacted] ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ទទួល បណ្ដឹងឧទ្ធរណ៍លេខ [redacted] ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២.តម្កល់ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នលេខ [redacted] ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣.សាលដីកានេះ ប្រកាសជាអសាធារណៈ នៅថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ។

បើកសិទ្ធិសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ [redacted] ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

- ចៅក្រមបានអានរបាយការណ៍ ។

- តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា ៖

- យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

- យល់ឃើញថា លើសាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចតម្កល់ដីកាសម្រេចមិនអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន ដោយលើកសំអាងហេតុថា សំណុំរឿងនេះត្រូវបានចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរ រួចចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿង និងជនជាប់ចោទរូបនេះទៅជំនុំជម្រះ [illegible]

សភាស៊ើបសួរមិនពិចារណាលើការសុំនៅក្រៅឃុំឡើយ ។ ការសម្រេចរបស់សាលាឧទ្ធរណ៍ ត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

ហេតុដូច្នេះ

តំណាងមហាអយ្យការ ប្ដឹងសុំក្រុមប្រឹក្សាសម្រេច

- តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ។

សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតាមច្បាប់ ។

**+លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា ៖**

ទី១ ខ្ញុំសុំរក្សានៅសារណាការពារសិទ្ធិកូនក្ដីខ្ញុំបាទដាក់ចូលតុលាការកំពូល ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ទាំងមូលដដែល ។

បន្ទាប់មកទៀត ខ្ញុំសុំធ្វើសេចក្ដីសន្និដ្ឋានខ្លះនៅក្នុងអង្គហេតុនេះ ដែលជាមូលហេតុនៃភាពចាំបាច់នៃការសុំធានាកូនក្ដីខ្ញុំបាទឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន នៅសភាស៊ើបសួរនៅតុលាការកំពូល ។ ចំណុចទី១ អង្គហេតុនេះជាអង្គហេតុមួយវាជារឿងកាតព្វកិច្ចនៃការអនុវត្តសិទ្ធិកិច្ចសន្យាក្នុងការរកស៊ីពាណិជ្ជកម្មសុទ្ធសាធ ហើយនេះមិនពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ គួរឱ្យតុលាការកំពូលពិចារណាភាពចាំបាច់ ដោយសារខ្ញុំលើកឡើងនេះដែលឯកសារដាក់ជូនសាលាដំបូង និងតុលាការកំពូលនេះសុទ្ធតែស្ដែងឡើងពីកិច្ចព្រមព្រៀងប្រតិបត្តិការរកស៊ីពាណិជ្ជកម្មទាំងអស់ មិនមានភាពទុច្ចរិតទេ ។ ប៉ុន្តែទាក់ទងនឹងការអនុវត្តកាតព្វកិច្ចក្នុងការអាក់ខានគឺចេញពីកិច្ចសន្យាសុទ្ធសាធ មិនមែនជាអំពើឆបោក ឬរំលោភលើសេចក្ដីទុកចិត្តទេ ។

ចំណុចមួយទៀត ពីបទ រំលោភលើទំនុកចិត្តនេះ គឺភាគីដើមបណ្ដឹងដែលជាជនជាតិកូរ៉េនេះ ដែលបានប្ដឹងកូនក្ដីខ្ញុំបាទ គឺបីបទល្មើស នៅសាលាដំបូងភ្នំពេញនេះ ទី១ បទ ឆបោក, រំលោភសេចក្ដីទុកចិត្ត និងមូលប្បទានបត្រគ្មានប្រាក់ ប៉ុន្តែតំណាងអយ្យការនៅសាលាដំបូងរាជធានីភ្នំពេញ គាត់បានចោទប្រកាន់បទល្មើសមួយទាក់ទងចេញសែកអត់សាច់ប្រាក់ ចំណែកពីរបទល្មើសទៀត គាត់អត់បានចោទទេ រហូតដល់អង្គហេតុទាក់ទងរឿងសែកនេះ ត្រូវបានកូនក្ដីខ្ញុំបាទប្ដឹងពីសាលាដំបូងរហូតដល់កំពូល អត់ទាន់បានសម្រេច ហើយស្រាប់តែរឿងនេះខាងដើមបណ្ដឹងគាត់បានប្ដឹងកូនក្ដីខ្ញុំបាទទៀត ទាក់ទងបទរំលោភសេចក្ដីទុកចិត្ត រហូតទាក់ទងសុំនៅក្រៅឃុំនៅក្នុងសវនាការពេលនេះ ទាក់ទងនឹងលំហូរនៃការប្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលប្ដឹងកូនក្ដីខ្ញុំបាទដល់តុលាការកំពូលនេះ ។

មូលហេតុខ្ញុំសុំឱ្យកូនក្ដីខ្ញុំនៅក្រៅឃុំជាបណ្ដោះអាសន្ន ទី១ ស្ថានភាពនៅពេលនេះ គាត់មិនអាចនិយាយបាន ព្រោះគាត់មានឧបករណ៍ទាក់ទងបេះដូង ស្ថានភាពធ្ងន់ធ្ងររ៉ាំរ៉ៃ គាត់បានសម្រាកនៅមន្ទីរពេទ្យ ៥ខែមក

ហើយ មានលិខិតដែលខ្ញុំបានដាក់ជូនតុលាការពីមន្ទីរពេទ្យខ្មែរ សូវៀត បញ្ជាក់ថា គាត់មានជម្ងឺបេះដូងធ្ងន់ធ្ងរ ។ ទី២ ទាក់ទងភស្តុតាងដែលភាគីដើមបណ្តឹងប្តឹងកូនក្តីខ្ញុំបាទនោះ គឺគាត់បានដាក់រក្សាការពារទ្រព្យសម្បត្តិកូនក្តីខ្ញុំទាំងអស់នៅសាលាដំបូងរាជធានីភ្នំពេញ ហើយរក្សាការពារនេះកូនក្តីខ្ញុំបាទមិនបានគេរាំ ឬជំទាស់ទេ ត្រូវបានរឹបអូសច្រើនបំផុតដាក់ជូនតុលាការរួចហើយ ។ ទី៣ នៅក្នុងរឿងមួយទៀត ដើមបណ្តឹងបានប្តឹងទៅតុលាការទាមទាររំលាយកិច្ចព្រមព្រៀង ហើយតុលាការភ្នំពេញ បានរំលាយកិច្ចព្រមព្រៀងនេះ និងបង្គាប់ឱ្យកូនក្តីខ្ញុំបាទប្រគល់បណ្ណកម្មសិទ្ធិនេះ គឺដើមបណ្តឹងប្តឹងរដ្ឋប្បវេណីជាងប្តឹងព្រហ្មទណ្ឌផង ក្នុងពេលតែមួយលើកូនក្តីខ្ញុំបាទ ។

ចំណុចមួយទៀត ការឃុំខ្លួនកូនក្តីខ្ញុំ គឺមិនមានភាពចាំបាច់ទេ មាត្រា ២០៥ នេះ ដោយសារកូនក្តីខ្ញុំបាទជាអ្នកជំនួញ គាត់មានប្រពន្ធមានកូន មានការងារច្បាស់លាស់ ហើយទ្រព្យសម្បត្តិទាំងអស់ភាគីដើមបណ្តឹងគាត់បានរឹបអូសហើយ ។

ចំណុចចុងក្រោយ ខ្ញុំសុំឯកឧត្តមប្រធាន ពិនិត្យទៅលើឯកសារទាំងអស់របស់ខ្ញុំ ឱ្យកូនក្តីខ្ញុំបាននៅក្រៅឃុំ។

+ជនត្រូវចោទឈ្មោះ [redacted] បានឆ្លើយថា ៖ ខ្ញុំសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំបាទ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនត្រូវចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ [redacted] ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់លោក [redacted] ជាមេធាវីតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន យោងតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ , មាត្រា ៤២០ និងមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញសម្រេចតម្កល់ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ [redacted] ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដោយសំអាងហេតុជាមូលដ្ឋានថា រឿងក្តីនេះត្រូវបានចៅក្រមស៊ើបសួរសម្រេចបិទបញ្ចប់ការស៊ើបសួរ រួចចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿង និងជនត្រូវចោទឈ្មោះ [redacted] ទៅតុលាការដើម្បីជំនុំ

ជម្រះរួចហើយ ហេតុនេះ សភាស៊ើបសួរមិនអាចពិចារណាអំពីការស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទឈ្មោះ [redacted] បានទេនោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថា ការឃុំខ្លួនបណ្ដោះអាសន្នគ្រាន់តែជាវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ ដែលត្រូវពិចារណា និងសម្រេចផ្អែកលើមូលហេតុជាក់លាក់តាមបញ្ញត្តិមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ ដែលវិធានការនេះមិនចំណុះឱ្យកិច្ចនៃការបិទការស៊ើបសួរនោះឡើយ ។

៣-យល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នជាករណីពិសេស ហើយនីតិវិធីឃុំខ្លួនក្នុងរឿងក្ដីព្រហ្មទណ្ឌត្រូវអនុវត្តឱ្យស្របតាមកិច្ចនីតិវិធីដេញដោល ដែលមានបញ្ញត្តយ៉ាងច្បាស់លាស់តាមបញ្ញត្តិមាត្រា ២០៦ (កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដែលក្នុងន័យនេះ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការចេញដីកាសម្រេចឃុំ ឬមិនឃុំខ្លួននោះ ត្រូវមានចុះសម្ដី ឬសេចក្ដីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធឱ្យបានច្បាស់លាស់ ។ ប៉ុន្តែផ្ទុយទៅវិញ បើពិនិត្យមើលលើកំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខលើកិច្ចនៃការឃុំខ្លួនលើជនត្រូវចោទឈ្មោះ [redacted] ក្នុងរឿងក្ដីនេះឃើញថា មិនមានសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ , សេចក្ដីសង្កេតរបស់ជនត្រូវឃុំខ្លួន និងមេធាវីការពាររបស់ជននោះឡើយ ។ ករណីនេះ កិច្ចនៃការឃុំខ្លួនលើជនត្រូវចោទឈ្មោះ [redacted] ក្នុងរឿងក្ដីនេះធ្វើឡើងដោយបំពានលើសិទ្ធិរបស់ភាគីពាក់ព័ន្ធ ដែលកិច្ចនេះត្រូវទុកមោឃភាពដាច់ខាត ។

ម្យ៉ាងវិញទៀត ក្នុងនីតិវិធីសម្រេចសេចក្ដីអំពីការសុំនៅក្រៅឃុំ នៅដំណាក់កាលសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញនោះ លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ឃុំបានដាក់វិញ្ញាបនបត្រគ្រូពេទ្យលេខ [redacted] ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត ដែលបានបញ្ជាក់ថា ជនត្រូវចោទឈ្មោះ [redacted] កំពុងមានជំងឺបេះដូង ដែលត្រូវទទួលការព្យាបាលយ៉ាងល្អ និងទៀងទាត់ ។

៤-យល់ឃើញថា រឿងក្ដីព្រហ្មទណ្ឌនេះត្រូវបានតំណាងអង្គការអយ្យការបានបើកការស៊ើបសួរលើជនត្រូវចោទឈ្មោះ [redacted] តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ពីបទល្មើសរំលោភលើទំនុកចិត្ត ប្រព្រឹត្តក្នុងអំឡុងឆ្នាំ២០១៥ និង២០១៧ តាមបទប្បញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ដោយផ្អែកលើពាក្យបណ្ដឹង ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលអង្គហេតុក្នុងពាក្យបណ្ដឹងនេះ ត្រូវបានដើមបណ្ដឹងរដ្ឋប្បវេណីយកមកប្ដឹងរួចម្ដងមកហើយ តាមពាក្យបណ្ដឹង ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០១៨ ហើយបណ្ដឹងអាជ្ញាត្រូវបានបើកតែលើបទល្មើសការមិនបំពេញកាតព្វកិច្ច ចំពោះឧបករណ៍ជួញដូរបោក ដូចមានបញ្ជាក់ក្នុងសំណុំរឿងនេះដោយដីកាសន្និដ្ឋានស្ពាពរលេខ [redacted] ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដដែល ។

ម្យ៉ាងវិញទៀតតាមរយៈអំណះអំណាងរបស់មេធាវីគូភាគី បានបង្ហាញឱ្យឃើញថា ជនត្រូវចោទឈ្មោះ [redacted] បាននិងកំពុងស្ថិតក្នុងឋានៈជាភាគីចុងចម្លើយក្នុងកិច្ចដំណើរការរឿងរដ្ឋប្បវេណី ដែលប្តឹងទាមទាររំលាយសកម្មភាពនៃកិច្ចសន្យាលក់ទិញដី ដែលជាប្រភពនៃទំនាស់របស់ភាគីកន្លងមកនេះផងដែរ ដែលការណ៍នេះត្រូវបញ្ជាក់ដោយសាលក្រមរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាដីកាសម្រេចរក្សាការពារដែលពាក់ព័ន្ធ ។

៥-យល់ឃើញថា ផ្អែកលើការបំពានលើកិច្ចនៃការឃុំខ្លួនបណ្តោះអាសន្ន , ស្ថានភាពសុខភាព និងស្ថានភាពគ្រួសារ , អង្គហេតុព្រហ្មទណ្ឌក្នុងរឿងក្តីនេះ ត្រូវបានភាគីក្តីយកទៅប្តឹងទាមទារទាំងក្នុងរឿងព្រហ្មទណ្ឌផង ទាំងក្នុងរឿងរដ្ឋប្បវេណីផង និងការអនុវត្តនូវបញ្ញត្តិមាត្រា ២០៣ ដែលបញ្ញត្តស្តីពីគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន នៃក្រមនីតិវិធីព្រហ្មទណ្ឌ <u>*"ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព"*</u> ។....នោះ មិនគប្បីឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទបន្តទៅទៀតនោះទេ ដើម្បីធានានូវគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ ដែលកំពុងតែកើតមានឡើងចំពោះភាគីក្តី ។

៦-យល់ឃើញថា តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សុំឱ្យតុលាការកំពូលពិចារណាទៅតាមទិដ្ឋភាពច្បាប់ ។ ចំណុចនេះ តុលាការកំពូលបានពិចារណាដូចមានក្នុងសំអាងហេតុខាងលើនេះរួចហើយ ។

៧-យល់ឃើញថា សាលដីកាលេខ [redacted] ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវនឹងគតិច្បាប់ឡើយ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-ទទួល បណ្តឹងសាទុក្ខលេខ [redacted] ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់លោក [redacted] មេធាវីតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ក្នុងការប្តឹងសាទុក្ខ ។

២-បដិសេធ សាលដីកាលេខ [redacted] ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ។

៣-បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរជាពាណិជ្ជករ ដែលត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នតាមដីកាសម្រេចឱ្យឃុំខ្លួនជាបណ្តោះអាសន្នលេខ [illegible] ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ និងតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ [redacted] ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចេញពីមណ្ឌលឃុំខ្លួន ប្រសិនបើបុគ្គលឈ្មោះនេះមិនត្រូវបានឃុំខ្លួននៅក្នុងរឿងក្តីផ្សេងទៀតនោះទេ ។